សែម - សួរ
សាស្ត្រាចារ្យបរិញ្ញាប័ត្រអក្សរសាស្ត្រខ្មែរ
វិទ្យាល័យភ្នំពេញ

មេរៀន

# វប្បធម៌ . សិក្សាខ្មែរ

មានតែងសេចក្ដីគំរូ
សម្រាប់ថ្នាក់ទីបញ្ចប់



ស្របតាមកម្មវិធីថ្មី

បណ្ណាគារ
មូលមិត្ត ក្បាលលេខ ៩៩ ផ្សារចាស់
រក្សាសិទ្ធិគ្រប់យ៉ាង

១៩៧១

CA 19

ទឹកសម – ស៊ុះ

សាស្ត្រាចារ្យបរិញ្ញាប័ត្ររក្សសាស្ត្រខ្មែរ
វិទ្យាល័យភ្នំពេញ

សង្ខេបមេរៀន

# វប្បធម៌ សិក្សាខ្មែរ

មានតែងសេចក្តីគំរូ
សម្រាប់ថ្នាក់ទីបញ្ចប់

បណ្ណាគារ
មូលមិត្ត ផ្ទះលេខ ៩៩ ផ្សារចាស់

រក្សាសិទ្ធិគ្រប់យ៉ាង

-១៩៧១-

# កម្មវិធីថ្នាក់ទីបញ្ចប់

## វប្បធម៌ - អរិយធម៌ខ្មែរ

---

### ១.- សេចក្តីផ្តើម

– គោលបំណងនិងន័យនៃការសិក្សាវប្បធម៌ - អរិយធម៌ខ្មែរ

– ទំនាក់ទំនងរវាងវប្បធម៌-អរិយធម៌

– ការសិក្សាប្រៀបធៀបវប្បធម៌ឥណ្ឌានិងវប្បធម៌ខ្មែរ

### ២– មូលធម៌នៃវប្បធម៌ឥណ្ឌា

១– វេទនិយម (បញ្ញាពុទ្ធិ, ការៈ, សុខៈ)

២– ព្រាហ្មណ៍និយម (បញ្ញាពុទ្ធិ, ការៈ, សុខៈ)

ក) ព្រហ្មនិយម

ខ) វិស្ណុនិយម

គ) សិវនិយម

៣– ពុទ្ធសាសនា (លទ្ធិពុទ្ធ)

ក) ពុទ្ធប្រវត្តិ – ពុទ្ធប្រវត្តិសង្ខេប

– ពន្លឺអាស៊ីទ្វីប

– រំពឹព្រះពុទ្ធសាសនា (ល្វី ហ្វីណុត)

ខ) ពុទ្ធលទ្ធិ – អរិយសច្ចធម៌ (ភិម - ស៊ី)

– ទស្សនវិជ្ជានិងពុទ្ធសាសនា (ប៉ាំង - ខាត់)

### ៣– មូលធម៌នៃវប្បធម៌ខ្មែរ

– ព្រាហ្មណ៍និយម (ក្នុងសិល្បៈ អក្សរសិល្ប៍ ជំនឿ ទំនៀមទំលាប់)

– ពុទ្ធនិយម ( " )

– ខ្មែរនិយម ( " )

– បរទេសនិយម ( " )

### ៤– មូលបទនៃវប្បធម៌ឥណ្ឌា - ខ្មែរ (ដូចក្នុងផ្នែកទី១ - ប្រៀបធៀប)

### ៥– យោបល់បញ្ចប់

– តម្លៃនៃវប្បធម៌ខ្មែរក្នុងក្របខ័ណ្ឌអរិយធម៌ពិភពលោក ។

× × ×

# សង្ខេបមេរៀន

## វប្បធម៌ឥណ្ឌា – ខ្មែរ

### សេចក្ដីផ្ដើម–

ប្រជាជាតិខ្មែរយើង ជាជាតិសាសន៍មួយមានគ្រឹះ តាំងមូលដ្ឋានជាតិ និងលក្ខណៈជាតិច្បាស់លាស់ - តែប៉ុន្មានឆ្នាំមុនជាងនេះជាតិយើងផ្សាយសុវណ្ណភូមិនេះ ព្រោះខ្មែរមានវប្បធម៌-អរិយធម៌ចាស់ទុំ និងពិតប្រាកដជាងគេទាំងអស់ ព្រោះខាងភស្តុតាងនៅជាក់ច្បាស់ទល់សព្វថ្ងៃ ហើយទោះបីមានវប្បធម៌-អរិយធម៌ នៃជនជាតិដទៃ បានជះឥទ្ធិពលមកលើ ក៏វប្បធម៌-អរិយធម៌ នៅតែរក្សាលក្ខណៈនិងបុគ្គលភាពរបស់ខ្លួនដដែល ។

ក្នុងចំណោមវប្បធម៌ - អរិយធម៌នានាដែលបានផ្សាយចូលមកស្រុកខ្មែរនៅសម័យដើម, វប្បធម៌-អរិយធម៌ឥណ្ឌាបានផ្សាយឥទ្ធិពលមកលើវប្បធម៌ - អរិយធម៌ខ្មែរមុនគេ ហើយដោយទៅក្នុងសភាពលក្ខណៈរបស់ខ្លួន មានធាតុ, មូលដ្ឋានស្របខ្លួនត្រូវគ្នានឹងលក្ខណៈខ្មែរ ទើបខ្មែរទទួលយកមកចុកដាក់ក្នុងវប្បធម៌អរិយធម៌របស់ខ្លួនដោយច្រើន ប៉ុន្តែខ្មែរពុំ...យកទាំងស្រុង ទាំងដុល មកចុកដាក់ជារបស់ខ្លួនទេ គឺខ្មែរបានកែច្នៃបំប្លែងឲ្យមានលក្ខណៈ និងបុគ្គលភាពស្របស្រួលតាមលក្ខណៈនិងបុគ្គលភាពរបស់ខ្មែរស្ទើរតែទាំងអស់ ទោះក្នុងព្រាហ្មណ៍និយមក៏ដូចពុទ្ធនិយមដែរ ។

ដោយហេតុនេះហើយ បានជាក្នុងការសិក្សាស្វែងរកអំពីវប្បធម៌ - អរិយធម៌ខ្មែរ អ្នកសិក្សាត្រូវសិក្សាភ្ជាប់នូវវប្បធម៌ឥណ្ឌានិងខ្មែរ ព្រមទាំងធ្វើការគប់ចែកនូវធាតុដើមនៃវប្បធម៌ទាំងពីរនេះផង ជាពិសេសអ្នកសិក្សាត្រូវតែសិក្សានូវធាតុសំខាន់ៗ នៃវប្បធម៌ទាំងពីរដែលទាក់ទងគ្នានេះឯង ។

### អត្ថន័យ–

ពាក្យ "វប្បធម៌" សំគាល់អំពើ, កិច្ចការ, ... ផលិតផលនិងរូបភាពនៃអំពើនានារបស់មនុស្សជាតិនីមួយៗ ដែលមានការក្រកៀកលើកដោះគេឃើញ – ជាដំណាក់តាមមធ្យោបាយរបស់ខ្លួន ។ ...ធាតុ - វិធីប្រមើលភាពមួយ ដែលមនុស្សជាតិបានសាបព្រួសដាក់ ប្រឌិតបង្កើតសម្រាប់ស្រុក

មនុស្ស ។ មិនតែប៉ុណ្ណោះ វប្បធម៌ជាសាខានៃកត្តាលើកស្ទួយនិងជាការចេះដឹងនៃវិថីជាទៀត ។

រីឯពាក្យអរិយធម៌វិញ គឺជាលក្ខណៈនៃវប្បធម៌ប្រពន្ធ គេច្រើនតែភ្ជាប់ពាក្យ អរិយធម៌ជាមួយនឹងពាក្យវប្បធម៌ ដូចជាវប្បធម៌-អរិយធម៌ ប៉ុន្តែពាក្យ ២ ម៉ាត់សម្រាប់សំគាល់ផលនៃពាក្យមនុស្សគ្នា ផ្សេងពីគ្នា ព្រោះវប្បធម៌កើតមុន ហើយទៃកតាម ទើបកើតជាអរិយធម៌មួយៗ តាមសម័យជាតិសាសន៍ផ្សេងៗគ្នា ។ ដូច្នេះយើងនឹងឃើញភាពខុសគ្នារវាងវប្បធម៌-អរិយធម៌ៈ គឺអរិយធម៌មានអ្វីខ្លះ ? ហើយវប្បធម៌មានអ្វីខ្លះ ?

- អរិយធម៌
  - វប្បធម៌
    - ចំណេះ
      - ជំនឿ
      - សាសនា
      - វិជ្ជា
    - ការផ្សាយ
      - សញ្ញា
      - អក្សរ - ភាសា
      - សិល្បៈ
    - អនុវត្តន៍
      - ទំនៀមទំលាប់ - ប្រពៃណី
      - ការសិក្សា - អប់រំ
      - ល្បែង - កីឡា
  - សង្គមធម៌
    - ប្រដាប់ប្រដា
      - គ្រឿងរស់
      - គ្រឿងរបរ
      - គ្រឿងឧបភោគទេស
    - របៀបរបប
      - សេដ្ឋកិច្ច
      - សង្គមកិច្ច
      - នយោបាយ
    - ទម្រង់ក្រោយសង្គម
      - ក្រុមគ្រួសារ
      - ជាន់ថ្នាក់
      - អង្គការ

ដូច្នេះ វប្បធម៌និងសង្គមធម៌ ជាមូលដ្ឋាននៃអរិយធម៌នេះឯង ហើយនៅក្នុងវប្បធម៌មាន ចែកជាន់ខ្ពស់ ១ ជាន់ទាប ១ ថែមទៀត ។

× × ×

# មូលដ្ឋាន
# នៃវប្បធម៌ខ្មែរ

បានជាយើងលើកយកបញ្ហានេះ មកល្បងសិក្សាជាមុនដូច្នេះ ដោយហេតុថា យើងត្រូវស្គាល់វប្បធម៌ដើមនៃខ្លួនយើងជាមុនសិន មុននឹងស្គាល់វប្បធម៌មួយចំនួនទៀត ពីវប្បធម៌ឥណ្ឌា - ខ្មែរហើយនឹង ព្រោះវង្វេងយើងពិតជាមានវប្បធម៌ស្រុកតាមមួយ ដែលជារបស់ខ្មែរផ្ទាល់នៅលើដីខ្មែរស្រាប់ទៅហើយ ទើបមានវប្បធម៌ថ្មីដែលឥណ្ឌានាំចូលមកបង្រួបបង្រួមគ្នាជាមួយវប្បធម៌ដើមនេះ ។ ដំបូងយើងត្រូវស្គាល់តាមលំដាប់ខាងក្រោមនេះ ៖

## ១- កំណើតជនជាតិខ្មែរ

ក) អំបូរពូជសាសន៍ — គឺពូជសាសន៍មន - ខ្មែរ ដែលរស់នៅក្នុងតំបន់ព្រោយសុវណ្ណភូមិ (ដែនដីសម្បូណ៌មាស) មានជាតិសាសន៍ជាមនុស្សជាតិដើមនៅលើទឹកដីនេះដែរ មកពីឥណ្ឌា – ជ្វា – ចិន ផង ។

ខ) ឈ្មោះខ្មែរ — បើយោលទៅតាមប្រវត្តិសាស្ត្រ ពាក្យថា ខ្មែរ ( ខ្មែរ ) មកពីពាក្យកម្ពុ ជាឈ្មោះរបស់ព្រះឥសីម្នាក់ដែលជាប្រមុខនៃកម្ពុជ ។ ការហៅឈ្មោះរបស់កម្ពុជនឹងទាន់មេកបានជាកម្ពុមេក > កម្មេក > កមេក > កមេរ > ក្មេរ > ក្មែរ > ខ្មែរ នេះឯង ហើយក្នុងសិលាចារឹកមានសរសេរជាក្មេរឬក្មែរ តែប៉ុណ្ណោះ ។

បើតាមឯកសារខ្លះទៀត ពាក្យថា "ខ្មែរ" នេះ ក្លាយមកពីពាក្យថា "ក្មេរ" គឺជាឈ្មោះដែនដីមួយផ្នែកនៃប្រទេសឥណ្ឌាសម័យបូរាណ ។ ហើយក្នុងសម័យបច្ចុប្បន្ន គេក៏សរសេរថា "ក្មេរ ឬក្មែរ" នៅឡើយ ។ តំណតមក ពាក្យ ក្មេរ ឬក្មែរនេះ ក្លាយរូបមកជា "ខ្មែរ" ដូចសព្វថ្ងៃ ។

## ២-អំពីកំណើតស្រុកខ្មែរ

### ក-កំណកំណើត.-

ស្រុកខេមរខ្មែរកើតដោយភ្ជាប់ស្រុកចេនឡាខាងលើ (ខាងជើង) និងស្រុកនគរភ្នំ(ហ្វូណន) ខាងក្រោម (ខាងត្បូង) ។

### ខ-ពេលវេលា.-

មនុស្សបុរាណរស់នៅលើស្រុកខ្មែរនេះតាំងពីប្រហែល ៦ សែនឆ្នាំមុន គ.ស ហើយបើគិតពីការភ្ជាប់ស្រុកចេនឡា និងហ្វូណន គឺនៅដើមសតវត្សទីមួយនៃ គ.ស ។

## ៣-កំណើតវប្បធម៌ខ្មែរ

ក-អ្នកបង្កើត- គឺខ្មែរ · មន · សម្រែ · ព្នង

ខ-ពេលវេលា- ពី ៦ សែនមក ១៦.០០០ ឆ្នាំមុន គ.ស

គ-ទីកន្លែង- នៅសំរោងសែន (កំពង់ឆ្នាំង) ម្លូព្រៃ (កំពង់ធំ)

ឃ-វត្ថុ-ប្រដាប់- ខានក្អម · ឆ្នាំង · ពាង ។ល។

## ៤- ចំណែកនៃវប្បធម៌ខ្មែរ

ដើម្បីងាយសិក្សាអំពីវប្បធម៌ខ្មែរជាផ្នែកៗ គេត្រូវចែកវប្បធម៌នេះជា៤ផ្នែកគឺ:

ក- វប្បធម៌បុរេប្រវត្តិ តាំងពីដើមមកទល់គ្រិស្តសតវត្សទី ១ ។

ខ- វប្បធម៌មុនអង្គរ- ពីសតវត្សទី១ ដល់សតវត្សទី៨ នៃ គ.ស ។

គ- វប្បធម៌សម័យអង្គរ- ពីសតវត្សទី៨ ដល់សតវត្សទី ១៣ ។

ឃ- វប្បធម៌ក្រោយសម័យអង្គរ- ពីសតវត្សទី១៤ ដល់ទី១៩ នៃ គ.ស ។

### កំណត់ចំណាំ.-

តទៅយើងនឹងសិក្សាតែវប្បធម៌បុរេប្រវត្តិតែមួយផ្នែកប៉ុណ្ណោះ ដោយហេតុថា វប្បធម៌ខ្មែរផ្នែកនេះ ពុំទាន់មានវប្បធម៌ណាចូលមកជះឥទ្ធិពលទាក់ទងគ្នានៅឡើយ ។

## វប្បធម៌បុរេប្រវត្តិ.-

**វប្បធម៌បុរេប្រវត្តិ**

- ១- ជំនឿ
  - ជឿខ្មោច - ព្រាយ - អាប - អ្នកតា
  - សៀនអារក្ស - អ្នកតា - បន់បង់
  - ធ្វើពិធីបូជាគ្រឿងស័ក្ដិសិទ្ធិ
- ២- វិជ្ជា
  - ចេះយកដីធ្វើក្អម - ឆ្នាំង - ក្រឡ
  - ចេះយកដែកធ្វើកាំបិត - ល្ពង - ព្រួញ
  - ចេះធ្វើស្រាផឹក
- ៣- ភាសា-អក្សរ
  - ភាសាខ្មែរ-មន
  - គ្មានប្រើអក្សរ
- ៤- សិល្បៈ
  - ចេះធ្វើកណាត់សំពត់
  - ចេះធ្វើពាង - ក្រឡ - កន្ថៃ - ជើង
  - ចេះធ្វើក្បាច់ល្អ
- ៥- ទំនៀមទម្លាប់
  - ស្រីៗចេះធ្វើបំពេញការងារនៅផ្ទះ
  - ប្រុសៗ ធ្វើការខាងក្រៅ
  - កប់ខ្មោចឱ្យអង្គុយក្នុងពាង

## យោបល់រួម.-

ខ្មែរមានវប្បធម៌រួចមកហើយ តាមមនោគតិ តាមទំនោរចំណង់ចិត្តគាត់ពីសម័យដើមដំបូង រហូតទាល់តែពេលដែលវប្បធម៌ណាមួយចូលមកផ្សព្វផ្សាយជាមួយនឹងវប្បធម៌ខ្មែរ នៅដើមគ្រិស្តសតវត្សទី ១ មោះ៦៥ ។

× × ×

## ១- មូលធម៌នៃវប្បធម៌ឥណ្ឌា

### វិភាគវប្បធម៌ឥណ្ឌា.-

តាមធម្មតា គេតែងចែកវប្បធម៌ឥណ្ឌាជា ៤ ផ្នែក ព្រោះផ្នែកនីមួយៗ គឺជាមូលដ្ឋានទ្រទ្រង់វប្បធម៌នោះទាំងមូលគឺ :

១-វេទនិយម

២-ព្រាហ្មណ៍និយម

៣-ហិណ្ឌូនិយម

៤-ពុទ្ធនិយម

គោលនិយមមួយៗ ត្រូវមាន ៣ ផ្នែកទៀត លើកលែងតែហិណ្ឌូនិយមមួយចេញ ដែលមានគោលនិយម ៣ ដែរ តែផ្សេងគ្នា ។ គោលនិយមក្នុងវេទនិយម, ព្រាហ្មណ៍និយម និងពុទ្ធនិយមមាន ៣ ផ្នែកដូចគ្នាគឺ :

ក-បញ្ហា ពុទ្ធិ La Connaissance

ខ-បញ្ហា ភាព L'être

គ-បញ្ហាសុខ: Le Bonheur

ឯហិណ្ឌូនិយម មាន ៣ ផ្នែកដែរគឺ:

ក-ព្រហ្មនិយម

ខ-វិស្ណុនិយម

គ-សិវនិយម

គួរចំណាំថា នៅក្នុងព្រាហ្មណ៍និយម ក៏មានបញ្ហាព្រះព្រហ្ម, វិស្ណុ និង សិវៈនេះដែរ ។

### វេទនិយម

១- ន័យនៃវេទនិយម.-

លើគម្ពីរវេទ ។ គម្ពីរនេះ ជាចំណេះវិជ្ជា, គំនិត, កម្រងមន្តអាគម, អត្ថបទ, មូលដ្ឋាននិងជា វិធីរបៀបរៀបចំសង្គមមនុស្ស ដែលពួកអារ្យាន់ នាំចូលមកក្នុងប្រទេសឥណ្ឌា ។

២-អ្នកបង្កបង្កើត.-

ក- តាមមតិយោបល់ព្រាហ្មណ៍.- គឺជាអាទិទេពឈ្មោះបុរេសៈ ដែលផ្តល់គម្ពីរវេទ មកឲ្យឥសីៗបានយកមកបង្ហាត់បង្ហាញផ្តល់ឲ្យពួកព្រាហ្មណ៍ ។

ខ- តាមចលនាប្រវត្តិសាស្ត្រ.- គឺពួកមិលក្ខៈនិងពួកអាយ៉ិន ដែលបានរួមគំនិត, មនោគតិ បង្កើតគម្ពីរវេទនេះឯង ព្រោះមិលក្ខៈនេះ ជាពួកមនុស្សដែលជាម្ចាស់ដើមនៃស្រុកឥណ្ឌា ឯពួកអាយ៉ិនជាពនេចរ (ចើរព្រៃ) ដែលបានមកបង្ក្រាបលុកលុយប្រទេសឥណ្ឌាផ្នែកខាងជើង ហើយដោយខ្លួនទាំងពួក មានវប្បធម៌នៅក្នុងខ្លួនស្រាប់ ក៏ផ្តើមបង្កើតគម្ពីរវេទនេះឡើង ។

៣- រយៈពេលបង្កើត.-

គម្ពីរវេទត្រូវពួកមិលក្ខៈនិងអាយ៉ិន បង្កើតឡើងក្នុងរយៈពេល ពី១៥០០ដល់១០០០ឆ្នាំ មុន គ.ស ។

៤- ចំណែកនៃគម្ពីរវេទ.-

គម្ពីរវេទ ចែកចេញជា ៤ ផ្នែកគឺ:

ក- ឫគ្វេទ (ឫគវេទ) **Rgveda** .- ជាគម្ពីរមានចំណាស់ជាងគេ ហើយជាគម្ពីរមានគាថាសម្រាប់សូត្រ អង្វរបន់ស្រន់ ឬសរសើរអាទិទេព និងសូត្រធ្វើរីត ( Rite ), សូត្រក្នុងពិធីបូជាយញ្ញ ។

ខ- យជុរវេទ **Yajurveda** .- ជាគម្ពីរដែលមានចំណាស់បន្ទាប់ពី គម្ពីរឫគ្វេទប្រហែល ៦០០ ឆ្នាំមុន គ.ស. មានបទគាថាសំរាប់ធ្វើរីត និងបទពន្យល់ពីការធ្វើរីត ក្នុងពិធីបូជាយញ្ញផ្សេងៗ ។ ជាងនេះទៀត មានការរៀបរៀងបន្ថែមពីអត្ថបទសំរាប់បូជាផ្សេងទៀត ដូចជា:

-ការបូជាចំពោះទេវតា ដែលមហាក្សត្រនិងព្រាហ្មណ៍ត្រូវធ្វើឡើង ។

-ការបូជាក្នុងពិធីរាជាភិសេក ។

– ពិធីបូជាដែលមហាក្សត្រត្រូវធ្វើ ដើម្បីពង្រីកទឹកដីទៅជាចក្រពត្រាធិរាជ (អស្វមេធ) ។

គ– សាមវេទ Samaveda.– ជាគម្ពីរកើតក្នុងជំនាន់យជុរវេទដែរ គឺជាក្បួនដែលពោលអំពីបទកំណាព្យ សម្រាប់ច្រៀងបូជាពលីសូត្រសរសើរបន្ទន់ចិត្តព្រះអាទិទេពជាដើម ក្នុងពេលបូជាទឹកសោម ។ ដែលគឺមាន :

– ចម្រៀងសម្រាប់ច្រៀងក្នុងព្រៃ ។

– ចម្រៀងសម្រាប់ច្រៀងក្នុងភូមិស្ថាន ដើម្បីសុខសួស្តី ។

ឃ– អថវវេទ Atharvaveda.– ជាគម្ពីរកើតក្រោយបង្អស់ ហើយជាគម្ពីរដែលមានវេទមន្ត ស្នេហ៍កាគម សម្រាប់ស្រោចស្រង់ស្រឡាញ់ និងសម្រាប់បណ្ដេញខ្មោចបិសាចចង្រៃនានា ។

## ឃ្លាបញ្ជាប់សេចក្ដី.–

គោលគំនិតនៃគម្ពីរវេទទាំង ៤ គឺនាំការពារខ្លួនទៅនឹងសង្វេគៈវត្ថុ ដែលបានលើកយកបញ្ហាដែលជាគោលនិយមបួនប្រការ ៣ យ៉ាង គឺ បញ្ញាគតិ, កាមៈ និងសុខៈ មកដោះស្រាយជានិច្ច ។

## បញ្ហាពុទ្ធិក្នុងវេទនិយម

ពុទ្ធិ បានដល់ការដឹង, វិជ្ជា, គំនិត, យោបល់យល់ ដែលមានសភាពនៅខាងក្រៅ និងខាងក្នុងនៃមនុស្ស ។ ចំណែកនៃពុទ្ធិ មាន ៣ប្រភេទគឺ :

១– ពុទ្ធិវត្ថុ **Objet de la connaissance**

២– ពុទ្ធិវិធី **Méthode de la connaissance**

៣– ពុទ្ធិវាទ **Théorie de la connaissance**

### ១– ពុទ្ធិវត្ថុ Objet de la connaissance.–

បានដល់វត្ថុទាំងឡាយ គ្រឿងប្រដាប់ខាងក្រៅសម្រាប់បង្កើតពុទ្ធិ ដែលជាវិជ្ជា, ចំណេះ, បញ្ញា, ការស្គាល់ដឹងនានា ។ ក្នុងវេទនិយម ពុទ្ធិស្ថិតនៅលើអំណោយទេវតា ដែលមាន

គម្ពីរវេទទាំង ៤ ជាគ្រឿងប្រដាប់ខ្ពស់បំផុត គឺ ឫគ្វេទ, យជុរវេទ, សាមវេទនិងអថរ្វវេទ ។ ក្រៅ ពីនេះ មានគម្ពីរ ៣ ផ្សេងទៀត ដែលជាឧបករណ៍ដ៏សំខាន់គឺៈ

ក- សំហិតា.- ជាប្រជុំនៃបទគាថា ដែលនិយាយពីការបួងសួង បូជានិង សរសើរអាទិទេព ។

ខ- ព្រាហ្មណៈ.- ជាគម្ពីរនិយាយពីពិធីបូជាយញ្ញ ដែលមានអាយុប្រមាណ ១.០០០ ឆ្នាំមុន គ.ស ។

គ- ឧបនិស្សទ.- ជាក្បួនទស្សនវិជ្ជា ដែលនិយាយពីទ្រឹស្តីនៃលោកៈ និង ទេវៈ ហើយដែលជាប់ទាក់ទងទៅនឹងព្រហ្មន មានអាយុប្រមាណ ៨០០ ឆ្នាំមុន គ.ស ។

ឃ- អរញ្ញក (អារណ្យក).- ជាគម្ពីរធម៌កថារបស់ពួកឫសី សំរាប់សូត្រ ដេញខ្មោចបិសាចនៅក្នុងព្រៃ ដែលមានអាយុជំនាន់គ្នានឹងគម្ពីរឧបនិស្សទដែរ ។

គម្ពីរក្បួនច្បាប់ ដែលជាអំណោយនៃអាទិទេពទាំងនេះ ជាកត្តា និងជាទ្រឹស្តីនៃពុទ្ធិវេទ ។

២- ពុទ្ធិវិធី **Méthode de la connaissance.**—

គឺជាវិធីសំរាប់បង្កើតឱ្យមានពុទ្ធិ ដែលជាចំណេះចេះដឹង, ជាវិជ្ជា នោះឯង ។ វិធីធ្វើឱ្យ មានពុទ្ធិនេះ ស្ថិតនៅលើ ៖

ក- សិក្សាគម្ពីរវេទ.- ដែលទុកជាមធ្យោបាយបណ្តុះចំណេះវិជ្ជា ។

ខ- សូត្រមន្តអាគមគាថា .- ជាពាក្យស័ក្តិសិទ្ធិរបស់អាទិទេព ។

គ- បូជាយញ្ញ .- តាមវិធីផ្សេងៗ មានការសំឡាប់ មនុស្ស-សត្វ ដើម្បីបូជា អាទិទេព ។

ឃ- ពិចារណា.- ដោយការខំរិះគិតពិចារណាឯកភាពនៃអាត្មន់និងព្រហ្មន ដែល ជាប់ទាក់ទងគ្នា និងដាច់ចេញពីគ្នាជាអស្តូប ។

វិធីទាំងនេះ មនុស្សអាចធ្វើបានដោយការប្រព្រឹត្ត, ដោយបរិយាគតិដ៏ខំខន តាមចំណង់ របស់ខ្លួន ។

## ៣- ញុត្តិវាទ Théorie de la connaissance .–

ទ្រឹស្តីនៃការសម្រេចគតិ ដែលជាវិជ្ជាបឋមនេះ គឺជាកំណាយនៃអាទិទេព យ៉ាងស្ងួតស្ងាត់ បានសេចក្តីថា បានសម្រេចឬមិនបានសម្រេចស្រេចនៅលើអាទិទេព ។ អ្នកដែលមានបុណ្យសិទ្ធិអាចនឹងសិក្សារៀនសូត្រប្រព្រឹត្តបាន មានតែពួកព្រាហ្មណ៍ប៉ុណ្ណោះ ។

### បញ្ហាភាវៈក្នុងវេទនិយម

ភាវៈបានផលិតធម្មជាតិទាំងអស់ មានលោកៈ, មនុស្ស, សត្វ, រុក្ខជាតិ, ទេវៈ, កាយ, ចិត្ត, អគ្គិន, ភ្លើងខ្យល់, អាទិទេព ជាដើម ។ ភាវៈនេះមានមូលដ្ឋានឬមូលធាតុ៣យ៉ាងសំខាន់គឺ :

១- ភាពនិម្មាណ

២- ភាពវិធី

៣- ភាពវាទ

### ១- ភាពនិម្មាណៈ.–

លក្ខណៈរួមនៃធាតុ៤គឺ ទឹក ដី ភ្លើង ខ្យល់ ផ្សំបង្កើតបានជាធម្មជាតិ : មនុស្ស, សត្វ, ជាតិ, ទេវៈ ដែលជារូបកាយ ឬ ជាភូត ហើយភូតនេះ កាលជួបនឹងព្រលឹង, វិញ្ញាណ បង្កើតធាតុនេះ ហើយក៏កកើតទៅជាលោក ៣ គឺ : ទេវលោក, មនុស្សលោក និងយមលោក បាតាល ។

ក- បញ្ហាទេវលោក.– កន្លែង ឬ លំនៅនៃទេវ ដែលមានទេវៈច្រើនរស់នៅនិងគ្រប់គ្រង ។ ទេវៈក្នុងឫគ្វេទមានគួរសំខាន់គឺ :

-ព្រះឥន្ទ្រ.– ជាទេវៈបង្កើតផ្គររន្ទះគំហកាច់សង្គ្រាម ហើយមាន[illegible] ។ ប៉ុន្តែមកក្រោយទៀតបានចុះខ្លួនទៅវិញ ព្រោះចាញ់សង្គ្រាម ពួកអសុរញ៉ើក ហើយមិនតែប៉ុណ្ណោះ ព្រះឥន្ទ្រជាទេវៈ មិនល្អប្រព្រឹត្តបាយបុកផ្សងនឹងសីលធម៌យ៉ាងខ្លាំង ដូចជាសេពសុរាទឹកស្រវឹង, មានស្រីស្នំច្រើន ហើយប្រព្រឹត្តខុសក្នុងកាមគុណ ដូចជា

លួចប្រពន្ធគេជាដើម ។

.- ក្នុងសិល្បៈ ព្រះឥន្ទមានពណ៌ខៀវ ជិះដំរីឰរាវណ, កាន់ដំបងពេជ្រ, កងចក្រ, ព្នួជៅ, កង្វេរ ។

ព្រះឥន្ទមានមហេសី ៤ ឈ្មោះនាង សុធម្មា, សុជាតា, សុចិត្តានិងសុនន្ទា ។

- **ព្រះវរុណ**.- ជាទេវៈបង្កើតភ្លៀងនិងទឹក ជាបងបង្កើតរបស់ព្រះអាទិត្យ ចូលចិត្តពាក្យទៀងត្រង់ ចាំឃ្លាំមើលការប្រព្រឹត្តល្អអាក្រក់របស់មនុស្ស ។ ខ្មែរហៅថាព្រះពិរុណ ជាទេវៈមានរូបល្អណាស់ ។

.- ក្នុងសិល្បៈខ្មែរ ជារូបមនុស្សជិះនាគ ឬហង្ស ។

- **ព្រះអាទិត្យ**.- ជាទេវៈបង្កើតកំដៅ, ពន្លឺ, បង្កើតនិងបំបាត់ជម្ងឺ និង ជាចៅក្រមកាត់ទោសមនុស្សលោក ។

.- ក្នុងសិល្បៈខ្មែរ ព្រះអាទិត្យជារូបទេវៈជិះរទេះសេះ គង់លើផ្កាឈូក នៅនឹងកេស (ក្បាល) មានរស្មី ៦ ពណ៌ (ឆព្វណ្ណរង្សី) ។

- **ព្រះយមៈ**.- ជាទេវៈអ្នកផ្ដន្ទាទោសមនុស្ស (ទាំងរស់ទាំងស្លាប់) គឺជាទេវៈតំណាងមរណៈ ឬ មច្ចុ (សេចក្ដីស្លាប់) ហើយជាទេវៈនៅទៀងត្រង់ (ធម្ម) មិនបេះផ្លាស់ប្ដូរឡើយ ទាំងឋានៈនិងរូប ។

.- នៅក្នុងសិល្បៈខ្មែរ ព្រះយមជាទេវៈជិះដំរី កាន់ដំបង, ព្នួជៅ, កាំបិតស្បៀក, ខ្សែ និងបាស ។

- **ព្រះអគ្គិ**.- ជាទេវៈតំណាងភ្លើង ជាសាក្សីនៃសេចក្ដីល្អរបស់មនុស្ស ។

.- ក្នុងសិល្បៈខ្មែរ ព្រះអគ្គិ មានរូបជាមនុស្សក្បាលពីរ ដៃបួន ជិះចៀមឈ្មោល កាន់ព្នួជៅ, ស្លាបព្រា, ភ្លើងនិងទឹក ។

- **ព្រះរុទ្រៈ** .- ជាទេវៈមានសំណាបនិងកំហឹងច្រើន ខ្លាំងក្លៃ មានមហេសីច្រើន តំណាងចម្បាំង ។

- **ព្រះកុវេរៈ**.- ជាទេវៈតំណាងសច្ចៈ (ទៀងត្រង់) មានគេ[illegible]ចិត្តច្រើន និងជាទេវៈតំណាងទ្រព្យសម្បត្តិផង ។

.- ក្នុងសិល្បៈខ្មែរ ព្រះកុវេរៈមានរូបជាបិសាច វិកលវិការ មានធ្មេញ ៨ ភ្នែក ៣ ។

- **ព្រះចន្ទ** .- ជាទេវៈតំណាងរុក្ខជាតិ និងរូបល្អ កើតពីទឹកសោម ([illegible])។

.- ក្នុងសិល្បៈខ្មែរ ព្រះចន្ទជាមនុស្សមានរូបល្អឆើត ជិះសេះ[illegible] ឬ អង្គុយលើផ្កាឈូក ។

- **ព្រះព្រហស្បតី**.- ជាទេវៈតំណាងការចេះដឹង ព្រះគ្រូនៃមនុស្សលោក ។ កាលដើមជាទីប្រឹក្សានៃព្រះឥន្ទ ។

- **ព្រះវាយុ** (ព្រះពាយ).- ជាទេវៈតំណាងធាតុត្រជាក់, ខ្យល់ ។ ក្នុងរឿងរាមកេរ្តិ៍ខ្មែរ ព្រះពាយជាបិតាហនុមាន ។

ទេវៈទាំងនេះ មនុស្សតែងគោរពបូជានិងកោតខ្លាចថែមទៀត ហើយក្នុងសម័យក្រោយវេទនិយម ដូចជាសម័យព្រាហ្មណ៍និយម និងពុទ្ធនិយម គឺមនុស្សនៅគោរពទេវៈ[illegible]ដែរ ។ ជាងនេះ មានទេវៈជាច្រើនអង្គទៀត ដូចព្រះគង្គា, ព្រះសុក្រ, ព្រះពៃស្រពណ៍ ជាដើម ។

ខ- បញ្ហាមនុស្សលោក.-

លំនៅនៃមនុស្សរស់នៅ ត្រង់ជុំវិញចង្កេះភ្នំព្រះសុមេរុ ។ មនុស្សនេះមាន[illegible]បែងចែកជាវណ្ណៈ (ពណ៌ - ប្រភេទ) ៤ យ៉ាងគឺ :

**១- វណ្ណៈព្រាហ្មណ៍** .- ជាវណ្ណៈខ្ពស់ជាងគេ កើតពីព្រះមុខព្រហ្ម ជាអ្នកថែរក្សានិងនាំពាក្យនៃពួកទេព ហើយជាគ្រូបង្រៀនសាសនាដល់មនុស្សលោក ។ ព្រាហ្មណ៍ស្លៀកពាក់ស មានសិទ្ធិរៀនសូត្រគម្ពីរវេទគ្រប់យ៉ាងបាន ។

**២- វណ្ណៈក្សត្រ** .- ជាវណ្ណៈទី២ កើតពីព្រះហស្តព្រហ្ម មានមុខងារជា[illegible]ទឹកដី ថែរក្សាការពារទឹកដីនិងធ្វើចម្បាំងព្រមទាំងរៀនយុទ្ធវិធីនានាផង ។ វណ្ណៈក្សត្រស្លៀកពាក់ក្រហម ជានិមិត្តរូបនៃសេចក្តីក្លាហាន ។

៣- វណ្ណៈវេស្ស (វៃស្យ) .— ជាវណ្ណៈដែលកើតពីភ្លៅព្រហ្ម មានមុខងារជាអ្នកកសិ ធ្វើស្រែចំការនិងជំនួញផ្សេងៗ ស្លៀកពាក់ពណ៌លឿង ។

៤- វណ្ណៈសុទ្ទៈ (សូទ្រៈ) .— ជាវណ្ណៈកើតពីជើងព្រហ្ម មានមុខងារជាខ្ញុំបំរើគេ (ខ្ញុំបំរើវណ្ណៈទាំងបីខាងលើ) ស្លៀកពាក់ពណ៌ខ្មៅ ។

វណ្ណៈទាំង៤ នេះ មានជីវភាព, មុខរបរ, ការយកស្វាមី ភរិយា ដាច់ស្រឡះពីគ្នា ។ បើព្រាហ្មណ៍, ក្សត្រ្យ វេស្ស បានលបសាហាយស្មន់ជាមួយវណ្ណៈសូទ្រៈ ហើយបានកូនមក កូននោះហៅថា មនុស្សចណ្ឌាល ជាក្រុមមនុស្សមួយពួកទៀត ដែលប្រកបដោយក្តីថោកទាបក្រៃពេក ប្រៀបបាននឹងសត្វធាតុ ។

គ- បញ្ហាបាតាល (យមលោក) .—

បាតាលជាលំនៅមួយទៀត នៃពួកមនុស្សសត្វដែលមានកំហុសធ្ងន់ ។ បាតាលចែកជា ៤ គឺ :

១- នរក .— លោកជាលំនៅនៃមនុស្ស ដែលមានទោសធ្ងន់ ត្រូវធ្វើទុក្ខទោស ។ នរកមាន ១៨ កន្លែង មានអវិចី, លោហកុម្ភី ជាដើម ។

២- ប្រេត .— លោកជាលំនៅនៃមនុស្សសត្វ ដែលបានទទួលទោសធ្ងន់រួចហើយ ក៏មកយកកំណើតក្នុងប្រេតវិស័យ ដែលពោរពេញទៅដោយការក្រៀវក្រំអត់ឃ្លាន គ្មានអ្វីស៊ីចុក មានរូបធំប៉ុនត្នោត តែមាត់ប៉ុនម្ជុល ជាដើម ។

៣- អសុរកាយ.— លោកជាលំនៅនៃមនុស្សសត្វ ដែលបានទទួលទោសធ្ងន់ ហើយក៏មកកើតជាបិសាច ស៊ីខ្ទុះឈាម សំរុយនៃសាកសពមនុស្សសត្វ ។

៤- តិរច្ឆាន .— បានដល់ពួកសត្វទាំងឡាយ ដែលគ្មានធម្មសញ្ញា ដូចឆ្កែ, គោ, ក្របី ជាដើម ។

ភាពដែលជាទិញ្ញាណនេះ មានការទាក់ទងទៅនឹងត្រៃភព ។ ពួកនរក ប្រេត តិរច្ឆាន អសុរកាយ ឬ ទេវៈ ក៏មានលំនៅស្ថាន មានកំណើតនៅក្នុងមនុស្សលោកនេះ ក៏មានគ្រាន់តែបរិសុទ្ធ

ដោយធាតុផ្សំគ្នា ។

## ២_ ភាវវិធី .–

គឺជាវិធី, របៀបដែលពន្យល់ពីភាវៈ ពីកំណើតនៃភាវៈដែលកើតឡើង ។ ភាវៈកើតឡើង ដោយព្រហ្មន ដែលជាឯកធាតុដ៏បំផុត ជាសាកលវិញ្ញាណ ហើយដែលនាំឲ្យមានអាត្មនជាព្រលឹងតូចៗ ចំពោះព្រហ្មន និងអាត្មននេះ មានកម៌មួយទៀត ដែលសម្រាប់នាំមនុស្សសត្វឲ្យកើតក្នុងសង្សារវដ្ត ។

ព្រហ្មននេះ មានលក្ខណៈជាអាទិទេព ដែលមានឥទ្ធិពលទៅលើគ្រប់ធម្មជាតិ ហើយ បង្កើតធម្មជាតិ : មនុស្ស, សត្វ, រុក្ខជាតិ ។

អាត្មនជាភាវៈ ជាចិត្តវិញ្ញាណ ដែលជាតត្តនរចិត្ត (ចិត្តខាងក្នុង) ស្ថិតនៅក្រោមឥទ្ធានុភាព នៃព្រហ្មន ។ អាត្មននេះ ពុំចេះស្លាប់បាត់បង់ទៅណាឡើយ ។

ឯកម៌ន ជាពូជ, ជាធាតុ ដែលនាំធម្មជាតិ មនុស្សសត្វ ឲ្យទៅកើត, ឲ្យយកបដិសន្ធិ ក្នុងភពណាមួយ : ទេវលោក, មនុស្សលោក ឬ បាតាលនេះឯង ។

ភាវៈទាំង៣ កាលណាជួបប្រទះគ្នានឹងបង្កើតជាភាវៈមួយឡើង ។ នេះជាវិធីបង្កើតភាវៈ ។

## ៣– ភាវទាន .–

គឺជាទស្សនៈទ្រឹស្តីមួយដែលពន្យល់ពីការបង្កើតភាវៈ ដែលជាឯកភាវនិយម ឬ ជាមូលធាតុ ដែលចាត់ទុកព្រហ្មនជាឯកធាតុ ឬ ជាប្រភពនៃការបង្កើតលោក ។ ព្រហ្មននេះ ស្ថិតនៅនឹងទេវៈ ឈ្មោះបុរុសៈ (Purusa) ជាអ្នកបង្កើតលោក ដោយការបំបែកព្រលឹងវិញ្ញាណមួយភាគមកក្រោម ដើម្បីបង្កើតធម្មជាតិ ដែលជាទឹក ដី ភ្លើង ខ្យល់ នេះឯង ។

## យោបល់រួមចំពោះភាវៈ:

ភាវៈជាពហុធាតុ ដែលកើតឡើងដោយការផ្សំគ្នានៃ ទឹក ដី ភ្លើង ខ្យល់ នេះឯង ប៉ុន្តែ គន្លាក់ គឺមានទេវៈដែលជាព្រហ្មន ជាអ្នកផ្តល់កំណើត, មានឥទ្ធានុភាពលើធម្មជាតិគ្រប់យ៉ាង ទោះសេចក្តីថា លោកកើតដោយសារអាទិទេព-ព្រហ្មន ដែលជាធាតុដើមដំបូងរស់ ។

ការយល់ពីបញ្ហាភាវៈនេះ នាំឲ្យមានប្រយោជន៍ដល់ការកែទិដ្ឋិយល់ខុសបញ្ហាសុខៈតទៅ ។

## បញ្ហាសុខៈក្នុងវេទនិយម

សុខៈជាបញ្ហាមួយធំទៀត ដែលទាក់ទងទៅនឹង សុខ ទុក្ខ វិជ្ជា ជាដើម ហើយ ដែលលទ្ធិសាសនាណាក៏ដោយ តែងតែស្វែងរកនិងដោះស្រាយជានិច្ច ។ បញ្ហាសុខៈនេះ ចែកជា ៣ ផ្នែកគឺ :

១- សុខប្រភេទ

២- សុខវិធី

៣- សុខរាង

**១- សុខប្រភេទ .–** គឺជាផ្នែកនៃសេចក្ដីសុខ ។ គេចែកសុខប្រភេទនេះ ជា ២ យ៉ាងគឺ : សាមញ្ញសុខនិងបរមសុខ ។

ក- សាមញ្ញសុខៈ ឬសុខធម្មតា .– ជាសុខដែលមាននៅក្នុងលោកិយ ប្រកប ដោយការត្រេកត្រអាល ពុំបរិសុទ្ធ ដោយហេតុថា នៅទាក់ទងនឹងវត្ថុ ព្រោះការវិលរស់កើត ស្លាប់ ដោយសារតណ្ហា ដែលជាកម្មជាបច្ច័យ ។ សុខបែបនេះ ពុំទាន់គ្រប់គ្រាន់ នៅឡើយ ទាល់តែបានបរមសុខថែមទៀត ។

ខ- បរមសុខ .– ជាសុខក្នុងបរលោក គ្មានទុក្ខណាមួយឡើយនៅពេលដែលតណ្ហា ដាច់ចេញពីព្រលឹង ទៅកើតជារូប ហើយរលាយត្រឡប់ទៅរួមនឹងការដើមវិញ ។

ប៉ុន្តែសុខនិងទុក្ខនេះ តែងទាក់ទងទៅនឹងវិជ្ជា និង អវិជ្ជានេះថែមទៀត ។

យ៉ាងណាមិញ វិជ្ជាជាធាតុដែលប្រាសចាកកម្ម ហើយអាចនាំឲ្យតណ្ហា ទៅរួមនឹង ព្រហ្មវិញ ដែលជាមូលហេតុនាំឲ្យបានបរមសុខៈ ឯអវិជ្ជា ជាធាតុដែលប្រកបដោយកម្ម ហើយនាំឲ្យតណ្ហាពុំត្រឡប់ទៅជួបនឹងព្រហ្មនេះឡើយ តែនៅវិលរស់កើតស្លាប់ក្នុងសង្សារនេះ ។ មូលហេតុនេះបណ្ដាលមកពី : កម្ម, សំសារ និងអវិជ្ជា ។

**២- សុខវិធី .–** គឺជាវិធីដែលនាំឲ្យបានសុខ ។ គេចែកសុខវិធីនេះជា ២ ផ្នែកទៀតគឺ វិធីបង្កើតសុខធម្មតា ឬសាមញ្ញសុខ និងវិធីបង្កើតបរមសុខ ។

ក–វិធីបង្កើតសុខធម្មតា.– ដើម្បីនឹងបានសុខធម្មតា ជាសុខក្នុងលោកិយ គេត្រូវ :

– ប្រកាន់វណ្ណៈ ដោយការបែកពួកមនុស្សតាមវណ្ណៈទាំង ៤

– គោរពព្រាហ្មណ៍

– គោរពវេទ

– ធ្វើពិធីបូជាយញ្ញ

– មានភក្តិ ( ជំនឿ La foi )

– បំពេញតបៈនិងរៀនវេទ ។

ខ–វិធីបង្កើតបរមសុខ.– ចំណែកខាងវិធីបង្កើតបរមសុខវិញ គេត្រូវ :

– ធ្វើមោក្សៈ (Délivrance) ដែលជាវិធីធ្វើឲ្យអាត្មនទៅជួបនឹងព្រហ្មន៍ ដែលជាមេ ឬជាធាតុដើមវិញ ។ ការលែងស្លាប់កើតវិលវល់ក្នុងសង្សារ ដោយអស់កម្មនៃបាបនេះ នាំឲ្យមានបរមសុខនេះឯង ។

– មិនតែប៉ុណ្ណោះ គេត្រូវបួសជាតាបសផង បំពេញតបៈ និងយោគៈ ។

តប .– ការដុតកំដៅផ្លូវកាយ ។

យោគ .– ការហាត់ពត់ អប់រំចិត្ត ។

វិធីបែបបទទាំងនេះ ក៏នៅពុំទាន់គ្រប់គ្រាន់នៅឡើយ ដូច្នេះត្រូវប្រើវិធីស្វែងរកសុខ ១ បែបថែមទៀត គឺការបង្កើតវិជ្ជា ឬ បំបាត់អវិជ្ជា ។

យើងឃើញហើយ បញ្ហាសុខទុក្ខ តាមទស្សនវេទនិយមទាក់ទងទៅនឹងវិជ្ជានិងអវិជ្ជា ។ ដើម្បីរកបរមសុខ ឬ ឯកត្តសុខ ជាសុខមិនប្រែប្រួលមកកាន់ទុក្ខវិញ គេត្រូវបំបាត់អវិជ្ជា ហើយបង្កើតវិជ្ជា ដែលជាចំណេះចេះដឹងដ៏ច្បាស់លាស់ឡើង ។ ការចេះដឹងដោយពិតថា ការជួបអាត្មនឹងព្រហ្មន៍ទៅជាឯកភាព គឺជាបរមសុខនេះឯង ឈ្មោះថាមានវិជ្ជា ។

ដូច្នេះ សុខវិធីដែលជាទស្សនៈនាំឲ្យមានសុខដែលជាបរមសុខនេះ គឺវិធីដែលពន្យល់ថា

ការផ្តាច់អាត្មន់ចេញពីរូបកាយទៅរួបរួមជាមួយនឹងព្រហ្មន៍ ជាឯកភាពនេះឯង ។

## ៣- សុខខាង .–

គ្មានអ្វីក្រៅពីវដ្តនៃការវិវត្តឡើយ ។ ក្នុងលទ្ធិវេទនិយម ការបានសុខមកពី ផលនៃមេសុខភាព ព្រោះជាការនាំវិវត្តសល់ឲ្យតាំងរស់ ហើយដើម្បីនឹងបានទទួលសុខណាមួយ នេះ គេត្រូវតែ :

– ធ្វើតាមគម្ពីរវេទ

– គោរពតាមគម្ពីរវេទ

– អនុវត្តតាមគម្ពីរវេទ

– មានភក្តីចំពោះគម្ពីរវេទ ។

កាលមនុស្សធ្វើយ៉ាងនេះ ដោយត្រឹមត្រូវតាមទស្សនៈទ្រឹស្តីនៃវេទនិយម ហើយការវិវត្ត ដែលជាទៅនៃខាងឯងនឹងផ្តល់សេចក្តីសុខ (សុខជម្ពូ ឬ ឋានសួគ៌តាមកម្ម) ឲ្យដល់អ្នកគោរពប្រតិបត្តិ ។

## យោបល់រួមចំពោះបញ្ហាវេទនិយម.–

រួបកាយនេះ យើងបានឃើញថា វេទនិយមស្ថិតនៅលើគន្លងដែលជាទ្រឹស្តីសំខាន់ៗ ដូចតទៅ :

– ជាអស្តិត្តនិយម ដែលគ្មានសភាពប្លុកលក្ខណៈជាប្រត្យក្សភាពសោះឡើយ ។

– ជាទេវនិយម ពានវែកជាពីរគឺ ឯកទេវនិយម (Monothéisme) ដែលគោរពតែព្រះមួយ និងពហុទេវនិយម (Polynothéisme) ដែលគោរពព្រះច្រើនអង្គ ដែលគេស្រុះគាត់គោលគ្នា ។

– ជាឯកភាពនិយម ដែលគេឲ្យតម្លៃទៅកាន់ភាពវិញ្ញាណទាំងអស់ : មនុស្ស, សត្វ, នោះ បានកើតពីព្រហ្មន៍ ហើយកាលណាអាត្មន់ត្រឡប់ទៅរួមព្រហ្មន៍វិញ នឹងបានសុខ ។

– ហើយមិនតែប៉ុណ្ណោះ លទ្ធិវេទនិយមបានឲ្យតម្លៃទៅលើចិត្ត, ព្រលឹងដែលជាអាត្មន់

នេះផង ទៅលើកាមវិតក្កផង ព្រោះចិត្ត (អាត្មន) ដែលអាស្រ័យនឹងរូបកាយមិនបរិសុទ្ធ គឺជាសារគមិន ហើយមានតែកាមវិតក្កមួយគត់ ដែលបានឲ្យនូវទ្រព្យគ្រប់យ៉ាង (កំណើត, វិជ្ជា, បរិសុទ្ធ, សុខទុក្ខ ។ល។) ដល់មនុស្សសត្វ ។

ដូច្នេះវេទនិយម មានលក្ខណៈជាលទ្ធិមួយ ដែលបង្គំដឹកនាំមនុស្សឲ្យបានដល់នូវសុខគ្រប់យ៉ាង ជាពិសេសនិព្វានសុខនេះឯង ។ បញ្ញាវុឌ្ឍិ, កាមៈ, សុខៈ ក្នុងវេទនិយម គឺជាអំណោយនៃកាមវិតក្កទាំងអស់ ។

× × ×

## បញ្ហាព្រាហ្មណ៍និយម

ការបរិបូរណ៍ផ្ទាល់ខ្លួននៃកាមវិតក្កនេះ និងភាពធុញទ្រាន់ចំពោះវណ្ណៈខ្ពង់ខ្ពស់ ដែលមិនសមហេតុផល ហើយជាពិសេស ពួកលទ្ធិបានក្រោយបង្អស់លទ្ធិនិយមឯទៀតក្នុងសម័យនោះយ៉ាងខ្លាំង អំពីវេទនិយម បានចាប់ផ្តើមសាបសោយទៅបន្តិចម្តងៗ ហើយលទ្ធិព្រាហ្មណ៍ បានចាប់កំណើតកំណើតឡើងក្នុងសង្គមឥណ្ឌា ដើម្បីរលំចោលនូវលទ្ធិផ្សេងទៀត ជាពិសេសគឺចង់រលំនូវពុទ្ធលទ្ធិនេះឯង ។

សម័យព្រាហ្មណ៍និយម ចាប់ផ្តើមកំណើតឡើងប្រហែលពីពេល ៥៥០ ឆ្នាំមុនគ.ស ហើយមានលក្ខណៈលេចធ្លោ នៅរហូតដល់សតវត្សទី១០ និងដើមសតវត្សទី១១ នៃគ.ស ថែមទៀត ។ លទ្ធិព្រាហ្មណ៍និយមនេះ មានប្រភពដើមមកពីលទ្ធិវេទនិយម ហើយបានចាក់ឫសគល់យ៉ាងមាំទៅក្នុងវប្បធម៌ឥណ្ឌា សូម្បីពុទ្ធលទ្ធិបានកាច់បំបាក់យ៉ាងខ្លាំងដែរនោះ ក៏ព្រាហ្មណ៍លទ្ធិនេះ នៅតែតាំងខ្លួនដោយធំធេងដ៏រឹងប៉ឹងដដែល ។

## មូលហេតុនៃការបង្កើតព្រាហ្មណ៍លទ្ធិ.-

សម័យវេទនិយម, មិនមានវណ្ណៈក្តាន់ក្តាប់ ក្រោយ ឬ សាបសោះបំណាច់អស់ស្រឡះនៅឡើយ ប៉ុន្តែពួកព្រាហ្មណ៍ ដែលមានវណ្ណៈខ្ពស់ឃើញថាយ ក៏បង្កើតលទ្ធិនេះឡើង ដោយៈ

- ក្រែងលទ្ធិវេទនិយម មិនអាចទប់ទល់តទល់នឹងពុទ្ធលទ្ធិបាន ។

- ពុទ្ធលទ្ធិ បានជះឥទ្ធិពលទៅលើលទ្ធិឯទៀតៗ ទាំងណាស់ទៅហើយ ឯពួកព្រាហ្មណ៍ ដែលពុំមានទស្សនៈស្របទៅនឹងពុទ្ធលទ្ធិ ព្រោះលទ្ធិខ្លួនជាវណ្ណៈទី១ ហើយភ្ជាប់គោរពតាមវេទនិយម ក៏បង្កការការពារផលប្រយោជន៍វណ្ណៈខ្លួនផង, បង្កើតឲ្យវត្តីស្វីផ្សេងៗ មានប្រសិទ្ធិភាពផង ក៏ទំនើបប្រែខ្លួនឡើង ។ ( ពុទ្ធលទ្ធិ បានវាយបំបាក់នូវពួកព្រាហ្មណ៍ និងក្សត្រយ៉ាងខ្លាំង ឥតឲ្យមានវណ្ណៈឡើយ មនុស្សត្រូវគោរពគ្នា តាមសមភាព . ទី ) . ។

សម័យព្រាហ្មណ៍និយម មានដំណើរឡើង ដើម្បីកែប្រែសេចក្ដីលទ្ធិចាស់ (វេទនិយម) របស់ខ្លួនផង និងដើម្បីទប់ទល់នឹងពុទ្ធលទ្ធិផង ។

## ចំណែកនៃជ័យរបស់ពួកព្រាហ្មណ៍.-

ដើម្បីនឹងធ្វើឲ្យជំនឿលទ្ធិព្រាហ្មណ៍ឲ្យមានប្រសិទ្ធិភាព ពួកព្រាហ្មណ៍បានបង្កើតការអប់រំគ្រួសារដោយវិធី ៤ យ៉ាង ក្នុងជីវភាពរបស់គេគឺ :

ក- ព្រហ្មចារ្យ.- ក្នុងកុមារវ័យ កូនព្រាហ្មណ៍ត្រូវរៀនសូត្រគម្ពីរវេទជាមួយគ្រូព្រាហ្មណ៍ ។

ខ- គ្រិហស្ថ.- ក្នុងយុវវ័យ ត្រូវមានគ្រួសារបន្តពូជពង្ស ។

គ- វានប្រស្ថ.- គមន (បព្វជ្ជា) ត្រូវទៅនៅព្រៃ រៀនរកអ្នកបួស ដែលបានចាកគ្រួសារទៅនៅមុនបាន ។

ឃ- សន្យាសៈ.- នៅទីបំផុត ពួកព្រាហ្មណ៍ ត្រូវប្រព្រឹត្តស្មឹងស្មាធិ៍ឲ្យស្ងប់ស្ងាត់ លែងគិតដល់សម្បត្តិលោកិយទាំងអស់ ។

## លទ្ធិសំខាន់ៗក្នុងព្រាហ្មណ៍និយម.-

ដើម្បីឲ្យលទ្ធិព្រាហ្មណ៍និយម មានកម្លាំងទប់ទល់បានជាមួយពុទ្ធលទ្ធិ ផងនិងទាំងក្នុងសម័យនោះ ពួកព្រាហ្មណ៍បានបង្កើតលទ្ធិ ៣ ទៀតគឺ :

១– លទ្ធិព្រហ្មចារ្យ

២– លទ្ធិអាគ្ន័ន

៣– លទ្ធិឧបនិស័ទ

១– លទ្ធិព្រហ្មចារ្យ .– ជាលទ្ធិមួយដែលពួកព្រាហ្មណ៍បានបង្កើតឡើង សម្រាប់ឲ្យពួកព្រាហ្មណ៍សំគិតសំគាំងចិត្ត ចេញចាកកាមទៅបួសជាសមណព្រាហ្មណ៍ រស់នៅក្នុងទីស្ងប់ស្ងាត់ ។

២– លទ្ធិអាគ្ន័ន .– ជាលទ្ធិដែលពួកព្រាហ្មណ៍អប់រំខ្លួនក្នុងគ្រួសារ ដែលជាព្រាហ្មណ៍ឲ្យសំគិតសំគាំងភក្តីឲ្យស្អាតបរិសុទ្ធ ដោយគ្រឿងសេព្ហា ដែលចៅចាកមិន ដើម្បីទៅជួបនឹងព្រហ្ម សម្រេចបរមសុខវិញ ។

៣– លទ្ធិឧបនិស័ទ .– ជាលទ្ធិដែលគេអប់រំកាយ វាចាចិត្ត ដោយវិធីធ្វើយោគៈ ព្រោះកាយពោរពេញទៅដោយកិលេសតណ្ហា ហើយចិត្តដែលជាធម្មជាតិរវើរវាយ មិនឈប់ឈរ កាលណាគេអប់រំធ្វើឲ្យលំបាកនិងមានការតឹងតែងចំពោះតណ្ហាខ្លះ ហើយចិត្តនឹងបរិសុទ្ធស្អាតឡើង ។

គោលលទ្ធិទាំង ៣ ស្ថិតនៅក្នុងគោលបំណងដូច គឺធ្វើលទ្ធិព្រាហ្មណ៍ឲ្យល្អស្អាត ចេញខ្លួនធ្វើប្រតិបត្តិលទ្ធិខ្លួនឲ្យតែល្អស្អាតឡើងជានិច្ច ។

សេចក្តីសង្កេត.– ប៉ុន្តែការប្រើលទ្ធិព្រាហ្មណ៍ បានមកដល់សម័យបច្ចុប្បន្ន ដែលមានគេដោយ កិលេសវិនាសទៅតែឲ្យតម្លៃទៅលើការពិធី ឲ្យតម្លៃទៅលើព្រហ្មជាដែល ដែលជាការគោរពថ្វាយតម្លៃលទ្ធិវេទនិយមសាសនាឡើយ ។ មិនតែប៉ុណ្ណោះ លទ្ធិព្រាហ្មណ៍និយម ក៏បាន ផ្តើមយកបញ្ហា ៣ យ៉ាងគឺ : តួរ៉ូ, ការៈនិងសុខ ជាការចាប់ផ្តើមការស្រាវជ្រាវ ។

## បញ្ហាពុទ្ធិក្នុងព្រាហ្មណ៍និយម.

១– ពុទ្ធិបត្ត.– គឺ គ្រឿងប្រកាច់សម្រាប់បង្កើតក្នុងពិធីក្នុងវេទនិយម ដែល គឺមាន :

ក- ឫគ្វេទ (ឫគវេទ)

ខ- សាមវេទ

គ- យជុរវេទ

ឃ- អថវ៌វេទ

ផ្សេងពីគម្ពីរវេទ, ដើម្បីបានលទ្ធិមួយទៀត ពួកព្រាហ្មណ៍បានរៀបចំអត្ថបទវិញ្ញាសំខាន់ៗ សំរាប់ប្រើជាឧបករណ៍នៃការបង្កើតពុទ្ធិដែរគឺ :

ក- រាមាយណៈ .- រឿងរ៉ាវនៃព្រះវិស្ណុ (ការចាប់កំណើតនៃព្រះនារាយណ៍ មកជាព្រះរាម) ជារឿងចម្បាំងរវាងសេចក្តីល្អ និងអាក្រក់ ជាអត្ថបទអក្សរសិល្ប៍និងសាសនា ។

ខ- មហាភារតយុទ្ធ .- រឿងចម្បាំងរវាងក្រួសៈ និង បាណ្ឌវ ដែលជា ជំលួយក្នុងរឿងកេរ្តិ៍សម្បត្តិ ហើយជារឿងវែងឆ្ងាយនៃព្រះវិស្ណុ (នារាយណ៍) ដែរ ។

គ- បុរាណ .- ជាគម្ពីរមួយ ដែលនិយាយពីប្រវត្តិសាស្ត្រលោក (ទឹកដី) ។

ឃ- ធម្មសាស្ត្រ .- ជាគម្ពីរច្បាប់ទូទៅ គ្រប់គ្រងប្រទេស, សង្គមមនុស្ស ។

ង- តន្ត្រៈ .- ជាគម្ពីរមេលេស, ទ្រឹស្តីសម្រាប់ដាច់ឡូវខ្លួនឯងផ្សេងៗ ។

គ្រឿងប្រដាប់សម្រាប់បង្កើតពុទ្ធិនៅក្នុងទស្សនៈព្រាហ្មណ៍ ប្រែទៅតាមសំនៀងសាសនា និងអក្សរសិល្ប៍ ។

២- ពុទ្ធិវិធី .- របៀបបែបផែន ដែលនាំឲ្យមានពុទ្ធិ ពួកព្រាហ្មណ៍តែងផ្អែកទស្សនៈទៅលើប្រភព ៣ យ៉ាងសំខាន់ :

ក- ស្រុតិ (Sruti) .- ជាចំណេះ បានមកដោយអំណាចនៃការទិវេត (Révélation) ។

ខ- ស្មិតិ (Smrti=Tradition sacrée).- ជាចំណេះដោយការចងចាំ (ចាំមាត់) ដោយមានពួកព្រាហ្មណ៍ជាអ្នកបង្រៀនតាមតែអត្ថបទគម្ពីរ និង គោលគំនិតដើម ។

គ- អន្វិក្សិកិ (Anviksiki=Investigation rationnelle) .- ជាចំណេះ

ទេវជីវ ដែលមនុស្សស្រាវជ្រាវ ពិចារណាគេឃើញ ស្រប ឬ ផ្ទុយនឹងគម្ពីរវេទ អត្ថជាតិ, ធម្មចិន្តា, ដោយឲ្យតម្លៃទៅលើទ្រឹស្តីនេះ មិនឲ្យតម្លៃទៅលើទ្រឹស្តី ឬ ទស្សនៈនោះ ។

ផ្ទៃពីនេះ ពុទ្ធវិធីសង្កត់ទៅលើ :

- ធ្វើពិធីបូជាយញ្ញ :
- សូត្រស្មូត្រ ចំពោះអាទិទេព (សរសើរ)
- បន់ស្រន់, បួងសួងចំពោះអាទិទេព
- អង្វរករចំពោះអាទិទេព ។

៣- ពុទ្ធិវាទ .— ចំណេះទេវជីវ ជាពិសេសទស្សនៈទ្រឹស្តី ៦ យ៉ាង ដែលហៅថា គម្ពីរទសាស្ត្រ :

ក- មិមំសា .— ការពិចារណាតន្ត្រៀបចំពោះធម៌វិន័យ, មន្តអាគម, វេទមន្ត លើពិធីបូជាយញ្ញចំពោះអាទិទេព ។ ទស្សនៈនេះ មានការគួរសក់តែបញ្ជាក់ចំពោះទ្រឹស្តី សម្រាប់អ្នកកាន់លទ្ធិឲ្យច្បាស់លាស់ ។ អ្នកបង្កើតទស្សនៈឈ្មោះ ជៃមិនិ នៅទី១ និងទី២ មុន គ.ស ។

ខ- វេទន្ត .— ទស្សនៈដែលពន្យល់តាមឫសគល់ដើមនៃគម្ពីរវេទ ជាឯកធាតុនិយម ឬ អទ្វៃតៈ ។ វេទន្ត មានន័យថា ទីដំបូត ឬ ចុងនៃវេទ អ្នកបង្កើតឈ្មោះ ពាទ្រាយណៈ មានចំណាស់ជាងលក្ខខ័ណ្ឌទស្សនៈ មិមំសា ឬ ក្រោយនេះបន្តិចប៉ុណ្ណោះ ។ ទស្សនៈនេះនិយមថា មានអាទិទេពធំ គឺព្រហ្មន ដូចក្នុងគម្ពីរឧបនិស្ស័ទ ហើយការសម្រេចបរមសុខទស្សនៈវេទន្ត បានពន្យល់ថា ត្រូវតែអាត្មនវិលទៅជួបព្រហ្មនជាដាច់ខាត ។

គ- សំខ្យា .— ជាទស្សនៈដែលពន្យល់ពីការកើតកាន រាប់ចំនួនធាតុដែលផ្តុំឡើងបង្កើតលោកប្រកបដោយធាតុ៤ :

- គុណ .— ធាតុល្អ អាក្រក់ នៃធម្មជាតិ
- សត្វ .— ធាតុរូបនៃធម្មជាតិ
- តមៈ .— ធាតុទំនាស់នឹងធម្មជាតិ

– ពាជំ: .– ជាគុរ៉ែលជាកម្លាំងសម្រាប់ការរំដោះ ធ្វើឲ្យរួចផុតពីទុក្ខ ព្រោះ ចាក់ចេញ ។ ទស្សនៈនេះ កើតប្រហែលក្នុងសតវត្សទី៦ ឬ ៧ នៃគ.ស អ្នកបង្កើត ឈ្មោះ កបិលៈ ។

ឃ– យោគ .– ជាទស្សនៈសម្រាប់ពន្យល់ពីការបញ្ចេញ ឲ្យប្រាសចាកពាក សៅហ្មង ។ បង្កើតនៅសតវត្សទី២ នៃ គ.ស ដោយលោក ឫសៈ មិនឹកឈ្មោះជា លោក បតញ្ជលី ។

ង– វៃសេសិក .– ជាទស្សនៈបញ្ជាក់ពីភាពផ្សេងនៃធម្មជាតិ ដែលលោក គណាទ បានពន្យល់ពីបរមាណុធាតុ ដោយបញ្ជាក់ថា ធម្មជាតិសុទ្ធតែកើតមកពីការរៀបចំ... គុណធម៌ ដូចជានៅក្នុងវិទ្យាសាស្ត្រ ចែកជា ៦ យ៉ាង គឺដូចតទៅនេះ :

១– ទ្រព្យៈ (Substance) .– គឺជាគុណធម្មដំបូងបំផុត សម្រាប់បង្កើតជាតិ ។

២– គុណៈ (Propri[été]).— គុណភាពនៃធម្មជាតិ ។

៣– កម្មៈ (Activité) .– សកម្ម, ចលនានៃធម្មជាតិ : មនុស្ស, សត្វ ដែលជាទ្រព្យ ១ ឲ្យទៅប្រើទ្រព្យ ១ ទៀត ។

៤– សាមញ្ញ (Généralité) .– ភាពទូទៅ ដែលនាំឲ្យធម្មជាតិជួបគ្នាដូចគ្នា, បង្កើតតភាព ។

៥– វិសេស (Corps composé) .– ជំនួបនៃទ្រព្យនិងទ្រព្យ ដោយសារកម្ម ។

៦– សមវាយៈ (Corps inhérent) .– ដំណើរជួបគ្នានៃទ្រព្យនិងទ្រព្យ ហើយលាយចូលជារូបធាតុផ្សេង ។

– ទស្សនៈវៃសេសិក គឺឲ្យតម្លៃទៅលើទេវនិយមផងដែរ ។

ច– ន្យាយៈ .– ជាទស្សនៈរបស់លោក គោតមៈ ដែលបានពន្យល់ ... ឲ្យតម្លៃទៅលើការផ្សំផ្គុំនៃធាតុ ទឹក, ដី, ភ្លើង, ខ្យល់ បង្កើតជាលោកនេះ ។ ទស្សនៈនេះ បានចំណាស់ស្របគ្នានឹងក្នុងសម័យដែរ (៥៤៣ មុន គ.ស) ហើយ...

ដែលរិះគន់ម្ដងទៀតលើលទ្ធិនិយមដដែល ។

ក្នុងលទ្ធិព្រាហ្មណ៍ តាំងពីមានការបែកបញ្ញលទ្ធិវេទនិយមកំរោយ កំពុងចិត្តក្នុងផ្នែកខ្លះ នៅតែជាប់ទាក់ទងទៅលើជំនឿក្នុងគម្ពីរវេទដដែល ហើយតែងតែឲ្យតម្លៃ និងគោរពចំពោះវណ្ណៈព្រាហ្មណ៍ ដែលជាវណ្ណៈទី ១ ក្នុងសង្គមឥណ្ឌា នៅសម័យនោះជានិច្ច ។

## បញ្ហាគោលៈក្នុងព្រាហ្មណ៍និយម

**១– គោលនិម្មាណ .–** ការនៅក្នុងលទ្ធិព្រាហ្មណ៍ បានបញ្ជាក់តាមគម្ពីរព្រហ្មបុរាណ៍ថា អ្វីៗទាំងអស់ជាធម្មជាតិ : មនុស្ស, សត្វ, រុក្ខជាតិ, ទឹក, ដី, ភ្លើង, ខ្យល់, អាកាស កើតពីព្រហ្មទាំងអស់ ។

**២– គោលវិធី .–** លោកៈ ពុំមែនតែពីក្រើសក្នុងវេទនិយមឡើយ ពោលគឺមានលោក ៣ :

**ក– ទេវលោក .–** ជាស្ថានសួគ៌នៅជាន់លើមនុស្សលោក ។ ក្នុងទេវលោក ពួកព្រាហ្មណ៍បានគោរពនិងឲ្យតម្លៃទៅលើអាទិទេពធំៗ ៣ [illegible] គឺ :

**១– ព្រះព្រហ្ម .–** (ព្រហ្មនិយម) ព្រហ្មបានឡើងជាអាទិទេពធំនៅសម័យព្រាហ្មណ៍និយម ដូចព្រះឥន្ទក្នុងសម័យវេទនិយមដែរ ។ ព្រះព្រហ្មមាននាទីជាអ្នកបង្កើតលោក ។

– នៅក្នុងសិល្បៈខ្មែរ ព្រះព្រហ្មមានព្រះភក្ត្រ ៤ ព្រះហស្ថ ៤ ជិះហង្សជាយាន, មានជាសដូចប៉ុនតែ ១ ជាសមួល ១ ស្លាបព្រា ១ និងខ្សែផ្កា ( Rosaire ) និងជួនកាលជាគម្ពីរ មានមហេសីឈ្មោះនាងសរស្វតី ។

គេថាៈពេលវេលានៅស្ថានព្រហ្មមានរយៈវែងណាស់ មួយថ្ងៃនៅស្ថានព្រហ្មស្មើនឹងមួយកល្បនៅស្ថានមនុស្ស ពេលព្រះព្រហ្មភ្ញាក់គឺជាពេលកើតនៃកល្ប ពេលព្រះព្រហ្មដេក ជាកាលដែលផែនដីតកើតឡើងវិញ ។ កុំច្រឡំរូបព្រះភក្ត្រ ៤ នៅប្រាសាទបាយ័ន ថាជាព្រះព្រហ្ម គឺជារូបព្រះពោធិសត្វ អវលោកិតេស្វរៈ ។

**២– ព្រះវិស្ណុ (ព្រះនារាយណ៍) .–** ពេលដែលផែនដីកើតហើយ ព្រះវិស្ណុមាន

ទាំងជាអ្នកថែរក្សាការពារ-រៀបចំលោក ។

-ព្រះវិស្ណុកសិល្បៈខ្មែរ ជារូបមនុស្សមានក្បាលមួយ ដៃ ៤ កាន់ចាស ១ ស័ង្ខ ១ គោនទ ១ ដីដុំមូល ១ ពាក់មួកមូល (Mitre cylindrique) ជិះគ្រុឌជាយានជំនិះ ជួនកាលជារូបឈរ ឬផ្ទំនៅកណ្ដាលសមុទ្រ លើនាគមួយឈ្មោះ អនន្ត ។ នៅត្រង់ផ្ចិតមានផ្កាឈូកដុះចេញមក ហើយព្រះព្រហ្មគង់លើផ្កាឈូក ។ ព្រះវិស្ណុមានប្រពន្ធពីរឈ្មោះស្រី និង លក្ស្មី មានបុត្រម្នាក់ឈ្មោះកាមៈ ។ ស្រី ជាតំណាងភាពល្អស្រស់ (សោភណភាព), លក្ស្មី ជាតំណាងទ្រព្យសម្បត្តិ ។

ព្រះវិស្ណុមានឈ្មោះច្រើនគឺ នារាយណ៍, កេសវ, ហរិ, អនន្ត ហើយតែងចែងកាយជាមនុស្សសត្វផ្សេងៗ ដើម្បីជួយស្រោចស្រង់លោក ។ អវតាររបស់ព្រះវិស្ណុមាន ១០ យ៉ាងគឺ:

១– ត្រីមត្ស្យ (Matsya) .– ចែងកាយជាត្រី ដើម្បីជួយមនុស្សឲ្យរួចពីទឹកជំនន់ ដែលហយគ្រីវៈយក្សបណ្ដាលឡើង ។

២– អណ្ដើកឈ្មោះ កូម៌ (Korma) .– ធ្វើជាកំណល់ទល់ភ្នំមន្ទរៈ នៅពេលដែលអសុរនិងទេវតាចាប់កន្ទុយនាគវាសុកិទាញបង្វិលភ្នំ ដើម្បីកូរសមុទ្រទឹកដោះ ដើម្បីយកទឹកអម្រឹត និងវត្ថុសក្ដិសិទ្ធិ ១៣ មុខទៀតគឺៈ អ្នកបង្កើតឱសថ ធន្វន្តរិ, ទេពធីតាលក្ស្មី, ទឹកហោមសុរា, ព្រះចន្ទ, ទេពអប្សរឈ្មោះរម្ភា, សេះទេះឈ្មោះឧច្ចៃស្រវ៉ស, ពេជ្រកៅស្ទុភៈ, រុក្ខជាតិសួគ៌បារិជាត, គោញីសុរភី, ដំរីឰរាវតៈ, សង្ខ, ធ្នូ, ថ្នាំពុល ហាលាហលៈ ។

ក្បូរចនាខ្មែរ មាននៅទីងក្លោងទ្វារដើយចូលទៅនគរធំ និងនៅលើជញ្ជាំងប្រាសាទនគរវត្ត (ចម្លាក់លិប = Bas relief ) ។

៣– ជ្រូកព្រៃឈ្មោះ វរាហៈ ល្បីឈ្មោះដោយសម្លាប់ ហិរណ្យយក្ស ដែលចាប់នាង ភូមិទេវី នៅទុកនៅបាតសមុទ្រ ហើយមានច្រមុះវាលាលោកឲ្យទៅជាទឹកសមុទ្រ ។

៤– មនុស្សសិង្ហឈ្មោះ នរសិង្ហ .– មានក្បាលជាសិង្ហ: ខ្លួនជាមនុស្ស បានសម្លាប់យក្សឈ្មោះ ហិរណ្យកសិបុ ជាប្អូនយក្សឈ្មោះ ហិរណ្យាក្ស ។ យក្សហិរណ្យកសិបុ ដែលបានពរពីព្រះព្រហ្មថា កុំឲ្យស្លាប់ដោយមនុស្ស ឬ ទេវៈ ដែលបង់សម្លាប់ពេល

យប់ឬថ្ងៃ ហើយក៏ដើរកេងក្បាលទោះនិងមនុស្សតាមចិត្ត - នរសិង្ហបានសម្លាប់យក្សនេះ នៅពេលព្រលប់ ។

៥- មនុស្សតឿឈ្មោះ **វាមនៈ** .- ជាព្រាហ្មណ៍តឿជួយស្រោចស្រង់មនុស្សលោកពីកណ្ដាប់ដៃយក្សឈ្មោះ **ពលិ** ។ វាមនៈ បោកបញ្ឆោតយក្សសុំឈាន ៣ជំហាន ក៏ឈានផុតផែនដី ហើយយកដីឲ្យមនុស្សនៅ ។

៦- មនុស្សកាន់ពូថៅឈ្មោះ **បរសុរាម** .- ជាមនុស្សកាន់ពូថៅអំណោយសិវៈ ជួយស្រោចស្រង់មនុស្សឲ្យផុតពីអំណាចស្ដេចកាចឈ្មោះ **កាតិវិរ្យា** ដែលសង្កត់សង្កិនមនុស្សឯទៀតៗ ។

៧- **ព្រះរាម** .- ជាស្ដេចអាទិទេព ដែលមានមុខងារបង្ក្រាបពួកយក្សមានយក្សឈ្មោះ **រាពណ៍** ក្នុងរឿងរាមាយណៈ ដែលបៀតបៀនសាសនាព្រាហ្មណ៍ ។

៨- **ក្រិស្ណ** .- ជាមនុស្សខៀវខ្មៅ គោរពគោ ជាព្រះចាំងពួកគង្វាលគោឲ្យរួចពីផ្គរ, ភ្លៀង, រន្ទះ ហើយបានសម្លាប់ស្ដេចជាឪពុកមាឈ្មោះ **កំសៈ** ដែលចង់សម្លាប់ខ្លួន ដោយចោទថាជាក្បត់ ។ ក្រិស្ណៈ ជាតួឯកក្នុងរឿងមហាភារតយុទ្ធ ផ្ទុយពីនេះ គេស្រឡាញ់ច្រើន ។

៩- **ពុទ្ធ** .- ជាព្រះពុទ្ធសមណៈគោតម (តាមលទ្ធិព្រាហ្មណ៍) ។

១០- **កល្កិន** .- នឹងកើតមានខ្លួនជាមនុស្ស, ក្បាលជាសេះ (នឹងកើតនៅអនាគតកាល) ដើម្បីកាត់ទោសមនុស្សប្រព្រឹត្តអាក្រក់ និងរៀបចំយុគថ្មីឲ្យរុងរឿង ។

អវតារ គឺការចែកភាគនៃព្រះវិស្ណុនេះមាន ១០ យ៉ាង ហៅថា ទសាវតារ ។ ៩លើកមានរួចហើយ១ លើកទៀត នឹងមាននៅអនាគតកាល ។

៣- **សិវៈ** .-

សិវៈ ឬ ព្រះឥសូរ ជាអ្នកបង្កើតលោកផង បំផ្លាញលោកផង ជាអាទិទេពនៃជនជាតិឥណ្ឌាភាគខាងជើង និងពួកអារ្យ៉ានដែលកាចឃោរឃៅ ។

– រូបគង់សិល្បៈខ្មែរ គឺជារូបលិង្គស្ថិតលើផ្ទៃយោនី (ក្តិត) នៃនាងឧមា ពីដើមបែរទៅរវាង សតវត្សទី៦ ដល់ទី៨, ដល់ក្រោយមកជារូបមនុស្សក្បាល៥ ដៃ១០ ជាឥសូរក្សត្រ ។

– ជិះគោនន្ទិ ជាជំនិះ កាន់ត្រីសូល, ខ្សែធ្នូ, ស្គរ, ដប, ខ្សែមួយបក្សីយ, ធ្នូ, ខ្សែក ។

– មានឈ្មោះច្រើនគឺ: សិវៈ, ឥសូរ, មហាទេវ, ហរ, មហេស្វរៈ, រុទ្រ, សង្ករៈ, ស្រុទ, ភៃរវៈ ។

– មានមហេសី៩ គឺនាង ទុគ៌ា, ឧមា, គោរី, កាលី, ទេវី, កុមារី, ចណ្ឌី, បាវ៌តី, មហាទេវី ។

– មានកូន២ នាក់គឺ: ស្កន្ទៈ ជាទេពចំណាំងសង្គ្រាម និង គណេសៈ ជាទេពចំណេះវិជ្ជា ។ គណេសៈខ្លួនជាមនុស្ស ក្បាលជាដំរីមានសក្តិពេញខ្លួន មានភ្លុកតែមួយ ។

ចំណាំ.– នៅគង់សិល្បៈខ្មែរ ឃើញមានក្រុមសាងអណ្តែត រូបតែ១ ជាកំណាត់ វិស្ណុ និងសិវៈផង ហៅថា ហរិហរៈ គឺ ពាក់ចំហៀងក្បាលស្តាំសំគាល់សិវៈ (ឥសូរហរ) ចំហៀងឆ្វេងសំគាល់វិស្ណុ (នារាយណ៍ហរៈ) ។

ខ– មនុស្សលោក.– គម្ពីរវេទព្រាហ្មណ៍ បានចែកវណ្ណៈមនុស្សជា ៤ ពួក ដូចក្នុងវេទនិយមដែរ គឺ ព្រាហ្មណ៍, ក្សត្រ, វេស្សៈ និង សូទ្រៈ ។ ដោយឡែកមានពួក ចណ្ឌាល (កូនមនុស្សច្របល់យកកំណើតវណ្ណៈព្រាហ្មណ៍ និង សូទ្រៈឬ ក្សត្រនិងសូទ្រៈ) ។

គ– បាតាល.– (ដូចគ្នាក្នុងវេទនិយមដែរគឺ កន្លែងខាងក្រោមនៃភពផែនដីនេះទៅ ក្រោមដីឬ ក្រោមភ្នំព្រះសុមេរុ ហើយដោយឡែកមាន ប្រេត, អសុរកាយ, តិរច្ឆាន ថែមទៀត ។

ការពិត ក្នុងព្រាហ្មណ៍និយម គំនិតនៃត្រៃមូរតិលើកាទិទេព ហើយជាពិសេសគឺ ព្រហ្មញ្ញឯង ដោយមនុស្សនៃពួកព្រាហ្មណ៍នេះ បានគេស្គាល់ថា សកលៈគ្រប់យ៉ាង បានមានឡើង ក្នុងលោកនេះហើយៗ កាលពីដើម កកើតជាស៊ុតមួយ មានឋិតនិងជាព្រហ្ម ។ កាលអណ្តែតអស់ ១ម៉ឺនកប្បព្រហ្មក៏បំបែកស៊ុតជា២: មួយចំណែកលើជាមេឃ, អាកាស, ១ចំណែកក្រោមជាដី។ហើយ ព្រហ្មបានសាងសព្វសត្វទាំងនៅក្នុងលោក ទើបមានការគ្រប់យ៉ាងនេះឡើង ដែលជាវិធីបង្កើតលោក

ទាំង៣ មានឋានសួគ៌, ឋានមនុស្ស និងឋានបាតាលនេះឯង ។

### ៣_ គាបបាន.-

ទស្សនៈក្នុងព្រាហ្មណ៍និយម គឺនៅតែពុំទាន់ផុតចេញពីទេវនិយម ក្នុងផ្នែកការគោរពនេះដែរ ពោលគឺព្រាហ្មណ៍និយមឲ្យតម្លៃទៅលើពហុភាពនិយមទាំង ៣ ដែលមនុស្សត្រូវធ្វើការសែនស្ងាប់ ស្ដួកគ្រក់ នៅលើទេវតាទាំង ៣ គឺ ព្រះព្រហ្ម ព្រះវិស្ណុ និងសិវៈនេះឯង ។ ព្រោះទេវតាទាំង៣ ជាអ្នកបង្កើត - ព្យាបាល - រៀបចំ និងបំផ្លាញលោកសន្និកស ។ ដោយហេតុនេះ បានជាមានទស្សនៈមួយ ក្នុងសម័យព្រាហ្មណ៍នេះ ហៅថាទស្សនៈត្រៃមូរ្តិ គឺការនិយមលើកដម្កើងទេវតាទាំង ៣ អង្គ ដែលជាម្ចាស់នៃលោកទាំង៣ ។

## បញ្ហាសុខក្នុងព្រាហ្មណ៍និយម

បញ្ហាសុខៈនៅក្នុងព្រាហ្មណ៍និយម គឺនៅតែមាន២ ផ្នែកដដែល គឺសុខធម្មតា និងបរមសុខនេះឯង ប៉ុន្តែមុននឹងស្គាល់សុខ ត្រូវស្គាល់ទុក្ខសិន ។

**១- សុខប្រភេទ .-** សុខប្រភេទមាន ទុក្ខ - សុខ និងបរមសុខ ។

**ក- ទុក្ខ .-** ក្នុងទស្សនៈព្រាហ្មណ៍ ទុក្ខកើតឡើងដោយបុព្វហេតុ៤ យ៉ាង:

- ដោយសំសារ
- ដោយកម្ម
- ដោយអាត្មន ពុំស្អាត
- ដោយអវិជ្ជា (ល្ងិតល្ងង់)
- តណ្ហា (ចំណង់)

នៅក្នុងទស្សនៈទាំង៦ មានមីមាំសា, វេទន្ត ជាដើម សុទ្ធតែយល់ថា ទុក្ខកើតដោយហេតុទាំងនេះដែរ ។

ខ- សុខ.- (សាមញ្ញសុខៈ សុខធម្មតា) សុខផ្នែកនេះ មានការទាក់ទងទៅនឹងព្រះព្រហ្មជាអ្នកបង្កើតលោក ពោលគឺ ការស្គាល់អាត្មន ដែលមានទំនាក់ទំនងនឹងព្រហ្ម

នះឯង ។ ប៉ុន្តែសុខបែបនេះ កុំទាន់គ្រប់គ្រាន់ពេញលេញនៅឡើយ មានតែបរមសុខប៉ុណ្ណោះ ទើបជាសុខពេញលេញ ។

គ- បរមសុខ .- សុខដែលពួកព្រាហ្មណ៍មានប្រឹងប្រែងដោះស្រាយ និង ស្វែងរក គឺបរមសុខ ជាបរិបុណ្ណសុខ ហើយជាសុខរបស់អាទិទេពថែមទៀត ។

២- សុខវិធី .- វិធីសម្រេចបរមសុខមាន ២ យ៉ាង :

ក- មោក្ស .- ដើម្បីសម្រេច សុខ គេត្រូវបំបាត់អវិជ្ជា. សំសារ, កម្ម, តណ្ហា នេះឯង ។ មិនតែប៉ុណ្ណោះ គេត្រូវ :

- សិក្សាគម្ពីរវេទ ឲ្យចាំមាត់
- ធ្វើពិធីបូជាយញ្ញ
- អធិរ - សរសើរអាទិទេព
- រៀនមន្តអាគមគាថា
- ប្រព្រឹត្តតាមកិច្ចរបស់ព្រាហ្មណ៍ -
- បួសជាតាបសឥសី ចំរើនឈាន
- បង្កើតវិជ្ជា ដែលនាំឲ្យយល់ច្បាស់ថា ខ្លួនជាព្រហ្ម ។

ខ- ភក្តិ .- ប៉ុន្តែធ្វើតែប៉ុណ្ណោះ ក៏នៅពុំទាន់គ្រប់គ្រាន់ទៀត ដូច្នេះគេត្រូវ មានជំនឿយ៉ាងស៊ប់ទៅលើអាទិទេពតែមួយអង្គ (ជំនឿដោយគ្មានពិចារណា) ដែលមានលក្ខណៈសំខាន់ៗ គឺ:

- ជំនឿស៊ប់ស្ងួន
- ស្នេហាផ្ដិតផ្គួល
- គោរពកោតខ្លាច
- នឹកដល់អាទិទេព ។

មោក្សៈ និង ភក្តិនេះ ទុកជាកត្តាយ៉ាងសំខាន់ ដែលនាំឲ្យសម្រេចបរមសុខ ជាសុខ

គ្មានប្រែប្រួល ។

៣-សុខវាទ .- ចំណែកខាងសុខវាទ ទាំងអស់ខាងលើនេះ ក៏ស្រេចនៅលើព្រាហ្មណ៍ ដែលបានសេចក្ដីថាបាន សុខ ឬ មិនបានសុខ ស្ថិតនៅលើព្រាហ្មណ៍ ដែលជាវណ្ណៈសំខាន់ មានសមត្ថភាពជួយអន្តរាគមន៍សួង សុំសុខពីអាទិទេពបាន ។

## យោបល់រួមចំពោះលទ្ធិព្រាហ្មណ៍និយម

ព្រាហ្មណ៍និយម ដែលបានកែប្រែបង្កើតចេញពីវេទនិយម ក៏នៅតែមានលក្ខណៈស្រប ស្រួលទៅនឹងវេទនិយមស្ទើរតែទាំងអស់ គឺជា ទេវនិយម បែបឯកទេវៈ និងពហុទេវៈ ហើយនឹង ព្រាហ្មណ៍និយម ដែលព្រាហ្មណ៍មានតួនាទីជាអ្នកនាំពាក្យនៃមនុស្សទៅអង្វរលួងលោម អាទិទេព ។ នៅក្នុងព្រាហ្មណ៍និយម (ក្រោយវេទនិយម) អាទិទេពសុទ្ធតែមានសមត្ថភាព, មានលក្ខណៈគ្រប់ល្អ គ្រប់យ៉ាង (ដូចពជនិយម ក្នុងអក្សរសិល្ប៍ខ្មែរដែរ) ។ ទស្សនៈនេះ មានជាប់ទាក់ទងទៅនឹង ហិណ្ឌូនិយម ថែមទៀត ។

x x x

## ហិណ្ឌូនិយម

### អត្ថន័យសង្ខេប .-

ហិណ្ឌូនិយម ពុំមែនជាលទ្ធិថ្មីមួយ ដោយឡែករបស់ពួកហិណ្ឌូឡើយ ហើយទស្សនៈ ទ្រឹស្ដី ក៏ពុំបានផ្ដាច់ខ្លួនចេញស្រឡះពីលទ្ធិមុនដែរ បានសេចក្ដីថាហិណ្ឌូនិយម គឺជាលទ្ធិដែល ល្បាយលទ្ធិវេទនិយម និង ព្រាហ្មណ៍និយមបញ្ចូលគ្នានោះឯង ។

ពាក្យហិណ្ឌូនិយម សំគាល់ន័យថា លទ្ធិដែលគេយកតាមវប្បធម៌ អរិយធម៌ហិណ្ឌូ ប៉ុន្តែមិនមែនជារបស់ហិណ្ឌូ (ឥណ្ឌា) ដោយសុទ្ធសាធឡើយ ។ ពួកជនជាតិឥណ្ឌា មានប្រវត្តិ សាស្ត្រចាស់ទុំ មានលទ្ធិច្រើន ហើយមានជនជាតិ និងភាសាច្រើន ឡើងហើយ លទ្ធិ, សាសនា,

ទស្សនៈអប់រំ តែងមានលក្ខណៈប្លែកៗ គ្នាបន្តិចៗ តាមការបដិវត្តន៍នៃកាលវេលា, សម័យ ។

នៅក្នុងហិណ្ឌូនិយម មានការដោះស្រាយ បញ្ហាពុទ្ធិ, កាម៉ៈ និងសុខស្របស្មើនៃភាព ស្រុះទៅនឹង វេទនិយមនិងព្រាហ្មណ៍និយម ។ យ៉ាងណាមិញ៖ ការដោះស្រាយបញ្ហា ពុទ្ធិ កាម៉ៈ មានលក្ខណៈស្របតាមគម្ពីរវេទទាំង ៤ គឺ ឫគ្វេទ, យជុរវេទ, សាមវេទ និងអថវវេទ ជាដើម ។ ការចែកលោកទាំងបីៈ ទេវលោក, មនុស្សលោក និងបាតាលក៏ដូចគ្នា ។ល។

យោបល់.— ដូច្នេះ ហិណ្ឌូនិយម មិនមែនជាលទ្ធិមួយដ៏ទំនើបទៀត ដោយ ក៏មិនមានលក្ខណៈអ្វីប្លែកពីលទ្ធិមុនដែរ ប៉ុន្តែតាមដំណាក់នៃសង្គមមនុស្ស ការកើតលទ្ធិហិណ្ឌូទើប គឺ ដើម្បីទប់ទល់ចំពោះការលូតលាស់នៃលទ្ធិមួយ ដែលទាំងក្នុងសម័យកាលមួយ ដូចជាពុទ្ធ-លទ្ធិនេះ ជាដើមផង ដើម្បីសម្របសម្រួលចិត្តមនុស្ស ដែលបេះតែចង់ទទួលនូវអ្វីៗ ដែលថ្មីនោះផង ។ លទ្ធិហិណ្ឌូត្រូវទទួលការបដិវត្តន៍ឡើង ដើម្បីសម្របទស្សនៈទៅតាមសង្គម នៃពួកហិណ្ឌូថ្មីនេះឯង ។

× × ×

## ពុទ្ធនិយម

អាទិបទ .— ពុទ្ធលទ្ធិ ពុំមែនជាសាសនាដោយសុទ្ធសាធទៀយ ហើយក៏ពុំមែន លទ្ធិដែលនិយមតាមទេព ដោយមានព្រះពុទ្ធជាគ្រូគង្វាលទេពធំៗនោះដែរ ប៉ុន្តែពុទ្ធលទ្ធិ ជាចំណេះវិជ្ជា ពោរពេញទៅដោយវិចារណញ្ញាណ ជាទស្សនវិជ្ជា និងជាវិទ្យាសាស្ត្រនេះឯង ។ ព្រះពុទ្ធ ជាមនុស្សមានរូបរស់នៅក្នុងសង្គមមនុស្ស ធ្លាប់ធ្វើកិច្ចការសំខាន់ៗ ដែលគេពិបាកធ្វើ ហើយធ្លាប់ បញ្ចេញទ្រឹស្តីបន្ទាន់ គប់មនុស្ស, ទេវតា, សត្វធាតុ ដោះបណ្តាលថែមទៀត ។ ដើម្បីស្គាល់ពុទ្ធលទ្ធិ នេះ យើងនឹងធ្វើការសិក្សានូវពុទ្ធប្រវត្តិជាមុនដូចតទៅ ៖

### ក- ពុទ្ធប្រវត្តិសង្ខេប .—

ព្រះពុទ្ធ ជាបុត្រក្សត្រសាក្យត្រកូលនៅដែនសក្ករក្រុងកបិលពស្តុ (ស្ថិតនៅក្នុងប្រទេសនេប៉ាល

សព្វថ្ងៃ) ទ្រង់យាងពីស្ថានតុសិតឈ្មោះ សន្តុសិតទេវបុត្ត មកយកបដិសន្ធិក្នុងស្ថានមនុស្ស ។ ព្រះបិតាទ្រង់នាម សិរីសុទ្ធោទនៈ ព្រះមាតានាម សិរិមហាមាយាទេវី ។ ទ្រង់ប្រសូត្រនៅថ្ងៃសុក្រពេញបូណ៌មីវិសាខមាស ឆ្នាំច មុន គ.ស ៦២៣ ឆ្នាំ នៅក្នុងសួនឧទ្យាន ១ ឈ្មោះ លុម្ពិនី ចន្លោះក្រុងកបិល-ពស្តុ និងទេវទហៈ ។ ព្រះមាតាទ្រង់ប្រថាប់ឈរ ដោយតោងឈើរាំងរែង ។ ពេលប្រសូតភ្លាម ទ្រង់យាងបាន៧ជំហាន ដោយមានផ្កាឈូកទ្រព្រះបាទ ហើយបន្លឺវាចាថា «អគ្គោហមស្មិ លោកស្ស សេដ្ឋោ... នត្ថិទានិ បុនព្ភវោ= ខ្ញុំជាកំពូលនៃលោក, ខ្ញុំប្រសើរជាងលោក, ជាតិនេះជាជាតិទីបំផុតនៃខ្ញុំ» ។

កាលប្រសូតបាន ៥ ថ្ងៃ ព្រះបិតាបានធ្វើពិធីថ្វាយព្រះនាមថា សិទ្ធត្ថ (អ្នកសម្រេចប្រយោជន៍គ្រប់យ៉ាង) ហើយក្រោយមក ២ ថ្ងៃទៀត (៧ ថ្ងៃ) ព្រះមាតាទ្រង់សោយទិវង្គតទៅកើតទៅស្ថានតុសិត ដោយអស់ព្រះជន្ម ។

កាលព្រះជន្មបាន ៥ ថ្ងៃ ជាថ្ងៃថ្វាយព្រះនាម និងទាយលក្ខណៈព្រះអង្គ មានព្រាហ្មណ៍ម្នាក់ឈ្មោះ កោណ្ឌញ្ញៈ ទាយថា ព្រះសិទ្ធត្ថ នឹងចេញបួស ហើយបានត្រាស់ជាព្រះពុទ្ធ ។

លុះព្រះជន្មបាន ១៦ ឆ្នាំ ត្រូវទទួលរាជាភិសេកឡើងសោយរាជ្យស្នងបិតា ដោយមានព្រះនាង យសោធរាពិម្ពា ជាមហេសី ហើយដល់ព្រះជន្ម ២៩ វស្សា (ក្រោយសោយរាជ្យ ១៣ឆ្នាំ) ទើបមានបុត្រ ១ ឈ្មោះ រាហុលកុមារ ។

ក្នុងថ្ងៃដែលរាហុលបុត្រប្រសូត ព្រះសិទ្ធត្ថទ្រង់យាងទៅក្រសាលក្នុងឧទ្យាន ហើយទ្រង់ទតឃើញទេវទូតទាំង ៤ គឺ: មនុស្សចាស់, ឈឺ, ស្លាប់ និងអ្នកបួស លុះយាងត្រឡប់មកវិញ ក៏ទ្រង់នឹកសង្វេគស្មុគព្រះទ័យ ដល់កណ្ដាលរាត្រី ក៏ទ្រង់ឲ្យ ឆន្នអាមាត្យ រៀបសេះ កណ្ឋកៈ ហើយយាងចេញទៅសាងផ្នួសដោយមានឆន្នអាមាត្យនិងសេះកណ្ឋកៈជូនដំណើរព្រះអង្គទៅនៅក្នុងថ្ងៃពេញបូណ៌មី ខែអាសាឍ ឆ្នាំថោះ ក្នុងព្រះជន្ម ២៩ ព្រះវស្សា ។ ទ្រង់គង់សេះរំលងនគរ ៣ គឺ: កបិលពស្តុ, សាវត្ថី និងវេសាលី ដល់ត្រើយស្ទឹងអនោមា ; ក៏ដោះគ្រឿងប្រដាប់គ្រហស្ថចេញ ទ្រង់សាងផ្នួសតែមួយព្រះអង្គឯង ។

ក្រោយពេលសាងផ្នួសហើយបាន ៦ ឆ្នាំ ដោយបានធ្វើទុក្ករកិរិយា ស៊ីនសាពចំរើនពមិនមក ក៏បានគេឃើញនូវប្រាជ្ញាសម្មាសម្ពោធិញ្ញាណ ដែលហៅថាការត្រាស់ដឹងនៅឧរុវេលាប្រទេស ក្បែរស្ទឹងនេរញ្ជរា នៅថ្ងៃពុធពេញបូណ៌មី ខែពិសាខ ឆ្នាំរកា ក្នុងព្រះជន្ម ៣៥ ព្រះវស្សា (មុន គ.ស ៥៨៨ ឆ្នាំ) ។

កាលទ្រង់បានត្រាស់ដឹងធម៌ហើយ ទ្រង់យកពុទ្ធិ ដែលព្រះអង្គបានគេឃើញនោះ ទៅទូន្មាន ដឹកនាំអប់រំមនុស្សសត្វអស់ចំនួន ៤៥ឆ្នាំ ហើយទ្រង់ចូលបរិនិព្វានរំលត់សង្ខារ នៅថ្ងៃអង្គារ ពេញបូណ៌មីឆ្នាំម្សាញ់ នៅនគរ កុសិនារា ក្នុងព្រះជន្ម ៨០ ព្រះវស្សា (មុន គ.ស ៥៤៣) ។

ដូច្នេះ យើងបានឃើញថា ព្រះពុទ្ធជាស្ថាបនិកពុទ្ធសាសនា ពុំមែនជាអាទិទេព គ្មានរូប, ធាតុនៃឈ្មោះនោះឡើយ ប៉ុន្តែ ជាមនុស្សដែលរស់ក្នុងសង្គមមនុស្ស ហើយបានដឹកនាំសង្គមមនុស្សឲ្យចំរើន ល្អ មានវិចារណញ្ញាណ ហើយព្រះអង្គបានស្លាប់នៅក្នុងសង្គមមនុស្សនេះឯង ។

## ២– ពុទ្ធលទ្ធិ.–

ប៉ុន្តែមួយចំនួនអ្នកប្រាជ្ញខាងនា បានយល់ដូចគ្នាថា : ពុទ្ធលទ្ធិ ពុំមែនជាសាសនា ដែលយកអាទិទេពជាធំទេ ព្រោះពុទ្ធអង្គក៏ពុំទុកព្រះអង្គឯងជាអាទិទេព. ទទួលខុសត្រូវចំពោះអំពើល្អ អាក្រក់របស់មនុស្សសត្វទេពតាដែរ ។ ពុទ្ធលទ្ធិគឺជាទស្សនវិជ្ជាដែលព្រះពុទ្ធ បានពន្យល់អ្នកផង ឲ្យដើរផ្លូវត្រូវប្រកបដោយ វិចារណញ្ញាណផង ឲ្យមនុស្សសត្វទាំងអស់ ពឹងលើខ្លួនឯង ផង (អត្តាហិ អត្តនោ នាថោ) ។ គោលបំណងនៃការពន្យល់ដោះស្រាយនូវបញ្ហាទុក្ខ, គឺ: សុខៈហ្នឹងដែរ ។

## បញ្ហាពុទ្ធិក្នុងពុទ្ធនិយម

១–ពុទ្ធិប្រភេទ.– ពុទ្ធិក្នុងពុទ្ធនិយម សំដៅយកការចេះដឹងយល់ដោយវិចារណៈ និង ការពាក់ព័ន្ធ ចំពោះបញ្ហា ។ ពុទ្ធិសំខាន់ ៗ របស់ព្រះពុទ្ធមាន ៣ ជាថ្នាក់ញាណដែលព្រះអង្គ ទ្រង់ពិចារណាឃើញក្នុងត្រីយាមនៅពេញបូណ៌មីខែពិសាខ ឆ្នាំរកា ដល់ថ្ងៃត្រាស់ដឹងនោះគឺ :

ក– បុព្វេនិវាសានុស្សតិវិជ្ជា.– ចំណេះដឹងដែលជាការរឭកបាន - ឃើញ - ទឹក ឃើញដល់ជាតិកំណើត - ទឹកដែន - គតិដែលព្រះអង្គធ្លាប់កើតជាអនេកជាតិ (បឋមយាម) ។

ខ- ចុតូបបាតវិជ្ជា.– ចំណេះចេះដឹង - យល់ស្គាល់នូវការស្លាប់កើតនៃមនុស្សសត្វ គ្រប់សព្វសត្វ ។

គ- អាសវក្ខយវិជ្ជា.– ចំណេះចេះដឹង - យល់ស្គាល់នូវហេតុនិងផលនៃការអស់ ទាំងកិលេស ។

វិជ្ជាសំខាន់ៗ ទាំងនេះ មុខនាំឲ្យព្រះអង្គយល់ដល់ធម៌កើត - រលត់ ដោយមានបច្ច័យ តាមធម្មតា ដែលហៅថាបដិច្ចសមុប្បាទ ១២ ទៀត ។

## បដិច្ចសមុប្បាទ

- អវិជ្ជាប្បច្ច័យា សង្ខារា សង្ខារកើតដោយអវិជ្ជា
- សង្ខារប្បច្ច័យា វិញ្ញាណំ វិញ្ញាណកើតដោយសង្ខារ
- វិញ្ញាណប្បច្ច័យា នាមរូបំ នាមរូបកើតដោយវិញ្ញាណ
- នាមរូបប្បច្ច័យា សឡាយតនំ អាយតនៈ ៦ កើតដោយនាមរូប
- សឡាយតនប្បច្ច័យា ផស្សោ ផស្សៈកើតដោយអាយតនៈ ៦
- ផស្សប្បច្ច័យា វេទនា វេទនាកើតដោយផស្សៈ (ការពាល់ត្រូវ)
- វេទនាប្បច្ច័យា តណ្ហា ចំណង់កើតដោយវេទនា
- តណ្ហាប្បច្ច័យា ឧបាទានំ ឧបាទានកើតព្រោះចំណង់
- ឧបាទានប្បច្ច័យា ភវោ ភពកើតព្រោះឧបាទាន
- ភវប្បច្ច័យា ជាតិ ជាតិកើតព្រោះភពជាបច្ច័យ
- ជាតិប្បច្ច័យា ជរាមរណំ ជរានិងមរណកើតព្រោះជាតិជាបច្ច័យ ។
- សោកបរិទេវទុក្ខទោមនស្សុបាយាសា សម្ភវន្តិ សេចក្តីសោកខ្សឹកខ្សួល ព្រួយ ទុក្ខ ចិត្ត និងចង្អៀតចង្អល់ចិត្តក៏កើតឡើងព្រោះ មានជាតិជាបច្ច័យ ។

ការកើតឡើងនេះ [illegible] ព្រះពុទ្ធទ្រង់ [illegible] អវិជ្ជា គឺលត់សង្ខារ... [illegible] លត់ៗ [illegible] និរោធធម៌ ។

ជំនែតប៉ុណ្ណោះ វិជ្ជា ៣ ដែលជាពុទ្ធិសំខាន់នេះ នាំឲ្យគេឃើញនូវសច្ចធម៌ ៤ទៀត ។

## អរិយសច្ចៈធម៌៤ យ៉ាង

ក- ទុក្ខអរិយសច្ច.- ទុក្ខដែលជាសភាពពិត ។ ទុក្ខនេះមាន៦ គឺ:

ជាតិទុក្ខ .- ទុក្ខព្រោះកំណើត

ជរាទុក្ខ .- ទុក្ខព្រោះចាស់

ព្យាធិទុក្ខ .- ទុក្ខព្រោះឈឺ

មរណទុក្ខ .- ទុក្ខព្រោះស្លាប់

សោកបរិទេវទុក្ខ ទោមនស្សុបាយាសាទុក្ខ.- ទុក្ខព្រោះសោក, ខ្សឹក, ខូចចិត្ត, ចង្អៀតចង្អល់ចិត្ត ជាដើម ។

ខ- សមុទយអរិយសច្ច .- ហេតុដែលនាំឲ្យកើតទុក្ខព្រោះមានអវិជ្ជា និងតណ្ហា ។

អវិជ្ជា .- មកពីមិនដឹងមិនយល់ហេតុនៃទុក្ខ ។

តណ្ហា .- ចំណង់ចង់បានខ្លួនឯង គ្រប់យ៉ាង មានកាមតណ្ហា - ចំណង់ក្នុងកាម៥ មានរូប, សម្លេងជាដើម, ភវតណ្ហា ចំណង់ក្នុងភព ដោយចង់កើតជាទេព, ព្រហ្ម មានរូបជាដើម និង វិភវតណ្ហា - ចំណង់ចង់ទៅកើតក្នុងអរូបភព ដោយយល់ថាជាបរមសុខ ។

គ- និរោធអរិយសច្ច .- សភាពពិតក្នុងការរំលត់ទុក្ខ ដោយបំបាត់អវិជ្ជា ជាប្រភពដើមនៃទុក្ខ ។

ឃ- មគ្គអរិយសច្ច .- វិធីសំរាប់រំលត់ទុក្ខ ប្រកបដោយមគ្គ (ផ្លូវ) មានអង្គ ៨ ហៅថា អដ្ឋង្គិកមគ្គ គឺ:

សម្មាទិដ្ឋិ .- យល់ឃើញត្រូវ

សម្មាសង្កប្ប.- ត្រិះរិះត្រូវ

សម្មាវាចា .- សំដីត្រូវ

សម្មាកម្មន្ត .- ការងារត្រូវ

សម្មាអាជីវៈ .– ការចិញ្ចឹមជីវិតត្រូវ

សម្មាវាយាម .– ព្យាយាមត្រូវ

សម្មាសតិ .– រលឹកឃើញត្រូវ

សម្មាសមាធិ .– តាំងចិត្តត្រូវ ។

ពុទ្ធទាំងអស់របស់ព្រះពុទ្ធ ដែលទ្រង់បានប្រោសប្រទានដល់សត្វលោកចំនួន ៤៥ ឆ្នាំ បានចងក្រងទៅជាពុទ្ធវចនៈ ១ ចែកជាបិដកបី ហៅថាព្រះត្រៃបិដក ។

## ព្រះត្រៃបិដក

១– វិន័យបិដក .– គម្ពីរ ឬ ក្បួននៃពុទ្ធ គឺ ព្រះវិន័យ ជាពុទ្ធានុញ្ញាត និង ពុទ្ធប្បញ្ញត្តិ មានចំនួន ២១០០០ ព្រះធម្មក្ខន្ធ មាន ៥ គម្ពីរ គឺ:

ក– អាទិកម្ម .– ច្បាប់និយាយពីទោសធ្ងន់ៗ ដូចជាបារាជិក ៤ សង្ឃាទិសេស ១៣ ជាដើម ។

ខ– បាចិត្តិយ .– ច្បាប់និយាយពីទោសស្រាល ដែលអាចសំដែងរួច បាន ដល់និស្សគ្គិយ បាចិត្តិយ ៣០ និងសុទ្ធិក បាចិត្តិយ ៩២ ។ល។

គ– មហាវគ្គ .– វគ្គ ឬ ផ្នែកធំ ចុះពុទ្ធានុញ្ញាត ដែលជាគោលវិន័យ ។

ឃ– ចុល្លវគ្គ .– វគ្គ ឬ ផ្នែកតូច បានដល់ពុទ្ធានុញ្ញាតបន្ទាប់ពីមហាវគ្គ ។

ង– បរិវារ .– វិន័យកាយវិធី ដែលរ[illegible] បញ្ញត្តិ និង អនុញ្ញាតជាខាងក្រោយ ។

២– សុត្តន្តបិដក .– ក្បួននៃពុទ្ធផ្នែកព្រះសូត្រ ដែលនិយាយពីអំពើល្អ និង អាក្រក់ ការធ្វើបុណ្យទានជាដើម ។ សុត្តន្តបិដកនេះ មាន ២១០០០ ធម្មក្ខន្ធ ដូចព្រះវិន័យ ដែរ ហើយចែកចេញជាភាគមាន ៥ គម្ពីរ គឺ:

ក– ទីឃនិកាយ .– ផ្នែកនៃព្រះសូត្រដែលមានន័យវែង ។

ខ– មជ្ឈិមនិកាយ .– ផ្នែកនៃព្រះសូត្រ ដែលមានន័យជាកណ្ដាល - ល្មម ។

គ– សំយុត្តនិកាយ .– ផ្នែកនៃព្រះសូត្រ ដែលមានន័យប្រកបដោយនិទាន

ជាឧទាហរណ៍ ។

ឃ- អង្គុត្តរនិកាយ.- ផ្នែកនៃព្រះសូត្រ ដែលមានន័យប្រកបដោយក្តីសំខាន់ៗ

ង- ខុទ្ទកនិកាយ.- ផ្នែកនៃព្រះសូត្រ ដែលមានន័យតូចៗ ។

៣- អភិធម្មបិដក.- កម្រងនៃទស្សនៈ, ត្រិះរិះ ដែលនិយាយពីបរមត្ថធម៌ ប្រកបដោយអត្ថ ៤ យ៉ាងគឺ: ចិត្ត, ចេតសិក, រូប, និព្វាន ហើយចែកជា ៧ គម្ពីរ គឺ:

ក- ធម្មសង្គណី.- ផ្នែកនៃធម៌

ខ- វិភង្គ.- អត្ថ ឬ ចំណែកនៃធម៌

គ- កថាវត្ថុ.- ធម៌មានន័យផ្សេងគ្នា

ឃ- បុគ្គលប្បញ្ញត្តិ.- បុគ្គលពណ៌នា

ង- ធាតុកថា.- ការពន្យល់ធាតុ

ច- យមក.- ធម៌មានគូៗ

ឆ- បដ្ឋាន.- ធម៌មានទំនាក់ទំនងដោយបច្ច័យ ។

ព្រះអភិធម្មបិដក មានចំនួន ៤២០០០ ព្រះធម្មក្ខន្ធ ។ គួរកត់សំគាល់ថា:

- វិន័យបិដក ប្រើដោយកិច្ច
- ព្រះសូត្របិដក ប្រើដោយវោហារ
- ព្រះអភិធម្មបិដក ប្រើដោយអត្ថ ។

គម្ពីរបិដកទាំង ៣ បើប្រមូលជាការប្រៀនប្រដៅនៅខាងលោកុត្តរ យ៉ាងខ្លីគឺ:

១- សព្វបាបស្ស អករណំ.- ប្រាប់ហាមមិនឲ្យធ្វើបាបគ្រប់យ៉ាង (បានដល់វិន័យបិដក) ។

២- កុសលស្សូបសម្បទា.- ប្រាប់ឲ្យបំពេញកុសលធម៌ (បានដល់ព្រះសូត្របិដក) ។

៣- សចិត្តបរិយោទបនំ.- ប្រាប់ឲ្យធ្វើចិត្តឲ្យផូរផង់ស្អាតស្អំ (បានដល់ព្រះអភិធម្មបិដក) ។

២- ពុទ្ធិវិធី.- ដើម្បីនឹងបានពុទ្ធិ ក្នុងលទ្ធិពុទ្ធនិយម គឺបានដោយការសាងសន្សំ, ការសិក្សាពិចារណា, ការពិសោធន៍ផ្ទាល់ខ្លួន ។ បើនិយាយដោយឡែកព្រះពុទ្ធទ្រង់ទុកនូវវិធី ៤ យ៉ាងហៅថាឥទ្ធិបាទធម៌គឺ:

ក- ឆន្ទៈ.- ពេញចិត្តនឹងកិច្ចការ, បំណងវិជ្ជា

ខ- វិរិយ.- ព្យាយាមរៀន - ពិចារណា

គ- ចិត្ត.- មានចិត្តនឹងប៉ុនប៉ងរៀន - ពិចារណា

ឃ- វិមំសា.- សាកល្បងលទ្ធកិច្ចការ, បំណងវិជ្ជាដែលខ្លួនរៀនហើយ ។

ព្រះពុទ្ធកាលមុននឹងកើតពុទ្ធិ ដែលជាវិជ្ជាឃើញក្នុងថ្ងៃត្រាស់ដឹងនោះ ព្រះអង្គព្យាយាមរៀនជាមួយនឹងឧទកតាបសនិងអាឡារតាបស លុះរកការត្រាស់ដឹងមិនឃើញក៏ប្រឹងស៊ូទ្រាំព្យាយាមដោយព្រះអង្គឯង នៅថ្ងៃត្រាស់ដឹងក៏ទ្រង់ពិចារណាដោយវិធីច្រាសបណ្តោយចុះឡើង ។ ទើបឃើញបដិច្ចសមុប្បាទ ហើយកែវប្រាជ្ញាក៏ភ្លឺស្វាងឡើង ។

## ៣- ពុទ្ធិទាន.- បញ្ញាកម្ម - ផល

មនុស្សមានការចេះដឹង ល្ងង់ខ្លៅ ល្អអាក្រក់ស្រេចនៅលើខ្លួនឯង, លើអំពើរបស់ខ្លួន ៗ និងមានវិជ្ជា - ចេះដឹងបានសម្រេចមគ្គផល ក៏ដោយសារខ្លួនឯងបានសិក្សាសន្សំ - ប្រឹងស៊ូទ្រាំ, បើល្ងង់ខ្លៅឥតប្រាជ្ញា ក៏ដោយសារការខ្ជិលច្រអូស - ធ្វេសប្រហែស ។

បើបានល្អ - អាក្រក់ក៏ដោយសារកម្មនិងផល ២ យ៉ាង :

ក- កល្យាណកម្ម.- អំពើល្អឲ្យផលល្អ

ខ- បាបកម្ម.- អំពើអាក្រក់ឲ្យផលអាក្រក់ ព្រះពុទ្ធបានបញ្ជាក់ដោយពុទ្ធភាសិតមួយទៀតថា (យាទិសំ វប្បតេ ពីជំ តាទិសំ លភតេ ផលំ= អ្នកណាសាបព្រួសពូជបែបណា អ្នកនោះនឹងបានផលបែបនោះ) ។

រួមមកហើយនេះ យើងបានឃើញថា ការដោះស្រាយបញ្ហាពុទ្ធិ ក្នុងពុទ្ធនិយមមានលក្ខណៈជាវិចារណៈ, ជាកំលាំងខ្លួនឯង ជាវិទ្យាសាស្ត្រ និងប្រាកដនិយមដែលទៀតគ្មានការទេពណាជាធំតាម

ជួយអ្នកណាឲ្យល្អ បរិសុទ្ធបានឡើយ (សុទ្ធិ អសុទ្ធិ បច្ចត្តំ នាញ្ញោ អញ្ញំ វិសោធយេ-
ការបរិសុទ្ធិ និងមិនបរិសុទ្ធមានលក្ខណៈផ្សេងគ្នា មនុស្សម្នាក់មិនអាចធ្វើឲ្យមនុស្សម្នាក់ទៀតបរិសុទ្ធ
បានទេ)។

## បញ្ហាភាវៈក្នុងពុទ្ធនិយម

**ក- ភាវៈប្រភេទ.-** ក្នុងលទ្ធិពុទ្ធនិយម មានការចែកលោកជា៣ ប្រភេទ ដែលហៅថា ត្រៃលោក ឬ ត្រៃភពគឺៈ កាមភព១, រូបភព១, អរូបភព១ ។

### កាមភពមាន ១១ ជាន់គឺៈ

- ឋានកាមាវចរសួគ៌ ៦ ជាន់បានដល់ៈ

១- ឋានចាតុម្មហារាជិកា (មានទេវតាធំ ៤)

២- ឋានត្រៃត្រឹង្ស (មានទេវតា ៣៣ អង្គ មានព្រះឥន្ទ្រជាធំ)

៣- ឋានយាមា

៤- ឋានតុសិត (ជាទីនៅនៃអ្នកមានបុណ្យ)

៥- និម្មានរតី

៦- បរនិម្មិតវសវត្តី

- ឋានមនុស្ស ១ ជាន់

- ឋានអបាយ (អបាយភូមិ) ៤ ជាន់

រូបភព ១៦ ជាន់ បានដល់ឋានព្រហ្មមានរូបទាំង ១៦ ជាន់ ។

- ឋានអរូបភព ៤ ជាន់ បានដល់ឋានព្រហ្មឥតរូប ៤ ជាន់ មានអាកាសានញ្ចាយ-តនៈជាដើម ។

### ឋានកាមភព

ជាលំនៅនៃមនុស្ស, ទេវតា, សត្វ ដែលនៅជាប់ជំពាក់ក្នុងកាមគុណ ៥ ។

- ពួកទេវតា ជាអ្នកមានបុណ្យបារមីសន្សំទុកច្រើន សោយសុខច្រើន ។

– ពួកមនុស្សនិងសត្វ មានបុណ្យខ្លះ គ្មានបុណ្យខ្លះ ។

## ឋានអបាយ (អបាយភូមិ)

មាន: នរក, ប្រេត, អសុរកាយ, តិរច្ឆាន ។ (បាននិយាយរួចមកហើយ) ។

## ឋានមនុស្ស - និងមនុស្សប្រភេទ

មនុស្សក្នុងនិយម ចែកចេញជា ២ ផ្នែកផ្សេងគ្នា:

ក– មនុស្សខ្ពង់ខ្ពស់ ឬ អរិយបុគ្គល .- មនុស្សពួកទី១ នេះ បានដល់ពួកព្រះអរហន្តខីណាស្រពទាំងឡាយផង ពួកអ្នកបានសម្រេចមគ្គផលផ្សេងៗផង មានព្រះពុទ្ធ, អរហន្តសាវ័ក, ព្រះបច្ចេកពុទ្ធ, ព្រះពោធិសត្វជាដើម ។

ខ– មនុស្សសាមញ្ញ .- បានដល់មនុស្សទូទៅជាបុថុជ្ជន មិនទាន់បានសម្រេចមគ្គផលណាមួយនៅឡើយ ។

## ខ– ភាវៈវិធី.-

ភាវៈទាំងអស់មាន ២ ចំណែកគឺ ភាវៈជានាម ១ ភាវៈជារូប ១ ។

១– ភាវៈជានាមសំដៅយកចិត្ត

២– ភាវៈជារូបសំដៅយកកាយ ។

នាមនិងរូប ឬ ចិត្តនិងកាយនេះ កើតផ្សំគ្នាបង្កើតជាជីវិតប្រកបដោយខន្ធ ៥ គឺ រូបខន្ធ, វេទនាខន្ធ, សញ្ញាខន្ធ, សង្ខារខន្ធ និងវិញ្ញាណខន្ធ ។

ជីវិតដែលទាំងឡាយកើតមានឡើង មិនមែនដោយអាទិទេពណាជាអ្នកបង្កើតឡើយ តែដោយសង្ខតធាតុដែលផ្សំផ្គុំគ្នាឡើង តាមធម្មជាតិនេះឯង ។

## គ– ភាវខាង.-

ភាវៈជាសង្ខតធាតុទាំងអស់ ស្ថិតនៅលើត្រៃលក្ខណ៍ដូចតទៅ:

**១– អនិច្ចំ.–** ភាវៈទាំងអស់សុទ្ធតែមិនទៀងទាត់ គឺមានកើតស្លាប់ចំរើនវិនាស មិនទៀងពេល និងទីកន្លែង ។

២- ទុក្ខំ.- ការៈទាំងអស់ឡើតែមានខាងរូបនិងនាម សុខក៏មានទុក្ខផងដែរ ។

៣- អនត្តា.- ការៈទាំងអស់សុទ្ធតែមិនមែនជារបស់ខ្លួន ។

ដូច្នេះលោកៈក្នុងពុទ្ធនិយម ពុំមែនជាទិដ្ឋ ជាទ្រឹស្តីឡើយ ។

## បញ្ហាសុខៈ ក្នុងពុទ្ធនិយម

១- សុខប្រភេទ.- សុខក្នុងពុទ្ធវិជ្ជាមាន ២ យ៉ាងគឺ:

ក- សាមញ្ញសុខ ឬ លោកិយសុខ.- ជាសុខធម្មតា ឬ ហៅថាកាមសុខ គឺជាសុខនៅលាយឡំជាមួយទុក្ខ ។

ខ- បរមសុខ.- សុខដ៏ប្រសើរក្នុងខ្លួន គឺសុខដែលកើតមកពីចិត្តស្ងប់ មានដល់ព្រះនិព្វាន ។

២- សុខវិធី.- សុខធម្មតា មានការទាក់ទងទៅនឹងប្រយោជន៍ ៤ យ៉ាងក្នុងបច្ចុប្បន្នគឺ:

ក- ឧដ្ឋានសម្បទា.- ដល់ព្រមដោយព្យាយាម

ខ- អារក្ខសម្បទា.- ដល់ព្រមដោយការថែរក្សា

គ- កល្យាណមិត្តតា.- មានមិត្តល្អ

ឃ- សមជីវិតា.- ការចិញ្ចឹមជីវិតស្របតែ ។

ចំណែកឯការសុខក្នុងលោក ឬ បរមសុខ មានទាក់ទងនឹងសីល, សមាធិ បញ្ញាផង ទាក់ទងនឹងប្រយោជន៍ក្នុងបរលោក ៤ យ៉ាងផងគឺ:

ក- សទ្ធាសម្បទា.- ដល់ព្រមដោយជំនឿ

ខ- សីលសម្បទា.- ដល់ព្រមដោយសីល

គ- ចាគសម្បទា.- ដល់ព្រមដោយការបំណាយទាន

ឃ- បញ្ញាសម្បទា.- ដល់ព្រមដោយប្រាជ្ញា ។

ដូចនេះ គប្បីដុសខាត់ចិត្តឲ្យស្អាតចាកតំរេក, តណ្ហា, កិលេសផ្សេងៗនិងគប់រំខានចិត្ត

ដើម្បីសម្រេចមគ្គផលជាខ្ពស់គឺអរហត្តមគ្គនិងអរហត្តផលជាអវសាន ។

### ៣-សុខខាង...

បរមសុខក្តី សុខធម្មតាក្តី មិនមែនជាអំណោយនៃអាទិទេព ឬព្រះពុទ្ធ ឬ សាវ័កណាឡើយ ប៉ុន្តែជាផលដែលកើតចេញពីខ្លួនឯង , បានមកពីការប្រព្រឹត្តិធ្វើដោយខ្លួនឯងនេះតែម្តង ។ ដូច្នេះ ដើម្បីសម្រេចបរមសុខ ជាសុខសំខាន់ជាងសុខធម្មតាគេត្រូវ :

- លះបង់តណ្ហា
- កំចាត់អវិជ្ជា
- មិនប្រមាទធ្វេសប្រហែស
- តំកល់ចិត្តក្នុងសីលសមាធិបញ្ញា
- លះបង់អត្តៈ កុំប្រកាន់ថាខ្លួន , ថារបស់ខ្លួន ។

## យោបល់រួមចំពោះបញ្ហាពុទ្ធនិយម

**ពុទ្ធលទ្ធិ** ទោះបីកើតឡើងនៅក្រោយសម័យ ព្រាហ្មណ៍និយមក្តី កើតនៅក្នុងសង្គមហិណ្ឌូក្តី ក៏ពុទ្ធលទ្ធិមិនមែនជាលទ្ធិដែលកែប្រែដើម្បីកែក្រលទ្ធិព្រាហ្មណ៍សម្រាប់ជាផលប្រយោជន៍ពួកព្រាហ្មណ៍ឡើយ ពោលគឺពុទ្ធលទ្ធិមានលក្ខណៈជាលទ្ធិ ប្រកបដោយទស្សនៈទ្រឹស្តីជាវិចារនិយម និងវិទ្យាសាស្ត្រថែមទៀតៗ ព្រះពុទ្ធអង្គមហាទស្សនវិទូ មួយអង្គក្នុងសម័យនោះ ពុំបានទុកវណ្ណៈមនុស្សជាបួនពួកទេ តែព្រះអង្គបានឲ្យតម្លៃទៅលើអំពើផលនៃមនុស្ស , ការប្រឹងប្រែងសន្សំសាងបារមីរបស់មនុស្សទៅវិញ ហើយគោលបំណងធំគឺបង្កឲ្យមនុស្ស ជឿលើខ្លួនឯងជាមុនក្នុងដំណើរ ទៅកាន់បរមសុខ ជាឧត្តមៈ ឯកន្តសុខ គឺនិព្វានហ្នឹងឯង ។

× × ×

## មូលធម៌នៃវប្បធម៌ខ្មែរ

វប្បធម៌ខ្មែរកើតជាមានឡើងមកហើយ តាំងពីសម័យបុរេប្រវត្តិសាស្ត្រ (Préhistoire) មកម្ល៉េះ

ប៉ុន្តែចំនួនខ្លះនៃវប្បធម៌ ដែលជាផ្នែកនៃគោលគំនិត - ការបេះដូង (ជាពុទ្ធិ) នៃជនជាតិមួយ ៗ នៅសម័យបុរេប្រវត្តិសាស្ត្រ ដែលមានចំណុះ ពុំទាន់គ្រប់គ្រាន់ស្របតាមកាលវិវត្តន៍នៅឡើយ ។ ដូច្នេះគោលគំនិតថ្មី ៗ របស់ខ្មែរត្រូវតែរះទៅទៀតជានិច្ច ។

ជាមួយនឹងការរកគំនិតនេះខ្មែរបានជួបនឹងវប្បធម៌មួយមុនគេ គឺវប្បធម៌ឥណ្ឌា ។ រឿងនេះជាការពិតហើយឥតប្រកែកបាន ព្រោះឥណ្ឌាបាននាំវប្បធម៌របស់ជាតិខ្លួនដែលមានវ័យចាស់ទុំបន្តិចទៅហើយចូលមកស្រុកខ្មែរតាមផ្លូវជំនួញនិងសាសនា ។ តាមផ្លូវជំនួញ មានពួកឥណ្ឌាមកទិញគ្រឿងទេសដូចជាម្រេចជាដើម តាមដើងទឹក ។ ផ្លូវសាសនា ឥណ្ឌាបាននាំសាសនា ២ ចូលមកប្រទេសខ្មែរ ដោយមិនអាចប្រកែកបានគឺព្រាហ្មណ៍សាសនា និងពុទ្ធសាសនា ។

## ប្រវត្តិសាសនាចូលមកស្រុកខ្មែរ

សាសនាឥណ្ឌាធំ ៗ ពីរគឺ ព្រាហ្មណ៍សាសនានិងពុទ្ធសាសនាត្រូវឥណ្ឌានាំចូលមកស្រុកខ្មែរ ។ ពុទ្ធសាសនា មានពីរផ្នែកទៀតគឺ ពុទ្ធសាសនាអាចារិយវាទ (មហាយាន) និងពុទ្ធសាសនាថេរវាទ (ហីនយាន) ។ សាសនាព្រាហ្មណ៍និងពុទ្ធសាសនាទាំងពីរបែប បានមានជីវិតរស់នៅក្នុងប្រទេស, សង្គម, ជីវភាព រហូតដល់សព្វថ្ងៃដោយសុខសាន្តជាមួយគ្នា គ្រាន់តែមានការរីកចំរើនម្ដងម្នាក់ក្នុងសម័យមួយ ៗ :

– ពីគ្រិស្តសតវត្សទី ១ ដល់ទី៨ ពុទ្ធសាសនាថេរវាទចំរើនលូតលាស់ជាងព្រាហ្មណ៍សាសនា និងពុទ្ធសាសនាអាចារិយវាទ (មហាយាន) ។

– ពីគ្រិស្តសតវត្សទី ៨ ដល់ទី ១៣ ព្រាហ្មណ៍សាសនាចំរើនជាងពុទ្ធសាសនាទាំងពីរ ។

– ពីគ្រិស្តសតវត្សទី១៣ ដល់សព្វថ្ងៃ ពុទ្ធសាសនាថេរវាទ (ហីនយាន) ចំរើនជាងព្រាហ្មណ៍សាសនា ។

គួរកត់សំគាល់ថា នៅចុងសតវត្សទី ១២ (ប្រហែលពី ១១៨១ ដល់ដើមសតវត្សទី ១៣) ពុទ្ធសាសនាអាចារិយវាទ (មហាយាន) បានចំរើនជាងពុទ្ធសាសនាថេរវាទ (ហីនយាន) យ៉ាងច្រើន ព្រោះនៅនឹងប្រាសាទបាយ័ន និងប្រាសាទនានា ដែលសាងក្នុងរជ្ជស្តេចជ័យវរ្ម័នទី ៧ (១១៨១-

១៤១៨ ឬ ១៤៤០ ) មានសាងរូបពោធិសត្វ អវលោកិតេស្វរៈ ( ព្រះកេត្ត ៤ ) ជាច្រើនដែរ ។

## ចំណូលនៃលទ្ធិព្រាហ្មណ៍និយមមកក្នុងប្រទេសខ្មែរ

លទ្ធិព្រាហ្មណ៍និយម ត្រូវចូលមកស្រុកខ្មែរ តាំងពីមុនគ្រិស្តសករាជមកម៉្លេះ ប៉ុន្តែកាលច្បាស់លាស់គឺ នៅដើមគ្រិស្តសករាជ ពួកព្រាហ្មណ៍បាននាំយកលទ្ធិនេះចូលមកក្នុងស្រុកខ្មែរ ហើយបន្ទាប់ពីនោះ គឺព្រាហ្មណ៍ម្នាក់ឈ្មោះ **កៅឌិន្យ** បានមករៀបការជាមួយនាង **លីវយី** នៅលើកោះ **គោកធ្លក** ឲ្យខ្មែរគោរពសាសនាព្រាហ្មណ៍ ហើយខ្មែរខ្លះបានយកព្រះព្រហ្មជាធំ ខ្លះយកព្រះវិស្ណុ ខ្លះយកព្រះសិវៈ ជាអាទិទេព ។ ឥទ្ធិពលនៃសាសនាព្រាហ្មណ៍បានលាតត្រដាងនៅក្នុងសិល្បៈ[illegible]សិល្ប៍, ទំនៀមទម្លាប់, ប្រពៃណី និងសង្គមខ្មែរយ៉ាងច្រើន ។

### ១- សិល្បៈខ្មែរបែបព្រាហ្មណ៍និយម

**ក- ក្នុងសិល្បៈរចនាប្រាសាទបុរាណ.-**

ប្រាសាទខ្មែរស្ទើរតែទាំងអស់ នៅគ្រប់រចនាបថ លើកលែងតែរចនាបថ **បាយ័ន** មួយចេញ សុទ្ធសឹងតែសាងឡើងឧទ្ទិសចំពោះព្រះសិវៈ (ឥសូរ) និងវិស្ណុ (ព្រះនារាយណ៍ទាំងអស់) ។

**-ពួកប្រាសាទសាងថ្វាយព្រះសិវៈ.-** ប្រាសាទពួកនេះគេទុកជាបូជនីយដ្ឋាន ចំពោះព្រះសិវៈ ដូចប្រាសាទសំបូរព្រៃគុក, ភ្នំធំ, ប្រាសាទនាងខ្មៅ, កំពង់ព្រះ, ភូមិប្រាសាទ, ដីក្រហម, ខ្ទីងស្ពាប់, រូបភាគ្យ, ថ្មដាប់, ព្រះគោ, បាគង, លលៃ, ភ្នំបាខែង, ភ្នំក្រោម, កោះកេរ, បន្ទាយស្រី, ឃ្លាំង, តាកែវ, ពិមានអាកាស, ភ្នំជីសូរ, ព្រះវិហារ, ចៅស្រីវិបុល ជាដើម ។

**ខ- ភស្តុតាង.-** ប្រាសាទទាំងនេះ មានរូបលិង្គព្រះសិវៈនិងយោនីតាំងមានគង់នៅពាសពេញ ។

**ចំណាំ** - ប្រាសាទភ្នំបាខែង មានលក្ខណៈល្អិតល្អតាមក្បួនព្រាហ្មណ៍ហើយសម្បូណ៌លិង្គនិងយោនីជាងគេ ។

**-ពួកប្រាសាទសាងថ្វាយព្រះវិស្ណុ.-** ប្រាសាទពួកនេះគេទុក ជាបូជនីយដ្ឋានចំពោះព្រះវិស្ណុ ដូចប្រាសាទបាពួន, វត្តភូ, មេបុណ្យ, អង្គរវត្ត, បន្ទាយសំរែ, ព្រះពិធូ, ធម្មនន្ទ

ទៅសាយមទេវតា , វត្តអគ្គា ជាដើម ។

ភស្តុតាង.– ប្រាសាទទាំងនេះ មានរូបព្រះវិស្ណុឈរឬអង្គុយជាច្រើនដូចនៅប្រាសាទមេបុណ្យខាងលិច មានរូបព្រះវិស្ណុផ្ទំជានិមិត្តរូបនៃការគិតបង្កើតលោក ។

ចំណាំ.– ប្រាសាទអង្គរវត្ត គេសាងថ្វាយព្រះវិស្ណុតាំងស្រេចក្នុងរាជ្យស្តេចសូរិយ-វរ្ម័នទី ២ ហើយស្តេចអង្គនេះកាលសុគតទៅ ក៏មានព្រះនាមថា «បរមវិស្ណុលោក» ដែរ ។

## លក្ខណៈប្រាសាទ

ក្នុងព្រាហ្មណ៍និយម គេតែងសង់ប្រាសាទលើភ្នំធម្មជាតិ ឬលើទីខ្ពស់ដែលគេលើកដីភ្នំឡើង ។

សំគាល់.– រូបលក្ខណៈនៃរូបបដិមាព្រះព្រហ្ម ព្រះសិវៈ ព្រះវិស្ណុនិងប្រពន្ធក្នុងព្រមទាំងគ្រឿងអលង្ការ , គេបានពណ៌នានិយាយក្នុងលទ្ធិព្រាហ្មណ៍ខាងដើមរួចហើយ ។

## ២– អក្សរសិល្ប៍ខ្មែរបែបព្រាហ្មណ៍និយម

អត្ថបទអក្សរសិល្ប៍បែបព្រាហ្មណ៍មានទៅក្នុងគម្ពីរផ្សេងៗ ដូចគម្ពីរវេទទាំង ៤ គម្ពីរមហា-ភារតៈ , រាមាយណៈ , បុរាណៈ , តន្ត្រៈ (បញ្ចតន្ត្រៈ) ធម្មសាស្ត្រជាដើមជាភាសាសំស្ក្រឹត ។

ខ្មែរយើងយកគម្ពីរទាំងនោះជាគោលដែរ តែបានរៀបរៀងដែលជាអត្ថបទអក្សរសិល្ប៍ខ្មែរឡើង មានលក្ខណៈជាខ្មែរតាមទស្សនៈ , មនោសាស្ត្រ , និងការរបស់ខ្មែរ ដែលមានហេតុការណ៍អស្ចារ្យ, សិល្បសាស្ត្រ , មន្តអាគម ជាបែបជំនឿរបស់ខ្មែរដែលខ្មែរធ្លាប់មានតាំងពីពេលមុនសាសនាព្រាហ្មណ៍ចូលផ្សាយឥទ្ធិពលមកម៉្លេះ ។ អត្ថបទអក្សរសិល្ប៍ខ្មែរដែលមានលក្ខណៈជាព្រាហ្មណ៍និយមនេះមានច្រើនដែរ ដូចជារាមកេរ្តិ៍ខ្មែរ , រឿងព្រះជិនវង្ស , ទិព្វសង្វារ ជាដើម ។

## លក្ខណៈអក្សរសិល្ប៍ខ្មែរបែបព្រាហ្មណ៍និយម

១– ផ្តើមរឿង.– បង្ហាញពីឈ្មោះអាទិទេពធំៗ ដូចព្រហ្ម , វិស្ណុ , សិវៈ ។

២– តួរឿង .–

ក.– តួអង្គ.– អាទិទេពឬអវតារនៃព្រះវិស្ណុ, សិវៈមកយកកំណើតក្នុងមនុស្សជា

បុរសអស្ចារ្យនិងនារីអស្ចារ្យ ។ តួអង្គនានាមានឥសី, ទេវៈ, យក្ស, គ្រុឌ ។ល។

- ដំណើររឿង.– ច្បាំងមិនចេះចប់ ប្រកបដោយសិល្បសាស្ត្រអស្ចារ្យ ។

គ– ទីកន្លែង.– ព្រៃហេមពាន្ត, ក្រុងអយុធ្យា, ស្ថានសួគ៌, ភ្នំកៃលាស, បាតាល, ស្ថានសិទ្ធវី ។ល។

ឃ– បញ្ហាចោទ.– ដោយមានវិបត្តិទំនាស់រវាងសភាវៈល្អនិងសភាវៈអាក្រក់ ។

ង– បញ្ហាដោះស្រាយ.– ដោយសិល្បមន្ត ឫទ្ធិអំណាច, សង្សឹក, ច្បាំងគ្នា ។

ច– ស្នេហា.– មកពីឥទ្ធិពលនៃកាមទេព ហើយអ្នកឈ្នះ គឺបានទទួលស្នេហា ។

ឆ– កំសត់.– កើតដោយវិបត្តិទំនាស់រវាងសភាវៈល្អនិងអាក្រក់ ច្បាំងទាស់ទែង, មានការណកម្លាតផ្លូវចិត្ត (រាមកេរ្តិ៍) ឬកាយ (ជិនវង្ស) ។

ជ–គតិរឿង.– ធ្វើឲ្យមនុស្ស :

–មានជំនឿលើអាទិទេព

–ស្គាល់អាទិទេពនិងឥទ្ធិពល

–ខ្វះការគោរពលើខ្លួនឯង

–ខ្វះសីលធម៌ ។ល។

៣– បញ្ចប់រឿង.– រឿងតែងបញ្ចប់នៅពេលណា ដែលតួអង្គតំណាងអាទិទេព, មានជ័យជំនះលើសភាវៈអាក្រក់ យក្ស, គ្រុឌ, អសុរ ។

## ៣– ព្រាហ្មណ៍និយមនិងសង្គមខ្មែរ

### ទំនៀមទំលាប់ - ប្រពៃណី

ក្នុងសង្គមខ្មែរ មានទំនៀមទំលាប់ប្រពៃណីជាច្រើនដែលមានទាក់ទងនឹងលទ្ធិព្រាហ្មណ៍និយម (លាយនឹងពុទ្ធនិយមខ្លះផង) ដូចជា :

ក–ពិធីប្រូកក់ប្រសិទ្ធីទារក.– មានផ្លាត់ព្រលឹង, អន្ទងព្រលឹង ។

ខ–ពិធីកោរជុក.– ប្រើមន្តគាថាប្រសិទ្ធ ។

គ- ពិធីរៀបមង្គលការ.- ធ្វើនំអន្សមតំណាងលិង្គឥស្សូរ , ធ្វើនំគម តំណាង យោនីនាងឧមាភគវតី ។ ធ្វើពិធីបុកល័ក្ខណ៍, បង្វិលពពិល , បញ្ចុកបេក ។ គ្រមុំកម្លោះស្រឡាញ់គ្នាមានដាក់ស្នេហ៍ , មន្តអាគម ។

ឃ- ធ្វើពិធីសែនព្រេន.- ឡើងផ្ទះថ្វាយស្រា , ស្លាធម៌ , បាយសី ។

ង- ក្នុងពិធីបុណ្យទាន.- មានធ្វើរោងទេវតា ៨ ទិស , ធ្វើទ្រុង , មានស្លាធម៌ បាយសី ៧ ជ្រុង ។

ច- ធ្វើពិធីបក់ព្រលឹង

ឆ-ពិធីលោយសព.- មានធ្វើបកិច្ចផ្ទុំខ្មោចនៅពេលបូជាសពរួច លាងធាតុដោយ ទឹកដូង (លាងបាប) ។

ជ- ព្យាបាលជម្ងឺ.- ប្រើមន្តអាគម, ស្រោចទឹក, គ្រូប្រើសំពត់សអាវស , ក្រមាសបង់ ។ល។

នៅមានពិធីច្រើនទៀតណាស់ ដែលទាក់ទងនឹងលទ្ធិព្រាហ្មណ៍និយម ប៉ុន្តែពិធី, កិច្ចការទាំងនេះមានខ្លះ ។ ជារបស់ខ្មែរស្រេចទៅហើយ ។ ដូច្នេះខ្មែរយករបស់អ្នកណាមកធ្វើក៏ក្រៀវ យ៉ាងណា ទ្រូទៅជារបស់ខ្មែរ មានលក្ខណៈជាខ្មែរវិញ ។

× × ×

## ២- ពុទ្ធនិយមក្នុងសង្គមខ្មែរ

### ក- ចំណូលមកក្នុងស្រុកខ្មែរនៃពុទ្ធសាសនា.-

តតិយសង្គាយនា ក្រោមមហាថេរាធិបតីនៃព្រះមោគ្គលីបុត្តតិស្សត្ថេរ ដោយមានព្រះបាទអសោកមហារាជ ជាអ្នកឧបត្ថម្ភ បានធ្វើចប់នៅ ព.ស. ២៣៦ នៅវត្តអសោការាម ក្រុងបាតលីបុត្ត (ឧប្បត្តិហេតុនៃតតិយសង្គាយនានេះ កើតឡើងតាំងពី ព.ស. ២១៨ ឆ្នាំម្ល៉េះ) ។ ក្រោយ

តតិយសង្គាយនានេះ ព្រះមោគ្គលីបុត្តទ្រង់បានបញ្ជូនព្រះសមណទូត ទៅគ្រប់ទិសទីក្នុងជម្ពូទ្វីប ចំនួន១៦ កន្លែង ដើម្បីផ្សាយព្រះពុទ្ធសាសនា ។ ព្រះសោណត្ថេរ និងព្រះឧត្តរត្ថេរ បាននិមន្តចូលមកកាន់ដែនដីសុវណ្ណភូមិ (មានភូមា, សៀម, ខ្មែរ, លាវ) ដើម្បីផ្សាយព្រះពុទ្ធសាសនា ។ ប្រទេសខ្មែរបានទទួលយកពុទ្ធសាសនាថេរវាទ តាំងពីពុទ្ធសតវត្សទី៣ នៃពុទ្ធសករាជនោះឯង ។

## ខ- ពុទ្ធសាសនានិងប្រជាជនខ្មែរ.-

ព្រះពុទ្ធសាសនាទាំងពីរនិកាយ គឺនិកាយមហាយាន និង ហីនយាន បានផ្សាយចូលមកក្នុងសង្គមខ្មែរតាំងពីដើមមក ។ ប៉ុន្តែនិកាយហីនយាន (ថេរវាទ) មានការលូតលាស់ជាងនិកាយមហាយាន (អាចរិយវាទ) លើកលែងតែនៅចុងគ្រិស្តសតវត្សទី ១២ និងដើមសតវត្សទី ១៣ បន្តិចចេញ (សម័យរចនាបថបាយ័ន - រជ្ជស្តេចជ័យវរ្ម័នទី ៧) ដែលនិកាយមហាយានរីកចំរើនជាងហីនយាន ។

**ចំណាំ.-** និកាយមហាយាន-ហីនយានបានបែកចេញពីគ្នា ក្រោយទុតិយសង្គាយនា នៅវត្តវាលុការាម ក្រុងវេសាលីដែនវជ្ជី ក្រោយពុទ្ធបរិនិព្វាន១០០ ឆ្នាំ រឿងវត្ថុ ១០ ប្រការ ។ និកាយមហាយាន បែកទៅទិសខាងជើងនៃប្រទេសឥណ្ឌា ឬ ហៅថាឧត្តរនិកាយ ២ និកាយហីនយាន បែករីកចំរើនមកផ្នែកខាងត្បូង ហើយទីបំផុតរីកចំរើននៅកោះលង្កាទ្វីប ដែលជានិកាយត្រឹមត្រូវមានព្រះអរហន្តសាវកតាំងទ្រតាមពុទ្ធវិន័យ ឬ ហៅថាទក្ខិណនិកាយ ។

និកាយមហាយាន គោរពព្រះពោធិសត្វជាងព្រះពុទ្ធ ព្រោះគេយល់ថា ព្រះពុទ្ធនិព្វានទៅហើយ មិនអាចនៅជួយយកយានដឹកនាំសត្វឲ្យទៅនិព្វានបានទេ មានតែពោធិសត្វ ទើបជួយបាន ព្រោះពោធិសត្វមិនទាន់បានត្រាស់ មិនទាន់និព្វាន ។

ឯនិកាយហីនយាន (ថេរវាទ) គោរពតាមតែព្រះពុទ្ធ ដែលទ្រង់សំដែងរួចមកហើយតែប៉ុណ្ណោះ ។

ប្រជាជនខ្មែរបានយកពុទ្ធសាសនា បែបថេរវាទនេះ មកគោរពប្រតិបត្តិជាច្រើនសតវត្សណាស់មកហើយៗ សូម្បីក្នុងសម័យនុះ សាសនាព្រាហ្មណ៍មានឥទ្ធិពលជាង ក៏ពុទ្ធសាសនាថេរ-

រាជធានីតែមានជីវិតនិងរស់នៅក្នុងសង្គមខ្មែរ ដោយសុខសាន្តជាដរាប ជាពិសេសចាប់តាំងពីសតវត្សទី ១៣ រហូតដល់សព្វថ្ងៃ ពុទ្ធសាសនាថេរវាទបានរីកចំរើនយ៉ាងខ្លាំងក្នុងប្រទេសខ្មែរដែលមិនអាចនឹងមានសាសនាណាដទៃ ចូលមកផ្សព្វផ្សាយយកជ័យជំនះបាន ព្រោះពុទ្ធសាសនាថេរវាទបានចាក់ឫសយ៉ាងក្នុងសង្គមនិងចិត្តគំនិតខ្មែរផងស្រេចទៅហើយ សឹងមានពុទ្ធិកមហាវិទ្យាល័យ , ពុទ្ធិកវិទ្យាល័យ សាលាពុទ្ធិកបឋមសិក្សា និងវត្តអារាមគ្រប់ភូមិស្រុកនិងក្រុងជាភស្តុតាង ។ ក្នុងច្បាប់រដ្ឋធម្មនុញ្ញ រដ្ឋបានបញ្ចូលព្រះពុទ្ធសាសនាទៅជាសាសនារបស់រដ្ឋថែមទៀត ។

## គ- សិល្បៈខ្មែរបែបពុទ្ធនិយម

### ១- រូបបដិមា.-

ក- ពុទ្ធរូប.- ពុទ្ធរូបខ្មែរមាន ១០ យ៉ាងដែលហៅថា មុទ្រា : គឺ :

១- សមាធិមុទ្រា ឬឈានមុទ្រា.- ទ្រង់គង់ពត់ព្រះភ្លៅ ព្រះហស្តផ្ងារដាក់ត្រួតលើគ្នា លើព្រះភ្លៅ ។

២- ភូមិសបំមុទ្រ.- ទ្រង់គង់ពត់ព្រះភ្លៅព្រះហស្តស្តាំដាក់លើព្រះជាណុស្តាំ ចុងព្រះហស្ត (ម្រាម ១) ដូចជាចង្អុលទៅរកដី ព្រះហស្តឆ្វេងដាក់ផ្ងារលើព្រះភ្លៅ ។

៣- អភយមុទ្រា.- ទ្រង់ឈរលើកព្រះហស្តទាំងពីរ ចុងព្រះហស្តឡើងជាសញ្ញានៃការប្រទានអភ័យចំពោះសព្វសត្វ ។

៤- ធម្មចក្រមុទ្រា.- ទ្រង់គង់ពត់ព្រះភ្លៅលើកព្រះហស្តទាំងពីរ លាបាតព្រះហស្តស្តាំមកក្រៅ ឆ្វេងចូលក្នុងធ្វើដូចជាកង់ចក្រសញ្ញាធម្មចក្រ ។

៥- បាត្រទានមុទ្រា.- ទ្រង់គង់ឬឈរ (ច្រើនឈរ) ព្រះហស្តទាំងពីរទ្របាត្រ ។

៦- វរមុទ្រា.- ទ្រង់ប្រថាប់ឈរលាព្រះហស្តទាំងពីរទៅមុខ ចុងម្រាមសំយុងរកដី ។

៧- វិតក្កមុទ្រា.- ទ្រង់ប្រថាប់ឈរលាព្រះហស្តទាំងពីរទៅមុខ គាត់ព្រះហស្ត ចង់មកក្ដួចប់នឹងមេព្រះហស្ត ជារង្វង់ ។

៨- ទុក្ករកិរិយាមុទ្រ.- ទ្រង់គង់ពត់ព្រះភ្លៅខ្ជុំ មានឆ្អឹងលេចពីព្រះកាយ ហើយឃើញព្រះកាយស្គាំងស្គម ។

៩- ប្រក់នាគ.- ទ្រង់គង់ដូចសមាធិមុទ្រ មាននាគពែនខ្លួនធ្វើជាបល្ល័ង្កបើក ពពារបាំងពីលើ ។

១០- និព្វានមុទ្រ ឬ សយនាមុទ្រ.- រូបផ្ទំផ្អៀងទៅខាងស្តាំ ព្រះហស្តស្តាំទ្រព្រះកេស ព្រះហស្តឆ្វេងសណ្តូកលើព្រះកាយ ។

ព្រះពុទ្ធរូបប្រក់នាគ ជាពុទ្ធរូបបែបខ្មែរសុទ្ធសាធ ព្រោះមាននៅក្នុងរចនាខ្មែរ មុនរចនាឯទៀតៗ ។

ព្រះពុទ្ធរូបក្នុងសិល្បៈខ្មែរ មានលក្ខណៈគួរកត់សំគាល់ច្រើនបែបគឺ :

- ទ្រង់គង់ពត់ភ្លៅលើបល្ល័ង្ក ឬ ឈរដោយមានផ្កាឈូកទ្រ ហើយឃុំ ឬ គ្រងចីពរ ។
- ព្រះពុទ្ធរូបអង្គខ្លះមានទ្រង់គ្រឿងថែមទៀត ។
- មានព្រះមោលីក្តុប (ទាល ឬ ស្រួច) នៅលើព្រះសិរ ។
- ព្រះកេសារួញខ្មៅ ប្រទក្សិណព្រះកេស ឬ ជាបន្ទាត់ទ្វា ។
- មានព្រះភមទៅផុះទៅប្រជុំចិញ្ចើម ។
- ព្រះកាណ៌វែងជិតធ្លាក់ដល់ស្មា ។
- ព្រះទស្សន៍បែបញញឹម ។

ក្នុងគន្ធូរ - បម្រាក់

- រូបប្រសូតិ មានព្រះនាងសិរីមហាមាយាឈរទាញមែកសាលព្រឹក្ស , ព្រះសិទ្ធត្ថទ្រង់ឈានបាន ៧ ជំហានលើផ្កាឈូក លើកព្រះហស្តស្តាំឡើងលើមានទេវៈបាំងឆ័ត្រ ។

- រូបកុមារវ័យ: គង់លើព្រះភេសកាឡ់ទេវិលថ្មគង់សមាធិក្រោមរុក្ខជាតិ ពេលព្រះបិតានាំទៅច្រត់ព្រះនង្គ័ល ។

- រូបជួបនឹងទេវទូតទាំង ៤: ចាស់ - ឈឺ , ស្លាប់ , អ្នកបួស ។

– រូបចេញសាងព្រះផ្នួស (ច្រើនបែប) តែតែងមានសេះកណ្ឋកៈនិងនាយឆន្នអាមាត្យជាចំបង ។

– រូបកំពុងសាងផ្នួស (សំខាន់គឺកាត់ព្រះកេសា) ។

– រូបធ្វើទុក្ករកិរិយា ។

– រូបទទួលមធុបាយាសពីនាងសុជាតា នៅថ្ងៃត្រាស់ដឹង ។

– រូបផ្ចាញ់មារ ។

– រូបត្រាស់ដឹងក្រោមពោធិព្រឹក្ស ។

– រូបសំដែងធម្មចក្រ មានបញ្ចវគ្គិយនៅជុំវិញ ។

– រូបសំដែងឱវាទបាតិមោក្ខនៅវត្តវេឡុវ័ន ។

– រូបសំដែងព្រះអភិធម្មប្រោសមាតា ។

– រូបចុះពីស្ថានត្រៃត្រិង្ស ។

– រូបប្រោសពុទ្ធបិតា ។

– រូបបរិនិព្វានក្រោមដើមសាលព្រឹក្ស ។ល។ និង ។ល។

ខ– ព្រះចេតិយ - ព្រះស្តូប .– ព្រះស្តូបកន្ធូល (ដូចផ្កាកក្តាប់) ឯព្រះចេតិយ កន្លង់ដូចអគារបារ មានកញ្ចប់បាតាជាទីសំរាប់តំកល់ធាតុ ឬព្រះសារីរិកធាតុ , អរហន្តធាតុ ។ ព្រះចេតិយមាន ៤ បែបគឺ:

១– ធាតុចេតិយ.– សំរាប់ដាក់ធាតុ ។

២– បរិភោគចេតិយ.– សំរាប់ដាក់គ្រឿងប្រើប្រាស់ មានបាត្រចីវររបស់ព្រះពុទ្ធ ។

៣– ធម្មចេតិយ.– សម្រាប់តំកល់ក្បួនខ្នាតគម្ពីរដីកា ដូចជាធម្មមន្ទីរ , ហោត្រៃ ជាដើម ។

៤– ឧទ្ទេសិកចេតិយ.– វិហារសម្រាប់ឧទ្ទិសថ្វាយព្រះពុទ្ធ ឬពុទ្ធរូបផ្សេង ៗ ។

គ– ព្រះវិហារ.– ជាអគារសំរាប់តំកល់ព្រះពុទ្ធរូបនិងសំរាប់ព្រះសង្ឃធ្វើឧបោសថកម្ម , សង្ឃកម្មផ្សេង ៗ ព្រមទាំងសម្រាប់ពុទ្ធបរិស័ទធ្វើបុណ្យទានផ្សេង ៗ ផង ។

ព្រះវិហារនៅតែឋិតនៅកណ្តាលឬផ្នែកខាងចុងនៃគូរត មានជំហូលពីរឬបីជាន់មានកំពូលស្រួច ទៅលើថែមទាំងទៅកើតចាំងរស់ ។ (លើកលែងតែវិហារលើភ្នំបាខែងសង្គមយាចេញ · ដែលថែមទាំងទៅជើងភ្នំនាងដាំនៅផ្សេង១) ។

ឃ– ប្រាសាទ.– គេច្រើនសង់ប្រាសាទបែបពុទ្ធនិយមនៅលើដីកដូចប្រាសាទ ក្នុងរបនាបាយ័ន មានប្រាសាទបាយ័ន, តាព្រហ្ម, បន្ទាយក្តី, ព្រះខ័នជាដើម ។

ង – ពោធិសត្វរូប.– រូបព្រះពោធិសត្វមាន ២ បែប :

១–បែបមហាយាន.– ក្នុងលទ្ធិមហាយាន គេតែងតែគោរពពោធិសត្វ ៣ អង្គគឺ :

ក– អវលោកេស្វរ ឬ អវលោកិតេស្វរៈ.– រូបគង់ឬឈរ លើផ្កាឈូក មានព្រះសិរមួយ ឬច្រើនត្រួតៗលើគ្នា : មានកេតនភណ្ឌជាគ្រឿងសំគាល់គឺ : គម្ពីរ, ខ្សែផ្កា, ថាស, ផ្កាឈូក, ដបទឹកកុណ្ឌី ។

ចំណាំ.– ក្នុងរបនាបាយ័ន មានប្រាសាទបាយ័នជាគោលសំខាន់ ព្រះពោធិសត្វអវលោកិតេស្វរ មានព្រះភក្ត្រ ៤ ហើយគឺជាតួអង្គព្រះជ័យវរ្ម័នទី ៧ នេះតែម្តង បានសេចក្តីថា ព្រះបាទជ័យវរ្ម័នទី ៧ ជាព្រះពោធិសត្វអវលោកិតេស្វរៈ ។

ខ–ម៉ៃត្រីយ.– រូបគង់ពត់ភ្នែន ដូចព្រះពុទ្ធក្នុងបែបសមាធិមុទ្រ តែមានពាក់ម្កុដ និងប្រដាប់អលង្ការ ។ ខ្លះថាជារូបព្រះគោតម កាលនៅជាពោធិសត្វ ។ តែខ្លះថាជាព្រះសិ-អារ្យមេត្រី ។

ចំណែកព្រះពោធិសត្វមញ្ជុស្រី មិនសូវមានក្នុងរបនាខ្មែរទេឡើយ ។ ព្រះពោធិសត្វអវលោ-កិតេស្វរៈត្រូវគេគោរពបូជាច្រើន ។

២–បែបហីនយាន.– ក្នុងលទ្ធិហីនយានមិនសូវមានឃើញរូបពោធិសត្វឡើយ ព្រោះខ្មែរមិនគោរពពោធិសត្វទេ គឺគោរពតែព្រះពុទ្ធនិងព្រះធាតុតាមបែបបុរាណតែម្តង ។

ទេវរូប – ទេវរូបជាទេវបុត្ត ឬ ទេវតាមានគ្រឿងអលង្ការ, ច្រើនជារូបទេពអប្សរៗ

# អក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយម

អក្សរសិល្ប៍បែបពុទ្ធនិយម ជាអត្ថបទរឿងរ៉ាវផ្សេង ៗ ដែលតែងនិពន្ធឡើង ដោយលើកយកទ្រឹស្តីក្នុងពុទ្ធលទ្ធិមកធ្វើជាគោលហើយទ្រឹស្តីទាំងនោះ ស្ថិតនៅក្នុងព្រះត្រៃបិដកផង. ជាពុទ្ធវចនៈសុទ្ធសាធ ។ ប៉ុន្តែអក្សរសិល្ប៍ក្នុងពុទ្ធនិយមនេះមាន ២ ប្រភេទគឺ :

**១- អក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយមពិត ៗ.–** សំដៅយកអក្សរសិល្ប៍ខ្មែរ ដែលនិយាយពីការសាងបារមីនៃព្រះពោធិសត្វដោយត្រឹមត្រូវ បានដល់ទសជាតកគឺ:

| | | |
|---|---|---|
| – តេមិយជាតក | សាង | នេក្ខម្មបារមី |
| – ជនកជាតក | " | វិរិយបារមី |
| – សុវណ្ណសាមជាតក | " | មេត្តាបារមី |
| – នេមិរាជជាតក | " | អធិដ្ឋានបារមី |
| – មហោសថជាតក | " | បញ្ញាបារមី |
| – ភូរិទត្តជាតក | " | សីលបារមី |
| – ចន្ទកុមារជាតក | " | ខន្តិបារមី |
| – នារទជាតក | " | ឧបេក្ខាបារមី |
| – វិធូរជាតក | " | សច្ចបារមី |
| – វេស្សន្តរជាតក | " | ទានបារមី |

**២- អក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយមក្លែងក្លាយ.–** សំដៅយកអក្សរសិល្ប៍ខ្មែរមួយប្រភេទដែលជាសាស្ត្រាល្បែងមានបញ្ញាសជាតក, ដែលនិពន្ធដោយព្រះសង្ឃលាវនៅឈៀងម៉ៃ ហើយបានប្រែដោយអ្នកនិពន្ធខ្មែរជាកំណាព្យខ្មែរ ដូចរឿងព្រះសុធន, ក្រុងសុភមិត្រ, គោតកុលកុមារជាដើម ។ មានរឿងពុទ្ធនិយមក្លែងក្លាយមួយបែបទៀត ពុំមានលក្ខណៈជាពុទ្ធនិយមសោះ ប៉ុន្តែអ្នកនិពន្ធបានដាក់តួអង្គជាពោធិសត្វដែរ ដូចរឿងកាកី, ហង្សយន្ត, ខ្យងសង្ខ, សព្វសិទ្ធិជាដើម ។

## លក្ខណៈនិពន្ធអក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយម

១– ផ្ដើមរឿង.– មានធ្វើវន្ទនមស្ការព្រះរតនត្រ័យជាមុន ។

២– សាច់រឿង.–

ក– តួអង្គ.– ប្រុសជាពោធិសត្វ, ស្រីជាកញ្ញាសារពេជ្ញ ។ តួរាយរង មាន មនុស្ស, ទេវៈ, អសុរ ។

ខ– ទីកន្លែង.– នគរពារាណសី, សាវត្ថី, រាជគ្រឹះ, តក្កសិលា, ព្រៃហេមពាន្ត ។ល។

គ– បញ្ហាចោទ.– ជាទំនាស់រវាងព្រះពោធិសត្វនិងសង្គមមនុស្ស, ទំនៀមទំលាប់, តម្រៀវ ។

ឃ– បញ្ហាដោះស្រាយ.– ព្យាយាមតស៊ូប្រឹងប្រែង និងយកសីលធម៌ទៅអប់រំដោយសន្តិវិធី ។

ង– ស្នេហា.– គឺស្នេហារវាងពោធិសត្វ និង បារមី, ពោធិសត្វ និង កញ្ញាសារពេជ្ញ ជាស្នេហាបរិសុទ្ធ ។

ច– កំសត់.– កើតឡើងដោយការព្រាត់ប្រាស ព្រោះសង្គមមនុស្ស - ទំនៀមទម្លាប់ - ពៀរវេរ ។

ឆ– ឧត្ដមគតិ.– អប់រំមនុស្សឲ្យស្គាល់បុណ្យបាប, ឲ្យធ្វើល្អ, ឲ្យប្រឹងតស៊ូព្យាយាម ។

៣– បញ្ចប់រឿង.– មានការសរជាតិ គឺតួអង្គល្អ ជាពោធិសត្វនិងកញ្ញាសារពេជ្ញ ឯតួអង្គអាក្រក់ជាទេវទត្ត, នាងចិញ្ចា ។ល។

## ប្រពៃណី-ទំនៀមទម្លាប់ខ្មែរបែបពុទ្ធនិយម

លទ្ធិពុទ្ធនិយមបានជ្រួតជ្រាប ចាក់ឫសយ៉ាងជ្រៅណាស់មកក្នុងប្រពៃណី - ទំនៀមទ ខ្មែរ ។ នៅក្នុងពិធីផ្សេងៗ ដែលជាប្រពៃណីខ្មែរ ដូចប្រកាន់ប្រសិទ្ធិការផ្ទុកកូន, ឡើងផ្ទះ,

ចេញម្លប់កូនស្រី, រៀបអាពាហ៍ពិពាហ៍កូនប្រុសស្រី, ឡើងអ្នកតា, ចូលឆ្នាំថ្មី ជាដើម ប្រជាជនខ្មែរ តែងប្រារព្ធធ្វើដោយយកពិធីក្នុងពុទ្ធនិយមមកធ្វើជាមួយផងគឺ និមន្តព្រះសង្ឃចំរើនព្រះបរិត្ត បាចទឹកម្ចាប់ចាស្រ្ត, ទេសនាក្នុងពេលយប់ ព្រឹកឡើងនិមន្តព្រះសង្ឃបិណ្ឌបាត្រ, ទទួលភត្ត ។

បើក្នុងពិធីបុណ្យ ជាប្រពៃណីក្នុងព្រះពុទ្ធសាសនា ដូចបុណ្យចូលវស្សា, ចេញវស្សា, កឋិនទាន, មាឃបូជា, វិសាខបូជា ជាដើម ខ្មែរបានធ្វើទៅជាទំនៀមទម្លាប់របស់ខ្លួនដោយមានបញ្ចូលការកំសាន្តសប្បាយជាមួយផង ។

ឯក្រៅពីនេះ ក្នុងពិធីបុណ្យអភិសេក, លើកសព, បូជាសព, ឆាក, បង្សុកូល, វេរភត្ត, កតញ្ញូ, បច្ច័យ ៤ ជាដើម ខ្មែរបានធ្វើតាមទំនៀមទម្លាប់ផង តាមប្រពៃណីព្រះពុទ្ធសាសនាផង (ហើយពិធីខ្លះបានយកលទ្ធិព្រាហ្មណ៍មកបញ្ចូលជាមួយផង) ។

## វប្បធម៌ខ្មែរផ្នែកភាសា-ពាក្យពេចន៍ក្នុងព្រាហ្មណ៍និយមនិងពុទ្ធនិយម

តាមរយៈសាសនាពីរគឺ សាសនាព្រាហ្មណ៍និងពុទ្ធសាសនា ដែលធ្លាប់បានផ្សាយមកក្នុងសង្គមខ្មែរ ខ្មែរបានទទួលវប្បធម៌ផ្នែកភាសា - ពាក្យពេចន៍ពីរបែបគឺ:

**១- ភាសាសំស្ក្រឹត.-** ក្នុងអក្សរសិល្ប៍បែបព្រាហ្មណ៍និយម ខ្មែរមានប្រើភាសាសំស្ក្រឹតយ៉ាងច្រើន ។ ក្នុងសិលាចារឹក នៅសម័យដែលសាសនាព្រាហ្មណ៍លូតលាស់ខ្លាំង (ពីសតវត្សទី ៨ ដល់ទី ១៣) មានចារជាភាសាខ្មែរបូរាណផង ភាសាសំស្ក្រឹតផង ហើយភាសាខ្មែរនឹងភាសាសំស្ក្រឹត ។

**២- ភាសាបាលី.-** ក្នុងអក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយម មានប្រើភាសាបាលីយ៉ាងច្រើន ។ ចំណែកព្រះត្រៃបិដក គេឃើញមាននៅក្នុងអត្ថបទផ្សេងៗ ជាអត្ថកថា ឬ ជារឿងកំរ ជាភាសាខ្មែរ មានពាក្យបាលីយ៉ាងច្រើននៅពាសពេញ លាយឡំនឹងភាសាខ្មែរ ហើយភាសាបាលី ខ្មែរទុកជាភាសាសំខាន់ក្នុងសតវត្សទី ១៣ ដល់សព្វថ្ងៃ ។

## យោបល់រួមចំពោះលទ្ធិពុទ្ធនិយម.-

រួចមកហើយនេះ យើងបានឃើញថាលទ្ធិពុទ្ធនិយម បានជ្រួតជ្រាបចាក់ឫសគល់យ៉ាងខ្លាំង

ចាក់ក្នុងវប្បធម៌ខ្មែរ ហើយសន្ទុះនៃកម្លាំងនេះ បានដក់ជាប់ក្នុងចិត្តគំនិតខ្មែរ ៩៥ ភាគរយថែមទៀត ដែលមិនអាចនឹងមានឥទ្ធិពលនៃសាសនា ឬ លទ្ធិណាមកប្រណាំងប្រជែងបានឡើយ ។ ខ្មែរបានយកព្រះពុទ្ធសាសនា ដ៏មានសរណៈ៣ គឺៈ ព្រះពុទ្ធ, ព្រះធម៌, ព្រះសង្ឃ ទុកជាទីពឹង រំលឹកស្មើជីវិត ។

## ខ្មែរនិយម

ចំពោះបញ្ហាខ្មែរនិយម ក្នុងន័យនៃខ្លួនជាខ្មែរស្រេចទៅហើយនេះ យើងអាចមើលឃើញ ដោយខ្លួនឯងបានគឺៈ

**១– សង្គមកិច្ច.–** ខ្មែរបានរៀបចំសង្គមកិច្ច ស្របទៅតាមពុទ្ធលទ្ធិដោយច្រើន ដែលមានលក្ខណៈជាការសង្គ្រោះតាមបែបមនុស្សធម៌. តាមបែបបែកខាង និងតាមចំណង់ចិត្ត ។

**២– សិល្បៈ.–** ក្នុងផ្នែកសិល្បៈ (ចម្លាក់ក្បាច់ចេតនា, តន្ត្រី, របាំ, ចម្រៀង) ខ្មែរមានលក្ខណៈមួយសម្រាប់ជាតិខ្លួន គ្រប់សិល្បៈមានបែបទំនង មានដើម, កណ្តាលនិងចុង ។ ក្នុងសិល្បៈចម្លាក់ ចាប់ពីបុរាណសម័យព្រះគោមក ខ្មែរមានលក្ខណៈមួយដោយឡែក គ្រប់កាលល្អស ល្អន់ ហើយទឹកមុខខ្មែរ លើផ្ទាំងថ្មក្នុងប្រាសាទបុរាណ គឺជាការញញឹមពព្រាយ ហើយមានជម្រៅ វិជ្ជាខ្ពស់បំផុត ។ រហូតមកដល់បច្ចុប្បន្នកាល សិល្បៈខ្មែរគ្រប់ផ្នែក នៅតែរក្សាលក្ខណៈខ្លួនជាប្រពៃណីជាតិមួយ មានវិជ្ជានិងគំនិតខ្ពស់ជានិច្ច ។

**៣– អក្សរសិល្ប៍.–** ឥណ្ឌាចូលចិត្តតែអ្វី ដែលជាអរូប, ផុតពិស្ស័យមនុស្ស, សាសនា ឯអក្សរសិល្ប៍ខ្មែរ បានកាត់បំបែកអរូប ផុតពិស្ស័យ-សាសនានេះ មកជាបញ្ហា បច្ចុប្បន្នភាព ទៅវិញ ដូចក្នុងរឿងរាមកេរ្តិ៍ ខ្មែរកែងតែចូលចិត្តរឿងអំពីមនុស្ស ឲ្យច្រើនប្រែងចៀរ ការនិទានក្នុងបច្ចុប្បន្ន ដើម្បីប្រយោជន៍បច្ចុប្បន្ន ឃើញជាក់ស្តែងនឹងភ្នែក ។ ក្នុងពាក្យខ្មែរសាមញ្ញ ខ្មែរនិយាយថា «កើស៊ី» ជាការបញ្ជាក់ថា ខ្មែរចូលចិត្តតែអ្វីដែលនាប់-ជាក់ស្តែងភ្លាមៗ ។

នៅក្នុងរឿងកេរ្តិ៍ខ្មែរក្តី, មហាវេស្សន្តរជាតកបែបខ្មែរក្តី ខ្មែរច្រើនតាញទេវភាព ពោធិសត្វភាព របស់ព្រះរាម-ព្រះវេស្សន្តរពីអាទិទេព, ពោធិសត្វអគ្គប្រាជ្ញានិព្វាន មកជាមនុស្ស

សាបញ្ញ ជាមនុស្សរស់នៅដោយភាពកាចសាហាវ, ឆាប់ខឹង, សាហាវ ដែលពេលស្រឡាញ់ប្រពន្ធកូន, ដែលជាប់ទ្រព្យច្រើន, មានកំហឹង ហើយត្រូវបានបោះបង់ចោលក្នុងស្រុកមជ្ឈិមទៀត ។ ពាណិជ្ជករក៏មានប្រាក់ច្រើន ហើយឱ្យព្រះលក្ខណ៍ដល់ព្រះសង្ឃ, ព្រាហ្មណ៍ មួយចំនួន; ព្រះសង្ឃប្រកាន់ចំណុះជាមួយ ពេលឃើញខ្ញុំដកខ្លួនចេញទៅ, ព្រះសង្ឃសុំកាតព្វកិច្ច ដើម្បីបានទៅសោយភពសម្បត្តិញជាដើម ។

៣- កិច្ចប្រតិបត្តិ-ជំនឿ.- ខ្មែរមានការប្រតិបត្តិដែលតែងមាន, មានជំនឿ ជាលេខ្មែរ ដីជឿដោយស្រឡាញ់ផ្ទាល់ខ្លួន ចំណែកខ្មែរមានការប្រតិបត្តិស្របតាមនិស្ស័យលក្ខណៈ ខ្លួនឯង តាមក៏រតដើមកាល (ប្រតិបត្តិតាមដើមកាលនៃបូរាណ ក៏មាន) ហើយជឿតាមមើល តាមការពិចារណា ហើយមានលក្ខណៈជាលោកិយសម្បូរទៀត ។

៤- ចរិតចិត្ត.- ទំពចិត្តខ្មែរ មនុស្សជាតិហេតុ ក្នុងលទ្ធិព្រាហ្មណ៍ក៏ដូចក្នុង លទ្ធិ ឯខ្មែរមានទំពចិត្តជាមនុស្សតែមួយ ដែលហៅថា „សម្របនិយម„ តាមការគោរព តាមសន្តិយបរិយាកាសៈ ។ល។

រូបភាពអស់នេះមក ខ្មែរយើង ស្ថិតនៅលើលោកិយនិយមផង លើមនុស្សនិយមផង ក៏ ប៉ុន្តែដោយការលក្ខណៈជាលោកិយនិយម ដែលអាចមើលឃើញ ហើយតែងតែខ្លួនទៅលើ សមត្ថភាពមនុស្សទាំងអស់ បញ្ហាព្រហ្មណ៍ ឬ សត្វ ដីភាព ជាបញ្ហាទី ២ ឬ បញ្ហាក្រោយ ដែលជា លោកិយ ជាបែបមនុស្សនិយម គឺជាបញ្ហាទី១ ហើយជាបញ្ហាផ្ទាល់ ។

## បរលោកនិយម

ជនជាតិខ្មែរពលរដ្ឋ ខ្មែរបានទទួលឥទ្ធិពលនៃវប្បធម៌ខាងលិចមួយទៀតពីប្រទេស គឺគន្ថិ ការផ្តួចផ្តើម ជាពិសេសពីប្រទេសបារាំង ដែលចូលមកកាន់ខ្មែរ ក្នុងសម័យអាណានិគម ។ ពីសម័យមុន ខ្មែរមានគន្ថិការផ្តួចផ្តើមកុលាការដែរ ប៉ុន្តែជាបៀបចាស់ លុះបារាំងបានចូលមកមានការទាក់ទង ជាមួយខ្មែរ ១ បានរៀបចំគន្ថិការ ៣ ស្របទៅតាមបរលោកនិយមគឺ :

១- អត្តការទើតបញ្ញត្តិ.— ខ្មែរបានរៀបចំតាក់តែងរដ្ឋធម្មនុញ្ញ , ឲ្យមានរបៀប

កំណាព្យនិពន្ធ , មានគណៈបក្ស , មានវេទិកា តាមលទ្ធិប្រជាធិបតេយ្យ ។

២- អង្គការនីតិប្រតិបត្តិ.- មានការរៀបចំរដ្ឋាភិបាល ដោយមានគណៈរដ្ឋមន្ត្រី ទទួលខុសត្រូវអំណាចពីរដ្ឋសភាមកបានតែងការងារតាមក្រសួង ។

៣- អង្គការតុលាការ.- ខ្មែរបានរៀបចំតុលាការតាមបែបសម័យថ្មី តែក្នុងនាមនៃព្រះមហាក្សត្រ ។

ដោយពីរបៀបនិងចំណុច ៣ ដ៏សំខាន់ ៗ សំរាប់រដ្ឋបាលនេះ ខ្មែរបានទទួលការរីកចំរើនផ្សេង ៗ យ៉ាងច្រើន ជាពិសេសក្នុងវិទ្យាសាស្ត្រ សម័យទំនើប ។

## ៣- យោបល់បញ្ចប់

### តម្លៃនៃវប្បធម៌ខ្មែរក្នុងក្របខណ្ឌអរិយធម៌ពិភពលោក

ជាការពិតមួយដែលគេប្រកែកបាន ខ្មែរមានវប្បធម៌មួយសំរាប់ជាតិសាសន៍ ដែលកើតតាំងពីដើម ដោយដើមកំណើត និងជំនឿរបស់ខ្លួនតាំងពីបុរេប្រវត្តិសាស្ត្រមកម្ល៉េះ ហើយតមក ខ្មែរបានទទួលវប្បធម៌ឥណ្ឌាពីរ តាមរយៈសាសនាព្រាហ្មណ៍ និងពុទ្ធសាសនាថែមទៀត ដោយវប្បធម៌នេះបានរីកលូតលាស់យ៉ាងល្អលើគំនិតខ្មែរ និងដោយវប្បធម៌ឥណ្ឌា មានលក្ខណៈស្របស្រួលនឹងចិត្តខ្មែរ ដែលខ្មែរបានទទួលយកបានល្អ ប៉ុន្តែទោះយ៉ាងនេះក្តី គឺខ្មែរពុំបានទុកខ្លួនជាអ្នកទទួល គេថា , រូបរាងនៃវប្បធម៌ឥណ្ឌាតាំងស្រុងនៅក្នុងវប្បធម៌ខ្មែរទេ គឺខ្មែរបានផ្លាស់ប្តូរវប្បធម៌ឥណ្ឌាឲ្យមានលក្ខណៈជាខ្មែរស្របតាមចំណង់ចំណូលចិត្តរបស់ខ្លួនតាំងពីសាសនា , សិល្បៈ, អក្សរសិល្ប៍, ប្រពៃណី ទំនៀមទំលាប់,ភាសានិងអ្វីៗ ផ្សេងទៀត ដែលវប្បធម៌ឥណ្ឌាបានក្លាយជាវប្បធម៌ខ្មែរទៅវិញ ។

តាមធម្មតា វប្បធម៌នៃជនជាតិនីមួយ ៗ តែងទទួលឥទ្ធិពលគ្នាពីជាតិមួយទៅជាតិមួយជាធម្មតា ដូចវប្បធម៌ថៃនិងឡាវ បានទទួលឥទ្ធិពលពីខ្មែរយើងទៅស្ទើរតែទាំងអស់ ប៉ុន្តែជនជាតិថៃបានកែច្នៃវប្បធម៌នេះ ទៅតាមចំណង់ចំណូលចិត្តរបស់គេរៀងៗទៅ ។ វប្បធម៌ខ្មែរសម័យមហានគរ បានឡើងដល់កំពូលយ៉ាងខ្ពស់ក្នុងតំបន់ឥណ្ឌូចិន ហើយវប្បធម៌នេះបានជះឥទ្ធិពលទៅលើប្រទេសជិតខាង

យ៉ាងឆ្ងាញ់ថែមទៀតដូចលា, ឃ្មុំ, ស្វាណាស៊ុំជាដើម ។

នៅក្នុងក្របខ័ណ្ឌនៃអរិយធម៌ពិភពលោកវប្បធម៌ខ្មែរចាត់ទុកជាកេតនភណ្ឌមួយសម្រាប់មនុស្សជាតិផ្សេងទៀត ព្រោះដូចយ៉ាងអង្គរវត្តជាដើម មនុស្សក្នុងពិភពលោកតែងស្ងើចសរសើរនិងឲ្យតម្លៃរហូតមិនអាចកាត់បាន : ពួកទេសចរ បានចំណាយប្រាក់យ៉ាងច្រើន ដើម្បីមកទស្សនាប្រាសាទអង្គរឲ្យបានឃើញផ្ទាល់ភ្នែក ។ ដទៃពីនេះវប្បធម៌ផ្នែកសិល្បៈ, របាំ, ភ្លេង, អក្សរសិល្ប៍, ភាសា, ប្រពៃណី, ទំនៀមទំលាប់ និងផ្នែកផ្សេងៗ ទៀត ក៏លេចមុខមាត់មានតម្លៃក្នុងផ្ទៃអន្តរជាតិដែរ ។

× × ×

# តែងសេចក្ដីគម្រូ

## សម្រាប់ថ្នាក់ទីបញ្ចប់

ប្រធានទី ១ .– បញ្ហាកើតស្លាប់នៃមនុស្សនៅក្នុងពុទ្ធនិយមនិងនៅក្នុងព្រាហ្មណ៍និយម ។

ប្រឡងឧត្ដមសិក្សាប័ត្រភាគទី២
ថ្ងៃ ២២ - ៦ - ៧១
ផ្នែកទស្សនវិជ្ជា

## អត្ថាធិប្បាយ

លទ្ធិពុទ្ធនិយមក៏ដូចលទ្ធិព្រាហ្មណ៍និយមដែរ សុទ្ធតែបានបញ្ចេញទស្សនៈទ្រឹស្ដីពន្យល់ដោះស្រាយនូវបញ្ហារបស់មនុស្ស ពិសេសគឺបញ្ហាកើតស្លាប់នេះដូចគ្នា ។ ប៉ុន្តែតើបញ្ហាកើតស្លាប់នៅក្នុងពុទ្ធនិយមនិងក្នុងព្រាហ្មណ៍និយមមានលក្ខណៈស្របគ្នាដែរឬទេ ?

បញ្ហាកើតស្លាប់នៃមនុស្សដែលជាការៈនៅក្នុងលទ្ធិទាំងពីរ ត្រូវបានទទួលការ[illegible] ដូចគ្នាឡើយ ។ យ៉ាងណាមិញ ;

ក– បញ្ហាកើតស្លាប់ក្នុងពុទ្ធនិយម.– ការៈទាំងអស់សុទ្ធតែរួមផ្សំឡើងពី[illegible] បរមាណូធាតុ គឺកើតដោយទឹកដីភ្លើងខ្យល់ហើយធាតុទាំង៤នេះផ្សំគ្នាកើតជាធម្មជាតិ ៖ មនុស្ស , សត្វ-រុក្ខជាតិ , ទៅៈផ្សេង ៗ ទៀត គ្មានការៈណាកើតដោយគ្មានការផ្សំធាតុនោះឡើយ ។ ធម្មជាតិមានមនុស្សជាដើមនេះ គឺជាផលនៃសង្ខតធាតុ មានរូប , វេទនា , សញ្ញា , សង្ខារ , វិញ្ញាណដែលជាខន្ធ ៥ នេះឯង ។

សង្ខតធាតុទាំងអស់នេះ កាលណាមានហើយក៏តែងស្ថិតនៅក្នុងអំណាចនៃបច្ច័យធម្មជាតិក្នុងលក្ខណៈទូទៅ ៣ យ៉ាងគឺ អនិច្ចំ , ទុក្ខំ , អនត្តាដែលជាសភាពមិនទៀង , ជាទុក្ខ មិនមែន[illegible] ជារបស់ព្រហ្មណាម្នាក់ឯង មានតែព្រះនិព្វានមួយប៉ុណ្ណោះ ដែលមិនស្ថិតនៅក្នុងអំណាចនៃ[illegible]ច្ច័យធម្មជាតិ ។ ការបែកធ្លាយនៃខន្ធនេះហៅថា ស្លាប់ ។ កាលណាមានខន្ធដោយការរួមផ្សំនៃ[illegible]ធាតុហើយ ក៏តែងតែបែកធ្លាយទៅវិញជានិច្ច ។ ដរាបណានៅមានកិលេសតណ្ហាដែលធាតុ

តាមគាត់តែងបាន ដរាបនោះ តែងតែមានបញ្ហាកើតស្លាប់នេះជាដរាប ។

ខ- បញ្ហាកើតស្លាប់ក្នុងព្រាហ្មណ៍និយម .— ផ្ទុយទៅវិញ នៅក្នុងព្រាហ្មណ៍និយម, ការៈទាំងអស់កើតដោយសារធាតុទឹកដី, ភ្លើងខ្យល់ និងអាត្ម័នទៅវិញ ។ របស់មនុស្ស, សត្វ ដែលជាទឹកដីភ្លើងខ្យល់នេះ ជាអនិច្ច តែងបែកធ្លាយទៅ ប៉ុន្តែអាត្ម័ន ដែលយើងហៅជាព្រលឹង ឬ ក្នុងពុទ្ធសាសនាហៅថា "វិញ្ញាណ" នោះ ពុំចេះបែកធ្លាយទេ ។ ការដែលជាសមូហភាពនៃទឹកដីភ្លើងខ្យល់នេះ ជាអំណោយនៃអាទិទេព គឺសុទ្ធតែអាទិទេពបង្កើតឡើងទាំងអស់ ។

តាមទស្សនៈទាំងពីរខាងលើ យើងអាចយល់បានថា បញ្ហាកើតស្លាប់ក្នុងពុទ្ធនិយមបានពន្យល់ថា ការៈជាសង្ខតធាតុ កាលណាកើតឡើងហើយ ក៏តែងបែកធ្លាយរលត់ទៅវិញទាំងអស់ ទាំងវិញ្ញាណ ក៏រលត់ដែរ ឯក្នុងព្រាហ្មណ៍និយមវិញ បានពន្យល់ថា ការៈទាំងអស់ ក្រៅពីអាទិទេពនិងអាត្ម័នចេញ សុទ្ធតែអាទិទេពបង្កើត ហើយការៈទាំងនោះរួមទាំងអាត្ម័នផង បើបែកធ្លាយទៅ អាត្ម័នពុំបានបែកធ្លាយទៅជាមួយឡើយ ។

ដូច្នេះចំពោះបញ្ហាកើតស្លាប់នេះ ពុំមានការស្របគ្នាទេ នៅក្នុងពុទ្ធនិយមនិងព្រាហ្មណ៍និយម ហើយតាមទស្សនៈព្រាហ្មណ៍និយម គេតែងជឿថាកាលណាមនុស្សស្លាប់ទៅនៅសល់អាត្ម័ន ឬព្រលឹងវិញ្ញាណនេះ ទៅលងញាតិធ្វើជាខ្មោចបិសាចតាមព្រាយ ឬទៅចាប់ជាតិកំណើតថ្មីទៀត ។

× × ×

ប្រធានទី ២.- ចូរធ្វើអត្ថាធិប្បាយ អំពីព្រះវិស្ណុនៅក្នុងសាសនាព្រាហ្មណ៍ ។ តាមការអធិប្បាយរួចមកហើយនោះ តើសិស្សអ្នកយល់ថា អាទិទេពនៅក្នុងសាសនាព្រាហ្មណ៍ ពិតជាមានឥទ្ធិពល អាចផ្ដល់នូវសេចក្ដីសុខ ឲ្យដល់មនុស្សដែរ ឬទេ? ព្រោះអ្វី ?

ប្រឡងឆមាសលើកទី ២
ថ្ងៃ ២២ - ៦ - ១៩៧១
ផ្នែកវិទ្យាសាស្ត្រពិសោធន៍និងគណិតវិទ្យា

# អត្ថាធិប្បាយ

នៅក្នុងសាសនាព្រាហ្មណ៍ ព្រះវិស្ណុជាអាទិទេពមួយអង្គយ៉ាងសំខាន់ក្នុងចំណោមអាទិទេពទាំងឡាយអង្គ ៗ ប៉ុន្តែតើអាទិទេព ដូចព្រះវិស្ណុជាដើមនេះ អាចផ្តល់សេចក្តីសុខឲ្យមនុស្សដែរ ឬមិនអាចផ្តល់ទេ?

ព្រះវិស្ណុ ឬ ព្រះនារាយណ៍ ជាអ្នកថែរក្សាមនុស្សផង សត្វមនុស្សផង ៗ ពួកប្រជាជនឥណ្ឌាកាន់ខាងក្បួនតែងគោរពព្រះវិស្ណុនេះណាស់ ព្រោះគេយល់ថា ព្រះវិស្ណុជាតំណាងនៃជាតិមិលក្ខៈ ដែលជាម្ចាស់ដើមនៃទឹកដីឥណ្ឌា ៗ

ក្នុងលទ្ធិព្រាហ្មណ៍និយម ព្រះវិស្ណុមាននាទីជាអ្នកថែរក្សាគ្រប់គ្រងមនុស្សលោក ហើយជាអ្នកផ្តល់សេចក្តីសុខឲ្យមនុស្សផង ៗ យ៉ាងណាមិញ យើងបានឃើញហើយថា ព្រះវិស្ណុបានថែងការចុះមកយកកំណើតក្នុងមនុស្សលោកចំនួន ១០ លើកហៅថា ទសាវតារ ដើម្បីជួយស្រោចស្រង់ពិភពលោក រំដោះការពារមនុស្សលោកឲ្យរួចពីគ្រោះថ្នាក់ច្រើនយ៉ាង ៗ នៅក្នុងសិល្បៈខ្មែរមានរូបមួយនៅក្នុងប្រាសាទមេបុណ្យខាងលិច (កណ្តាលបារាយណ៍ទឹកថ្លា) គឺរូបព្រះវិស្ណុផ្ទំផ្អៀងដើម្បីគិតរំពឹងគមនោបាយថែរក្សាការពារមនុស្សលោក ៗ ប៉ុន្តែ តើយើងអាចយល់បានថា តើអាទិទេពដូចយ៉ាងព្រះវិស្ណុនេះ អាចផ្តល់សេចក្តីសុខឲ្យមនុស្សបានមែនឬមិនបាន ?

តាមពិត យើងយល់ថាមិនបានទេហើយយើងមិនបាច់និយាយពីទ្រឹស្តីកម្មផល តាមពុទ្ធ[illegible]នៈ ក្នុងលទ្ធិពុទ្ធសាសនាទេ យើងនិយាយតែតាមលទ្ធិអាត្មន័និងកម្ម ក្នុងលទ្ធិព្រាហ្មណ៍និយមប៉ុណ្ណឹងឯង ៗ នៅក្នុងលទ្ធិព្រាហ្មណ៍ គេតែងយល់ថា មនុស្សកើតឡើងដោយសារអាទិទេព កាលស្លាប់ទៅអាត្មន់ពុំដាច់សាបទេ គឺបើកាលធ្វើល្អអាត្មន់នឹងទៅជួបព្រហ្មន៍ បាននូវលុបបរិបុណ្ណសុខ បើមិនបានធ្វើល្អមិនប្រព្រឹត្តធម៌នឹងលោកនេះទេ អាត្មន់នឹងទទួលទុក្ខវិលវល់កើតស្លាប់ក្នុងសំសារនេះឯង ៗ ក្នុងនាទីនេះ យើងយល់ថា បើរូបកាយនៃមនុស្សជាតំណាងនៃអាទិទេព, អាត្មន់ក៏ផ្តាច់ខ្លួនចេញពីអាទិទេពមកស្ថិតនៅជាមួយការៈជាមនុស្សម្នាក់នេះដែរ ម្តេចក៏អាទិទេពមិនព្រមធ្វើការៈនោះឲ្យល្អ[illegible]ទៅ? ម្តេចក៏បណ្តោយឲ្យមានអាក្រក់ ហើយផ្តល់សេចក្តីទុក្ខឲ្យការៈទៅវិញ? ហើយម្ល៉េះ[illegible] អាទិទេព

ដ៏មួយមានសមត្ថភាព អាចបង្កើតការៈបានដូច្នេះ ម្តេចក៏មិនផ្តល់សុខនូវសេចក្តីសុខឲ្យគេ ? ត្រង់យើងឃើញថា អាទិទេពគ្មានសមត្ថភាពអាចផ្តល់សេចក្តីសុខឲ្យមនុស្សឡើយ បើមានសមត្ថភាពដូច្នោះមែន ការៈជារបស់ខ្លួនទៅហើយ មុខជាអាចផ្តល់សុខមិនខាន ដូចម្តាយឪពុកដែលមានសមត្ថភាពបង្កើតកូនប្រុសស្រី ហើយពិតជាមានសមត្ថភាពស្តីប្រដៅ អប់រំ ការពារ មិនបង់ឲ្យកូនធ្វើអាក្រក់ឡើយ ។ ឯសមត្ថភាពអាទិទេព ក៏រឹតតែមានប្រសិទ្ធិភាពណាស់ទៅទៀត ។

ទោះបីអាទិទេព នៅក្នុងសាសនាព្រាហ្មណ៍មាននាទីជាអ្នកថែរក្សាលោក តាមទស្សនៈពួកព្រាហ្មណ៍ បែបណាក៏ដោយ ក៏នៅក្នុងទស្សនៈខ្ញុំឯងដែលនេះ ពុំអាចដោះស្រាយបញ្ហាខ្លួនឯងរួច ត្រង់ឲ្យមានការៈផង មានកត្តិផង ហើយបែរជាគ្មានអំណាចការពារ... ក្នុងនោះ ឲ្យប្រព្រឹត្តនៃអំពើល្អ ដើម្បីទៅជួបព្រហ្មវិញ និងទទួលបរមសុខ នោះឯង ។

\+ + +

ប្រធានទី ៣.– គេថា វប្បធម៌ខ្មែរ គឺវប្បធម៌ឥណ្ឌា ។ ចំពោះគំនោលនេះ តើអ្នកមានទស្សនៈយ៉ាងណាដែរ ? ចូរធ្វើអត្ថាធិប្បាយ ។

សែម-ស្វរ

## អត្ថាធិប្បាយ

ខ្មែរពិតជាបានទទួលវប្បធម៌មួយផ្នែកធំពីឥណ្ឌាដោយឥតប្រកែកបាន ជាពិសេសគឺសាសនា, អក្សរសិល្ប៍, ភាសានេះឯង ។ ប៉ុន្តែតើការទទួលយកមកនេះ ខ្មែរទុករបស់ឥណ្ឌានោះឲ្យនៅជាលក្ខណៈឥណ្ឌាតាំងស្រុង ឬខ្មែរធ្វើជាទេសរើសយកមកឲ្យមានលក្ខណៈជាខ្មែររស់ទៅហើយ ?

យើងទទួលយកវប្បធម៌ឥណ្ឌាមកបញ្ចូលក្នុងវប្បធម៌យើងមែន ព្រោះវប្បធម៌នេះចូលមកស្រុកខ្មែរយើងមុនគេ និងមានលក្ខណៈ ស្របស្រួលដែលខ្មែរអាចទទួលយកបានផង ។ ឧទាហរណ៍ៈ

– ក្នុងសិល្បៈ ខ្មែរទទួលយកតាមបែបឥណ្ឌាក្នុងសម័យមុនអង្គរនិងសម័យអន្តរៈ ដូចជា

ទៅតាមគំរូប្រាសាទ , រូបចម្លាក់ មានកាច់ចង្កេះ , ការសាងប្រាសាទ ដើម្បីថ្វាយអាទិទេព ។ល។

— ក្នុងអក្សរសិល្ប៍ ខ្មែរទទួលយកតាមរយៈសាសនាពីរ គឺព្រាហ្មណ៍សាសនា និងពុទ្ធសាសនានូវអត្ថបទរឿងរាមកេរ្តិ៍ , មហាភារតយុទ្ធ , រាមាយណ , ទសជាតក៍ជាដើម ព្រមទាំងឈ្មោះទីកន្លែងភូមិ និងគោលសំខាន់ៗ ។

— ក្នុងភាសា គឺខ្មែរទទួលយកភាសាពីរគឺបាលី និងសំស្ក្រឹតផង ។

— ឯក្នុងសាសនា គឺខ្មែរទទួលយកពីឥណ្ឌានូវសាសនាពីរ គឺព្រាហ្មណ៍សាសនា និងពុទ្ធសាសនាផង ។

ប៉ុន្តែតើវប្បធម៌ទាំងអស់នេះ ដែលខ្មែរយកមកបញ្ចូលក្នុងវប្បធម៌របស់ខ្លួន តើខ្មែរទុកឲ្យនៅជាលក្ខណៈឥណ្ឌាទាំងស្រុងឬ ? តាមពិតខ្មែរទទួលយកពីឥណ្ឌាមែន តែខ្មែរបានបនាកែច្នៃកែឲ្យមានលក្ខណៈជាខ្មែរស្របតាមទំនោរចំណង់ចិត្តរបស់ខ្លួនអស់ទៅហើយ បានសេចក្តីថា ខ្មែរពុំបានទុកវប្បធម៌ឥណ្ឌាទាំងស្រុងឲ្យនៅក្នុងវប្បធម៌ខ្មែរទេ ។ យ៉ាងណាមិញ :

— ក្នុងសិល្បៈ រូបចម្លាក់ដែលកាច់ចង្កេះក្នុងសិល្បៈឥណ្ឌា ខ្មែរបែបនាំឲ្យមានដងខ្លួនត្រង់ , ហើយប្រាសាទដែលគេសាងថ្វាយអាទិទេពនោះ ខ្មែរបានធ្វើឲ្យទៅជាទីសក្ការបូជាសម្រាប់បុព្វបុរសទៅវិញ ដូចយ៉ាងប្រាសាទភ្នំបាខែង ខ្មែរសាងទុកជានិមិត្តរូបនៃពិភពលោកផង ទុកជានិមិត្តរូបនៃស្ថានព្រះត្រៃត្រឹង្សផង និងជាប្រក្រតិទិនប្រចាំឆ្នាំសំរាប់ខ្មែរផង ។ រូបព្រះពោធិសត្វអវលោកិតេស្វរៈ ខ្មែរធ្វើឲ្យមានមុខ ៤ តំណាងព្រះបាទជ័យវរ្ម័នទី ៧ ដែលបានព្រហ្មវិហារធម៌ទៅគ្រប់ទិសទាំង ៤ ចំពោះប្រជារាស្ត្រផង ។ មិនតែប៉ុណ្ណោះ ដូចយ៉ាងក្បាច់ផ្កាប្រាក់ជាសិល្បៈខ្មែរយ៉ាងស្រស់ស្អាតក្រោះក្បាច់បែបនេះ មាននៅតែក្នុងសិល្បៈខ្មែរតែប៉ុណ្ណោះ តែគ្មានក្នុងសិល្បៈឥណ្ឌាទេ ។

— ក្នុងអក្សរសិល្ប៍ ខ្មែរបានបនាអក្សរសិល្ប៍ពីរឿងព្រាហ្មណ៍និយម និងពុទ្ធនិយមឲ្យមានលក្ខណៈជាខ្មែរទាំងអស់ គឺមានលក្ខណៈជាលោកិយនិយមផង ជាមនុស្សនិយមផង ដែលឲ្យតម្លៃទៅលើផលប្រយោជន៍បច្ចុប្បន្ន និងឲ្យតម្លៃទៅលើសមត្ថភាពមនុស្ស ។

– ក្នុងភាសា ខ្មែរបានយកភាសាបាលី សំស្ក្រឹតមកប្រើផង តែបានធ្វើឲ្យទៅជាបែបខ្មែរអស់ទៅហើយ ដូចពាក្យបុណ្យ, បាប, ប្រព្រឹត្ត, ព្រឹក្សព្រៃ, ព្រះភក្ត្រជាដើម ។

– ក្នុងសាសនា ខ្មែរបានកែខ្លះលក្ខណៈ នៃសាសនាព្រាហ្មណ៍គឺដូចក្នុងសាសនាពុទ្ធដែរ ឲ្យមានលក្ខណៈនៃការគោរពប្រតិបត្តិពិធីផ្សេងៗ ឲ្យមានលក្ខណៈជាខ្មែរ ស្របស្រួលទៅនឹងសន្តិម ទឹកចិត្តខ្មែរទាំងអស់ ។

ប្រពៃណីខ្មែរ គឺដូចប្រពៃណីនៃជនជាតិឯទៀតៗដែរ គឺជាផលនៃការប៉ះទង្គិចគ្នានៃប្រពៃណី ១ និងប្រពៃណីទឹកចិត្តបំណងនៃជាតិ១ នេះឯង ហើយកាលណាជាតិ១ យកប្រពៃណីជាតិ១ ទៅប្រើ ក៏កែច្នៃប្រពៃណីនោះ ឲ្យមានលក្ខណៈស្របតាមមនោសាស្ត្រ ចំពោះទំនងចិត្តរបស់ខ្លួនជាដរាប ។

ដូច្នេះ ប្រពៃណីខ្មែរមិនមែនជាប្រពៃណីឥណ្ឌាឡើយ គឺប៉ុន្តែ គឺជាផលនៃការទាក់ទងរវាងឥណ្ឌានិងខ្មែរ ព្រោះរូបសំណាកដើមរបស់ឥណ្ឌា បានបាត់បង់ស្ទើរតែអស់ទៅក្នុងប្រពៃណីខ្មែរនេះទៅហើយ ។ ការបកប្រែនេះបានចេញជាផល ១ ទៀតនៃប្រពៃណីខ្មែរនេះឯង ។

-ចប់-

## ដំណឹងពិសេស

សូមប្អូនៗ រៀននៅថ្នាក់ទីបញ្ចប់ កុំភ្លេចស្វែងរកទិញសៀវភៅ "បរមាធិប្បាយខ្មែរ" និពន្ធដោយលោក គឹម – សែត ។ សៀវភៅថ្មីនេះមានប្រធានពណ្ណ - ខ្មែរ ប្រធានទស្សនវិជ្ជា ប្រធានតីមួយៗ សុទ្ធតែមានសេចក្តីណែនាំ សេចក្តីអធិប្បាយគំរូយ៉ាងសព្វគ្រប់ ។

តម្កល់ទុកត្រឹមត្រូវតាមច្បាប់ លេខ ១០១៩
ចុះថ្ងៃទី ១-៩-១៩៧១
បោះពុម្ពលើកទី ១ ចំនួន ១០០០ ក្បាល